# ព្រឹត្តិបត្រមេធាវី

លេខ ១៧

ខែ មេសា-មិថុនា ឆ្នាំ ២០១៨

រក្សាសិទ្ធិ © 2018 គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា

មតិដែលសំដែងនៅក្នុងព្រឹត្តិបត្រនេះ គឺជាមតិរបស់អ្នកនិពន្ធផ្ទាល់ ហើយមិនបញ្ជាំងនូវទស្សនៈរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាឡើយ។

ស្របតាមគោលការណ៍សេរីភាពនៃការបញ្ចេញមតិ ដែលជាគោលការណ៍គ្រឹះ និងមានចែងនៅក្នុងរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា គណៈមេធាវីគាំទ្រឱ្យមានភាពចម្រុះនៃមតិនានា។

សូមរក្សាសិទ្ធិ © ដោយអនុលោមតាមច្បាប់ស្តីពី "សិទ្ធិអ្នកនិពន្ធ និងប្រហាក់ប្រហែល" ដែលត្រូវបានប្រកាសឲ្យប្រើដោយ ព្រះរាជក្រមលេខ នស/រកម/០៣០៣/០០៨ ចុះថ្ងៃទី៥ ខែមីនា ឆ្នាំ២០០៣ ហើយរាល់ការថតចម្លងឡើងវិញ ដោយគ្មានការអនុញ្ញាតពីគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាត្រូវហាមឃាត់។

# មាតិកា

ទំព័រ


**សារពីប្រធានគណៈមេធាវី** ........ III

**ផ្នែកការងារ**

**ការរំលាយកិច្ចសន្យាការងារមិនកំណត់ថិរវេលា** ........ 1

១. សេចក្តីផ្តើម ........ 1

២. ហេតុផលនៃការរំលាយកិច្ចសន្យា ........ 1

៣. កាតព្វកិច្ចជូនដំណឹង ........ 3

៤. ប្រាក់បំណាច់ទូទាត់ក្នុងការរំលាយកិច្ចសន្យា ........ 3

៥. ប្រាក់សោហ៊ុយជម្ងឺចិត្ត ........ 6

**ផ្នែកពាណិជ្ជកម្ម**

**យុត្តាធិការរបស់តុលាការ ក្នុងបណ្តឹងបញ្ជូនវិវាទទៅមជ្ឈត្តការ**

**ពាណិជ្ជកម្ម** ........ 11

១. ការវិវឌ្ឍន៍និងការដាក់មជ្ឈត្តការក្នុងបញ្ញត្តិច្បាប់ ........ 11

២. យុត្តាធិការរបស់តុលាការ ក្នុងការអនុវត្តកិច្ចព្រមព្រៀងមជ្ឈត្តការ ........ 13

៣. បញ្ហាទាក់ទងនឹងការចាត់ការរបស់តុលាការ ក្នុងករណីគ្មានបណ្តឹងសុំឲ្យតុលាការ
បញ្ជូនវិវាទត្រឡប់ទៅមជ្ឈត្តការ ឬមានកិច្ចព្រមព្រៀងមជ្ឈត្តការ ........ 17

៤. សេចក្តីសន្និដ្ឋាន ........ 26

**ផ្នែករដ្ឋប្បវេណី**

**ការសុំកូន** ........ 31

ជំពូកទី១ សុំកូនពេញលេញ ........ 31

ផ្នែកទី១: លក្ខណៈនៃសុំកូនពេញលេញ ........ 31

ផ្នែកទី២: លក្ខខណ្ឌនៃសុំកូនពេញលេញ ........ 31

ផ្នែកទី៣: អានុភាពនៃសុំកូនពេញលេញ ........ 32

ផ្នែកទី៤: ការកាត់កាល់សុំកូនពេញលេញ ........ 33

ជំពូកទី២ ស្មុំកូនធម្មតា ........ 35
ផ្នែកទី១: លក្ខខណ្ឌនៃស្មុំកូនធម្មតា ........ 35
ផ្នែកទី២:អានុភាពនៃស្មុំកូនធម្មតា ........ 36
ផ្នែកទី៣:ការកាត់កាល់ស្មុំកូនធម្មតា ........ 37
ជំពូកទី៣ ទិដ្ឋភាពទូទៅនៃស្មុំកូនអន្តរប្រទេស ........ 39
១ - ទិដ្ឋភាពទូទៅនៃការស្មុំកូនអន្តរប្រទេស ........ 39
ផ្នែកទី១: សញ្ញាណទូទៅនៃការស្មុំកូនអន្តរប្រទេស ........ 39
ផ្នែកទី២: លក្ខខណ្ឌសម្រាប់ស្មុំកូនអន្តរប្រទេស ........ 43
ផ្នែកទី៣: ទណ្ឌកម្ម ........ 48
២- អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការស្មុំកូនអន្តរប្រទេស ........ 51
៣- នីតិវិធីស្មុំកូនអន្តរប្រទេស ........ 58

## សកម្មភាពរបស់គណៈមេធាវី

**១. ទំនាក់ទំនងជាតិ និងអន្តរជាតិ** ........ 73
១.១ ទំនាក់ទំនងជាតិ ........ 73
១.២ ទំនាក់ទំងអន្តរជាតិ ........ 75
**២. សកម្មភាពផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា** ........ 79
**៣. កិច្ចប្រជុំប្រតិភូមេធាវីរាជធានី/ខេត្តប្រចាំត្រីមាស** ........ 83
**៤. សេចក្តីជូនដំណឹង និងសេចក្តីសម្រេចផ្សេងៗក្នុងត្រីមាសទី២** ........ 85
៤.១ សេចក្តីណែនាំស្តីពី ការធ្វើលិខិតបញ្ជាក់អតីតភាពការងារជំនួយការមេធាវី ..... 85
៤. ២ សេចក្តីជូនដំណឹងស្តីពី ទំរង់របាយការណ៍បញ្ចប់កម្មសិក្សាថ្មី ........ 86

# សារពីប្រធានគណៈមេធាវី



គណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជាមានកិត្តិយស សូមបោះពុម្ពបន្តនូវ ព្រឹត្តិបត្រមេធាវីលេខ ១៧ សម្រាប់ត្រីមាសទី២ ខែមេសា-មិថុនា ឆ្នាំ២០១៨។ ព្រឹត្តិបត្រមេធាវីនេះ បានសម្រេចឡើងដោយ ការប្រឹងប្រែង លះបង់ពេលវេលាដ៏មាន តម្លៃរបស់អ្នកនិពន្ធនីមួយៗ ដើម្បីចែករំលែកចំណេះដឹង និងបទពិសោធន៍របស់គាត់។ តាងនាមឱ្យគណៈមេធាវី ខ្ញុំសូមថ្លែងអំណរគុណដល់អ្នកនិពន្ធ ដែលបានរួមចំណែក វិភាគទានអត្ថបទរបស់ខ្លួន។ ខ្ញុំក៏សូមថ្លែងអំណរគុណផងដែរ ដល់លោកអគ្គលេខាធិការ លោកអគ្គ-លេខាធិការរង ប្រធាន បុគ្គលិក និងអ្នកស្ម័គ្រចិត្ត នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វ-ផ្សាយនៃគណៈមេធាវីដែលបានខិតខំរៀបចំពិនិត្យ និងសម្រួលអត្ថបទ និងការបោះពុម្ពព្រឹត្តិបត្រលេខនេះ។

ព្រឹត្តិបត្រលេខនេះប្រមូលផ្តុំនូវអត្ថបទនៅក្នុងវិស័យនានានៃច្បាប់ ដូចជា ច្បាប់ការងារ ច្បាប់ពាណិជ្ជកម្ម និងច្បាប់រដ្ឋប្បវេណីជាដើម។ បន្ថែមលើការផ្សាយនូវអត្ថបទច្បាប់ ព្រឹត្តិបត្រមេធាវីបានផ្តល់ព័ត៌មានស្តីពី សកម្មភាពនៃគណៈមេធាវីដើម្បីឲ្យសហភាតាជាមេធាវីបានជ្រាបពីកិច្ចដំណើការនៃ គណៈមេធាវី។ គណៈមេធាវីនឹងស្វះស្វែងទាក់ទងមេធាវី និងអ្នកច្បាប់ដទៃទៀត ដើម្បីពង្រីកការចែករំលែកនូវចំណេះដឹងនៅក្នុងវិស័យដទៃទៀត នៅក្នុងការផ្សាយលើកក្រោយៗ។

ការបោះពុម្ពផ្សាយព្រឹត្តិបត្រមេធាវីនេះជាការឆ្លើយតបទៅនឹង**ទិសដៅទី ២ "ពង្រឹង និងការពារវិជ្ជាជីវៈ"** **នៃផែនការសកម្មភាពនៃគណៈមេធាវី** ដែលបានអនុម័តដោយក្រុមប្រឹក្សា-គណៈមេធាវី។

ខ្ញុំសង្កេតឃើញថា នៅក្នុងសហគមន៍អ្នកច្បាប់នៅក្នុងព្រះរាជាណាចក្រកម្ពុជាយើងមានអ្នកជំនាញខាងច្បាប់ជាច្រើន ដែលបានសរសេរផ្សព្វផ្សាយសៀវភៅសិក្សា ដើម្បីបម្រើសេចក្តីត្រូវការនៃអ្នកសិក្សាច្បាប់។ ទោះបីមិនមែនជាអ្នកជំនាញក៏ដោយ ខ្ញុំសូមលើកទឹកចិត្តដល់មេធាវី និងអ្នកសិក្សាទូទៅចូលរួមវិភាគទានអត្ថបទ ដើម្បីចុះផ្សាយក្នុងព្រឹត្តិបត្រមេធាវី។

គណៈមេធាវីស្វាគមន៍ជានិច្ច ដល់ការចូលរួមចែករំលែកអត្ថបទរបស់ខ្លួននៅក្នុងព្រឹត្តិបត្រនេះ។ ចំពោះអ្នកដែលមានបំណិនខាងសរសេរមានកម្រិត គណៈមេធាវីមានក្រុមបណ្ណាធិការមួយ ដែលនឹងជួយផ្ដល់ការណែនាំដល់អ្នកចូលរួម និងជួយកែសម្រួលអត្ថបទ។ គោលដៅនៃការបង្កើតព្រឹត្តិបត្រនេះ មិនត្រឹមតែផ្សព្វផ្សាយអត្ថបទនៃអ្នកនិពន្ធជើងចាស់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយលើកស្ទួយបំណិនខាងសរសេរដល់អ្នកនិពន្ធជំនាន់ក្រោយផងដែរ។

ខ្ញុំយល់ឃើញថា ថ្វីបើក្រុមបណ្ណាធិការបានផ្ចិតផ្ចង់ក្នុងការធ្វើឲ្យព្រឹត្តិបត្រទទួលបានគុណភាពមួយដ៏ខ្ពស់ក៏ដោយ ការខ្វះខាតគង់តែជៀសមិនផុត។ ដើម្បីជ្រោមជ្រែងឲ្យព្រឹត្តិបត្រនេះមានគុណភាពកាន់តែប្រសើរ ខ្ញុំសូមអំពាវនាវដល់អ្នកអានមេត្តាសរសេរតប និងរិះគន់ស្ថាបនា ធ្វើអត្ថាធិប្បាយ ឬបំពេញបន្ថែមទៅលើអត្ថបទនីមួយៗដែលបានបោះពុម្ពផ្សាយ។ ខ្ញុំសង្ឃឹមថា សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីនឹងបានរីករាយក្នុងការអានព្រឹត្តិបត្រមេធាវីលេខនេះ។

ចំពោះការចូលរួមវិភាគអត្ថបទ សូមធ្វើការទាក់ទងមកការិយាល័យគណៈមេធាវីដោយផ្ទាល់តាមរយៈលោកមេធាវី **ភុយ នាម** តាមអ៊ីម៉ែល neam130@bakc.org.kh និងលោកមេធាវី **កែ ប៊ុនធឿន** តាមអ៊ីម៉ែល bunthoeurn@bakc.org.kh ក៏បាន។

ជាទីបញ្ចប់ ខ្ញុំសូមជូនពរដល់សហភាតា ឯកឧត្តម លោកជំទាវ និងអស់លោក លោកស្រីទាំងអស់ សូមជួបតែជោគជ័យគ្រប់ប្រការ។

សូមអរគុណ!

ថ្ងៃសុក្រ ២រោច ខែបឋមាសាឍ ឆ្នាំ ច នព្វស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០១៨

**សួន វិសាល**

ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា

# ផ្នែកការងារ

# ការរំលាយកិច្ចសន្យាការងារមិនកំណត់ថិរវេលា

ដោយលោកមេធាវី ហំ ភា[1]

## ១. សេចក្តីផ្តើម

ការរំលាយកិច្ចសន្យា គឺជាប្រធានបទដ៏ក្តៅគគុក និងស្មុគស្មាញ នៅក្នុងទំនាក់ទំនងរវាងភាគីនៃកិច្ចសន្យា។ កិច្ចសន្យាការងារក៏មិនខុសពីកិច្ចសន្យាទូទៅប៉ុន្មានដែរ គឺមានការបង្កើតកិច្ចសន្យាការងារ ការប្រតិបត្តិកិច្ចសន្យាការងារ ការបន្តកិច្ចសន្យាការងារ និងចុងក្រោយគឺការរំលាយកិច្ចសន្យាការងារ។

ភាគីនៃកិច្ចសន្យាការងារត្រូវពិចារណាអំពីអង្គហេតុ ហេតុផល និងអង្គច្បាប់ឲ្យបានច្បាស់លាស់មុននឹងសម្រេចចិត្តរំលាយកិច្ចសន្យា ពីព្រោះការរំលាយកិច្ចសន្យាការងារ វាជាប់ពាក់ព័ន្ធទៅនឹងការបង់ប្រាក់បំណាច់ផ្សេងៗ និងសោហ៊ុយជម្ងឺចិត្ត។ លើសពីនេះ ភាគីនៃកិច្ចសន្យាក៏ត្រូវពិនិត្យមើលប្រភេទកិច្ចសន្យាផងដែរ ថាតើវាជាកិច្ចសន្យាការងារមានថិរវេលាកំណត់ (FDC) ឬ កិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC)។

ក្នុងអត្ថបទនេះ សូមលើកយកតែការរំលាយកិច្ចសន្យាការងារមានថិរវេលាមិនកំណត់ (UDC) តែប៉ុណ្ណោះ។

តើភាគីដែលចង់រំលាយកិច្ចសន្យាត្រូវដូចម្តេចខ្លះទើបត្រឹមត្រូវតាមច្បាប់?

## ២. ហេតុផលនៃការរំលាយកិច្ចសន្យា

មាត្រា៧៤(១) នៃច្បាប់ស្តីការងារចែងថា ***"កិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់ អាចរំលាយតាមឆន្ទៈភាគីតែម្ខាងបាន។ ការរំលាយកិច្ចសន្យានេះត្រូវអនុវត្តទៅតាមរបៀបឲ្យដំណឹងមុនជាលាយល័ក្ខណ៍អក្សរ ដែលភាគីមានបំណងចង់រំលាយកិច្ចសន្យាត្រូវឲ្យទៅភាគីម្ខាងទៀត។"***

---

[1] អ្នកនិពន្ធបច្ចុប្បន្នធ្វើការជាមេធាវី ជាស្ថាបនិក និងជាប្រធានការិយាល័យមេធាវី គ្លូ រី (Glory Legal) ។ លោកជាអនុប្រធានគណៈកម្មការកិច្ចការការងារនៃគណៈមេធាវីផងដែរ។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិឯកជនសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច។ លោកអតីតមន្ត្រីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ និងជាអតីតមន្ត្រីលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។ លោកមេធាវីបានចូលរួមផ្សព្វផ្សាយច្បាប់ស្តីពី ការងារនៅគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាច្រើនឆ្នាំ។

យោងតាមមាត្រាខាងលើនេះ ច្បាប់ស្តីពីការងារមិនបានតម្រូវហេតុផលជាក់លាក់សម្រាប់កម្មករនិយោជិតដែលមានបំណងរំលាយកិច្ចសន្យា UDC នោះទេ។ ប៉ុន្តែ ច្បាប់តម្រូវឲ្យមានជូនដំណឹងមុន ជាលាយលក្ខណ៍អក្សរទៅភាគីម្ខាងទៀត ដែលនឹងពិភាក្សាខាងក្រោម។

ប៉ុន្តែការរំលាយកិច្ចសន្យាការងារ ដោយនិយោជកអាចធ្វើបានក្នុងករណីហេតុផលសមរម្យ។

មាត្រា៧៤(២) *ក៏ប៉ុន្តែ គ្មានការបញ្ឈប់ណាមួយអាចធ្វើទៅបានដោយគ្មានហេតុផលសមរម្យទាក់ទងនឹងសម្បទា ឬចរិយានៃកម្មករនិយោជិត យោងទៅលើភាពចាំបាច់នៃដំណើររបស់សហគ្រាសរបស់គ្រឹះស្ថាន ឬរបស់ក្រុមឡើយ"*។

១. ជំនាញ ឬគុណសម្បត្តិក្នុងការបំពេញការងាររបស់កម្មករនិយោជិត

២. អាក្បកិរិយា ចរិយានៃកម្មករនិយោជិត ឬ

៣. ស្ថានភាពចាំបាច់នៃដំណើរការរបស់សហគ្រាស គ្រឹះស្ថាន ឬក្រុម។

ច្បាប់អនុញ្ញាតឲ្យនិយោជករំលាយកិច្ចសន្យាបាន និយោជកត្រូវតែមានលទ្ធភាពបង្ហាញភស្តុតាងគាំទ្រនូវចំណុចហេតុផលត្រឹមត្រូវ។

តើហេតុផលដូចម្តេចជាហេតុផលត្រឹមត្រូវ? ហេតុផលត្រឹមត្រូវ គឺជាការអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសនៅពេលនិយោជកដាក់ពិន័យដល់កម្មករនិយោជិតណាម្នាក់។ មាននិយោជកមួយចំនួន មិនបានដាក់វិន័យទៅតាមបទបញ្ជាផ្ទៃក្នុងពេលដាក់វិន័យកម្មករនិយោជិតនោះ។ កម្មករនិយោជិតបានប្តឹងនិយោជក និងទាមទារឲ្យនិយោជកផ្តល់សោហ៊ុយជម្ងឺចិត្ត។ និយោជកបានអះអាងថា ការបញ្ឈប់កម្មករនិយោជិតពីការងារ ដោយកម្មករនិយោជិតមានកំហុសធ្ងន់ ប៉ុន្តែអ្វីដែលនិយោជកលើកឡើងមិនមានចែងក្នុងមាត្រា៨៣ នៃច្បាប់ស្តីពីការងារ ឬបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាសទេ។

ច្បាប់តម្រូវឲ្យនិយោជក មានបទបញ្ជាផ្ទៃក្នុង មាត្រា២២នៃច្បាប់ស្តីពីការងាចែងថា *"និយោជកនៃសហគ្រាស ឬគ្រឹះស្ថានដែលមានចែងក្នុងមាត្រា ១៧ ខាងលើ ហើយដែលមានកម្មករ និយោជិតយ៉ាងតិច៨នាក់ត្រូវរៀបចំឲ្យមានបទបញ្ជាផ្ទៃក្នុងមួយជាដ៏រាប។"* មិនតែប៉ុណ្ណោះ ច្បាប់បានបើកសិទ្ធិឲ្យនិយោជកចែងកំណត់អំពីទង្វើ សកម្មភាពដែលជាកំហុសកម្មករនិយោជិតនៅក្នុងបទបញ្ជាផ្ទៃក្នុង។

**"និយោជកត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុង នៅពេលដាក់វិន័យកម្មករនិយោជិត"។ យុត្តិសាស្ត្ររបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៃសំណុំរឿងលេខ ២៦/០៦, ៣៣/០៦,៤៣/០៦។**

## ៣. កាតព្វកិច្ចជូនដំណឹង

ច្បាប់តម្រូវឲ្យភាគីដែលចង់រំលាយ ត្រូវជូនដំណឹងទៅភាគីម្ខាងទៀតជាលក្ខខណ្ឌទៅតាមរយៈពេលដែលបានបំពេញការងារ។ នេះបានន័យថា មិនថាតែនិយោជកនោះទេដែលត្រូវបំពេញកាតព្វជូនដំណឹងមុន តែកម្មករនិយោជិតដែលចង់លាឈប់ក៏ត្រូវបំពេញកាតព្វកិច្ចជូនដំណឹងមុននេះដែរ។

មាត្រា ៧៥ នៃច្បាប់ស្តីពីការងារកំណត់អំពីរយៈពេលជូនដំណឹងអប្បបរមា៖

| រយៈពេលនៃការងារ | រយៈពេលជូនដំណឹងអប្បបរមា |
|---|---|
| ៦ខែ ឬតិចជាង | ៧ថ្ងៃ |
| ៦ខែ ដល់ ២ឆ្នាំ | ១៥ថ្ងៃ |
| លើសពី ២ឆ្នាំ ដល់ ៥ឆ្នាំ | ១ខែ |
| លើសពី ៥ឆ្នាំ ដល់ ១០ឆ្នាំ | ២ខែ |
| លើសពី១០ឆ្នាំ | ៣ខែ |

ថិរវេលានៃការជូនដំណឹងក្នុងតារាងខាងលើនេះ គឺជាថិរវេលាអប្បបរមា។ កិច្ចសន្យាការងារ បទបញ្ជាផ្ទៃក្នុង ការយល់ព្រមរៀងៗខ្លួនដទៃទៀត ដែលកំណត់ថិរវេលាឲ្យដំណឹងមុនតិចជាងនេះ ត្រូវទុកមោឃៈដោយពេញច្បាប់, មាត្រា ៧៦នៃច្បាប់ស្តីពីការងារ។

មិនតម្រូវឲ្យមានការជូនដំណឹងមុនទេ ក្នុងករណីការរំលាយកិច្ចសន្យាដោយសារកំហុសធ្ងន់ដូចមានចែងក្នុងមាត្រា៨៣នៃច្បាប់ស្តីពីការងារ ឬក្នុងបទបញ្ជាផ្ទៃក្នុងឡើយ។

ក្នុងអំឡុងពេលជូនដំណឹង កម្មករនិយោជិតមានសិទ្ធិឈប់សម្រាក២ថ្ងៃក្នុង១សប្តាហ៍ដោយមានប្រាក់ឈ្នួលដើម្បីស្វែងរកការងារថ្មី (មាត្រា៧៨នៃច្បាប់ស្តីពីការងារ)។

ក្នុងករណីនិយោជកខកខានមិនបានជូនដំណឹងមុន បើកសិទ្ធិឲ្យកម្មករនិយោជិតទទួលបានសំណងទូទាត់ជួសការជូនដំណឹងមុនដែលស្មើនឹងប្រាក់ឈ្នួល និង អត្ថប្រយោជន៍ផ្សេងៗដែលអាចទទួលបានក្នុងរយៈពេលជូនដំណឹងនេះ (មាត្រា ៧៧នៃនៃច្បាប់ស្តីពីការងារ)។

## ៤. ប្រាក់បំណាច់ទូទាត់ក្នុងការរំលាយកិច្ចសន្យា

ច្បាប់ស្តីពីការងារមាត្រា៨៩ចាស់ អនុញ្ញាតឲ្យនិយោជករំលាយកិច្ចសន្យាការងារដោយឆន្ទៈម្ខាងរបស់ខ្លួនបាន ប៉ុន្តែនិយោជកត្រូវផ្តល់ប្រាក់បំណាច់បណ្តេញចេញជូនកម្ម

ករនិយោជិត។ រីឯការរំលាយកិច្ចសន្យាការងារ ដោយសារមូលហេតុនៃកំហុសធ្ងន់របស់កម្មករនិយោជិតនិយោជកគ្មានកាតព្វកិច្ចផ្តល់នូវប្រាក់បំណាច់បណ្តេញចេញទេ។

មាត្រា៨៩ នៃច្បាប់ស្តីពីការងារ ត្រូវបានរដ្ឋសភាធ្វើវិសោធនកម្ម ហើយប្រកាសឲ្យប្រើកាលពីថ្ងៃទី២៦ ខែមិថុនា ឆ្នាំ២០១៨។ ផ្អែកតាមមាត្រា៨៩ថ្មី ប្រាក់បំណាច់បណ្តេញចេញត្រូវបានប្តូរមកជាប្រាក់បំណាច់អតីតភាពការងារវិញ។ មាត្រានេះបានបញ្ញត្តិតម្រូវឲ្យនិយោជកផ្តល់ប្រាក់បំណាច់អតីតភាពការងារ ជូនកម្មករនិយោជិត ដែលកំពុងមប្រើការងារនូវប្រាក់បំណាច់ស្មើនឹងប្រាក់ឈ្នួល និងប្រាក់បន្ទាប់បន្សំចំនួន ១៥ (ដប់ប្រាំ) ថ្ងៃក្នុង១ឆ្នាំ។ មាត្រានេះក៏បានតម្រូវឲ្យនិយោជកទូទាត់ប្រាក់បំណាច់នេះជូនកម្មករនិយោជិត ចំនួនពាក់កណ្តាលរៀងរាល់៦ខែម្តង។

ផ្អែកតាមខ្លឹមសារនៃមាត្រា៨៩ថ្មីនេះ ការរំលាយកិច្ចសន្យាការងារ មាន៣ប្រភេទគឺ៖

### ១) ការរំលាយកិច្ចសន្យាការងារស្របតាមបញ្ញត្តិនៃច្បាប់ស្តីពីការងារ

ការរំលាយកិច្ចសន្យាការងារដែលស្របតាមបញ្ញត្តិច្បាប់ និយោជកក៏ត្រូវផ្តល់ប្រាក់បំណាច់អតីតភាពការងារជូនកម្មករនិយោជិតដែរ។ ឧ. ក្រុមហ៊ុន(ក) បានជួលបុគ្គលិក(ខ) ឲ្យធ្វើការមានកិច្ចសន្យាមិនកំណត់ចិរវេលា។ ក្រុមហ៊ុនបានព្រមានបុគ្គលិកនោះចំនួន៣ដង ផ្អែកតាមបទបញ្ជាផ្ទៃក្នុង ពីបទមកធ្វើការយឺត។ ពេលបុគ្គលិក(ខ) បានមកធ្វើការយឺតជាលើកទី៤ ក្រុមហ៊ុនក៏បានសម្រេចបញ្ឈប់បុគ្គលិក(ខ) ពីការងារ។ ក្នុងករណីនេះក្រុមហ៊ុន(ក) បានរំលាយកិច្ចសន្យាការងារជាមួយកម្មករ និយោជិតឈ្មោះ(ខ) ដោយស្របតាមបញ្ញត្តិច្បាប់ស្តីពីការងារ។ ដូច្នេះនិយោជកត្រូវតែឲ្យទៅកម្មករនិយោជិត នូវប្រាក់បំណាច់អតីតភាពការងារស្មើនឹងប្រាក់ឈ្នួលនិងប្រាក់បន្ទាប់បន្សំចំនួន៧ថ្ងៃ។

### ២) ការរំលាយកិច្ចសន្យាការងារដោយកម្មករនិយោជិតមានជម្ងឺ

ច្បាប់ស្តីពីការងារ អនុញ្ញាតឲ្យនិយោជកមានសិទ្ធិបញ្ឈប់កម្មករនិយោជិត ដែលមានជម្ងឺដែរ ប៉ុន្តែច្បាប់តម្រូវឲ្យនិយោជកផ្តល់ប្រាក់បំណាច់អតីតភាពការងារដល់កម្មករនិយោជិត។ ការបញ្ឈប់ដោយមូលហេតុកម្មករនិយោជិតមានជម្ងឺនេះ និយោជកមិនត្រូវបញ្ឈប់តាមតែអំពើចិត្តនោះទេ ពោលគឺត្រូវអនុវត្តទៅតាមបទបញ្ជាផ្ទៃក្នុងរបស់សហគ្រាស។

### ៣) ការរំលាយកិច្ចសន្យាការងារដោយសារកម្មករនិយោជិតមានកំហុសធ្ងន់

ការរំលាយកិច្ចសន្យាការងារដោយសារ កម្មករនិយោជិតមានកំហុសធ្ងន់ គឺជាការបញ្ឈប់ការងារកម្មករនិយោជិត ដែលបំពានមាត្រា៨៣នៃច្បាប់ស្តីពីការងារ ការបំពានបទបញ្ជា

ផ្ទៃក្នុង និងបំពានមាត្រាផ្សេងទៀតនៃច្បាប់ស្តីពីការងារ ឬច្បាប់ស្តីពីសហជីព។ ក្នុងករណីកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកមានសិទ្ធិបញ្ឈប់ពីការងារដោយ មិនផ្តល់នូវប្រាក់បំណាច់អតីតភាពការងារទេ។ មាត្រា៨៩ថ្មី វាក្យខ័ណ្ឌទី២ ចែងថា *"ក្នុងករណីដែលការរំលាយកិច្ចសន្យាការងារនេះដោយកំហុសធ្ងន់របស់កម្មករនិយោជិត ប្រាក់បំណាច់អតីតភាពការងារមិនត្រូវបានផ្តល់ឲ្យទេ"*។

### ៤) ការរំលាយកិច្ចសន្យាការងារដោយគ្មានហេតុផលត្រឹមត្រូវ

ភាគីនៃកិច្ចសន្យាគឺ និយោជក និងកម្មករនិយោជិតដែលមានបំណងចង់រំលាយកិច្ចសន្យាការងារហើយរួចផុតពីកាតព្វកិច្ចសងសោហ៊ុយជម្ងឺចិត្តឲ្យភាគីម្ខាងទៀត ត្រូវតែមានហេតុផលត្រឹមត្រូវ។ បើភាគីណាមួយរំលាយកិច្ចសន្យាការងារដោយគ្មានហេតុផលត្រឹមត្រូវទេ នោះភាគីម្ខាងទៀតអាចទារសងសោហ៊ុយជម្ងឺចិត្តបាន។ មាត្រា៩១ថ្មី នៃច្បាប់ស្តីពីការងារចែងថា *"ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីណាមួយ ដោយគ្មានហេតុផលត្រឹមត្រូវ នោះអាចបើកសិទ្ធិឲ្យភាគីម្ខាងទៀតទារសងជម្ងឺចិត្តបាន"*។

ដូច្នេះការរំលាយកិច្ចសន្យាការងារដែលមានហេតុផលត្រឹមត្រូវ គឺជាការរំលាយកិច្ច-សន្យាដែលនិយោជិកអនុវត្តទៅតាមច្បាប់ស្តីពីការងារ និងបានដាក់វិន័យដល់កម្មករនិយោជិតមុនពេលឈានដល់ការរំលាយកិច្ចសន្យាកាងារ ឬបញ្ឈប់ពីការងារ។

### ៥) ប្រាក់ឈ្នួល និងប្រាក់បំណាច់ផ្សេងៗពេលរំលាយកិច្ចសន្យាការងារ

ការរំលាយកិច្ចសន្យាការងារ មានមានភាពងាយស្រ្ួលជាងការរំលាយកិច្ចសន្យាទូទៅ ប៉ុន្តែវាមានការជាប់ពាក់ព៍ន្ធទៅនឹង តើកម្មករនិយោជិតដែលខ្លួនត្រូវបញ្ឈប់មានកំហុសអ្វី? កំហុសស្រាល មធ្យម ឬកំហុសធ្ងន់។ កំហុសរបស់កម្មករនិយោជិត វាជាប់ពាកព័ន្ធនឹងប្រាក់បំណាច់ផ្សេងៗ ដែលទាមទារឲ្យភាគីទាំងពីរបង្ហាញភស្តុតាងច្បាស់លាស់ទៅលើកំហុសរបស់ភាគីនៃកិច្ចសន្យាការងារ ជាពិសេសភាគីនិយោជកត្រូវបង្ហាញនូវកំហុសរបស់កម្មករនិយោជិត។

ប្រសិនបើការរំលាយកិច្ចសន្យាការងារកម្មករនិយោជិតដែលមាន*កំហុសធ្ងន់* កម្មករនិយោជិតមានសិទ្ធិទទួលបានតែ*ប្រាក់ឈ្នួលនិងប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំតែប៉ុណ្ណោះ* (មាត្រា ១១៦ និងមាត្រា ១៦៧ នៃច្បាប់ស្តីពីការងារ)។

ចំពោះការរំលាយកិច្ចសន្យាការងារដោយ កម្មករនិយោជិតដែលកម្មករនិយោជិតក្រៅពីកំហុសធ្ងន់ កម្មករនិយោជិតត្រូវមានសិទ្ធិទទួលបានប្រាក់ទូទាត់ការជូនដំណឹងមុន ប្រាក់-

បំណាច់អតីតភាពការងារ សោហ៊ុយជម្ងឺចិត្ត និងប្រាក់ឈ្នួលដែលនៅសល់ និងប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ។

តាមច្បាប់ស្តីពីការងារ កាលណាមានការរំលាយកិច្ចសន្យាការងារ លើកលែងតែកម្មករនិយោជិតមានកំហុសធ្ងន់ និយោជកត្រូវបើកជូនកម្មករនិយោជិតនូវប្រាក់ឈ្នួល និងប្រាក់បំណាច់គ្រប់ប្រភេទ ក្នុងរយៈពេល៤៨ម៉ោង បន្ទាប់ពីឈប់ធ្វើការ។ តាមខ្លឹមសារនៃមាត្រានេះ និយោជកមិនត្រឹមតែបើកប្រាក់ឈ្នួលជូនកម្មករនិយោជិតប៉ុណ្ណោះទេ ថែមទាំងប្រាក់បំណាច់ផ្សេងៗទៀតផង ប្រាក់បំណាច់នេះមានដូចជា ប្រាក់ជូនដំណឹងមុន(ក្នុងករណីនិយោជកមិនបានជូនដំណឹងមុនជូនកម្មករនិយោជិត) ប្រាក់បំណាច់អតីតភាពការងារ ប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំ និង សោហ៊ុយជម្ងឺចិត្តជាដើម។

មាត្រា ១១៦នៃច្បាប់ស្តីពីការងារចែងថា៖ *"ក្នុងករណីរំលាយកិច្ចសន្យាការងារ ប្រាក់ឈ្នួល និងប្រាក់បំណាច់គ្រប់ប្រភេទត្រូវបើកក្នុងរយៈពេល៤៨ ម៉ោង បន្ទាប់ពីថ្ងៃឈប់ធ្វើការ"*។

## ៥. ប្រាក់សោហ៊ុយជម្ងឺចិត្ត

ការរំលាយកិច្ចសន្យាការងារដោយស្របតាមបញ្ញត្តិច្បាប់ និងមានហេតុផលត្រឹមត្រូវ ភាគីដែលរំលាយកិច្ចសន្យាគ្មានកាតព្វកិច្ចបង់ប្រាក់សោហ៊ុយជម្ងឺចិត្ត ឲ្យភាគីម្ខាងទៀតទេ។ ផ្ទុយទៅវិញការរំលាយកិច្ចសន្យាដែលគ្មានហេតុផលត្រឹមត្រូវ ភាគីម្ខាងទៀតនៃកិច្ចសន្យាអាចទាមទារសោហ៊ុយជម្ងឺចិត្តបាន។ ភាគីកម្មករនិយោជិត អាចទាមទារប្រាក់បំណាច់បើកផ្តាច់មួយដែលមានចំនួនស្មើប្រាក់បំណាច់អតីតភាពការងារដែលបាន និងត្រូវទទួលក្នុងអំឡុងពេលនៃកិច្ចសន្យាការងារ។ ក្នុងករណីនេះកម្មករនិយោជិត គ្មានកាតព្វកិច្ចក្នុងការបង្ហាញភស្តុតាងអំពីការខូចខាតរបស់ខ្លួនឡើយ។ មាត្រា ៩១ថ្មី ចែងថា *"ការរំលាយកិច្ចសន្យាការងារតាមឆន្ទៈផ្ទាល់នៃភាគីណាមួយ ដោយគ្មានហេតុផលត្រឹមត្រូវ នោះអាចបើកសិទ្ធិឲ្យភាគីម្ខាងទៀតទារសងសោហ៊ុយជំងឺចិត្តបាន។*

*សោហ៊ុយជំងឺចិត្តនេះមិនត្រូវច្រឡំគ្នាជាមួយនឹងប្រាក់បំណាច់ទូទាត់ជួសការឲ្យដំណឹងមុន ឬជាមួយនឹងប្រាក់បំណាច់អតីតភាពការងារទេ។*

*កម្មករនិយោជិត អាចទាមទារប្រាក់បំណាច់បើកផ្តាច់មួយ ដែលមានចំនួនស្មើនឹងប្រាក់បំណាច់អតីតភាពការងារដែលបាន និងត្រូវទទួលក្នុងអំឡុងពេលនៃកិច្ចសន្យាការងារ។*

*ក្នុងករណីនេះកម្មករនិយោជិតត្រូវបានរួចពីកាតព្វកិច្ចដែលត្រូវផ្តល់ភស្តុតាងបញ្ជាក់ពីការខូចខាតរបស់ខ្លួន"។*

លើសពីនេះទៅទៀត ប្រសិនបើភាគីកម្មករនិយោជិតទាមទារសោហ៊ុយជម្ងឺចិត្តលើសពីប្រាក់បំណាច់អតីតភាពការងារដែលបាន នឹងត្រូវទទួលក្នុងអំឡុងពេលនៃកិច្ចសន្យាការងារ។ ការសម្រេចលើការទាមទារនេះត្រូវសម្រេចដោយតុលាការដែលមានសមត្ថកិច្ច។ មាត្រា ៩៤ថ្មី ចែងថា *"ដោយមិនគិតដល់បទប្បញ្ញត្តិទាំងឡាយនៃមាត្រា៩១ថ្មីខាងលើ សោហ៊ុយជំងឺចិត្តដែលត្រូវឲ្យក្នុងករណីផ្តាច់កិច្ចសន្យាការងារដោយគ្មានហេតុផលត្រឹមត្រូវ ព្រមទាំងសោហ៊ុយជំងឺចិត្តដែលនិយោជកត្រូវបង់តាមបទប្បញ្ញត្តិនៃមាត្រា៩០ថ្មីខាងលើនេះ ត្រូវសម្រេចដោយតុលាការមានសមត្ថកិច្ច ដោយផ្អែកតាមទម្លាប់ស្រុក តាមប្រភេទ និងតាមទំហំនៃសេវាដែលបានចុះកិច្ចសន្យា តាមអតីតភាព តាមអាយុនៃកម្មករនិយោជិត តាមប្រាក់ដែលកាត់ទុក ឬសម្រាប់សោធននិវត្តន៍ ហើយជាទូទៅ តាមគ្រប់កាលៈទេសៈដែលអាចបញ្ជាក់ការខូចខាតដែលកើតមានឡើង និងទំហំនៃការខូចខាតនោះ"*។

ចំណុចសំខាន់មួយទៀត បន្ថែមពីហេតុផលសមរម្យ ក្នុងការរំលាយកិច្ចសន្យាការងារ និយោជកត្រូវពិនិត្យមើលថា តើកម្មករនិយោជិតដែលជាភាគីនៃកិច្ចសន្យា គាត់ជាថ្នាក់ដឹកនាំសហជីពដែរ ឬប្រតិភូបុគ្គលិកដែរទេ? ថ្នាក់ដឹកនាំសហជីពរួមមាន *ប្រធាន អនុប្រធាន និងលេខាធិការសហជីព*។ ប្រសិនជាពួកគាត់ជាថ្នាក់ដឹកនាំសហជីព ឬជាប្រតិភូបុគ្គលិក ច្បាប់មិនអនុញ្ញាតឲ្យនិយោជកបញ្ឈប់ពួកគាត់ពីការងារទេ ជិយោជកមានសិទ្ធិត្រឹមតែព្យួរកិច្ចសន្យាការងារ រួចស្នើសុំការអនុញ្ញាតបញ្ឈប់ពីការងារទៅនាយកដ្ឋានវិវាទការងារនៃក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈតែប៉ុណ្ណោះ។

យោងមាត្រា៤៣ នៃច្បាប់ស្តីពីសហជីពចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួនអាចធ្វើបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ។ វិធានការការពារទាំងឡាយដូចគ្នានេះត្រូវអនុវត្តចំពោះអតីតប្រតិភូបុគ្គលិកក្រោយពេលបញ្ចប់អាណត្តិរបស់ខ្លួន ៣(បី) ខែ និងក្នុងរយៈពេល ៣(បី) ខែចំពោះអតីតបេក្ខជនមិនជាប់ឆ្នោតក្រោយការប្រកាសលទ្ធផលនៃការបោះឆ្នោត។ រាល់គម្រោងផ្លាស់ប្តូរ ឬផ្ទេរការងាររបស់ប្រតិភូបុគ្គលិកដែលនាំឲ្យមានការបាត់បង់តំណែងក្នុងអាណត្តិ ក៏ត្រូវដាក់ឲ្យស្ថិតក្រោមនីតិវិធីនៃមាត្រានេះដែរ។*

*អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករ និយោជិតដូចមានចែងក្នុងមាត្រានេះត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក និងដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ក៏ដូចជាដល់សហជីពដែលគ្រប់គ្រងកម្មករ និយោជិតនោះក្នុងរយៈពេល ១(មួយ) ខែ យ៉ាងយូរ ក្រោយទទួលពាក្យបណ្តឹង។*

*បន្ទាប់ពីបានទទួលសេចក្តីសម្រេចនោះ និយោជក ឬកម្មករនិយោជិតដែលត្រូវបញ្ឈប់ ឬសហជីពរបស់កម្មករនិយោជិតនោះមានពេល ២ (ពីរ) ខែ ដើម្បីធ្វើការតវ៉ាទៅរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារ។ រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារអាចលុបចោល ឬកែសម្រួលសេចក្តីសម្រេចរបស់អធិការការងារ។*

*បើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់អធិការការងារក្នុងរយៈពេលដែលបានកំណត់ឲ្យទេ ឬបើគ្មានការជូនដំណឹងអំពីសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យការងារក្នុងរយៈពេល ២ (ពីរ) ខែ បន្ទាប់ពីបានទទួលការតវ៉ាតាមឋានានុក្រម ពាក្យបណ្តឹងនិងការតវ៉ានោះត្រូវចាត់ទុកថាបានបដិសេធចោល។*

# ផ្នែកពាណិជ្ជកម្ម

# យុត្តាធិការរបស់តុលាការ ក្នុងបណ្តឹងបញ្ជូនវិវាទទៅ មជ្ឈត្តការពាណិជ្ជកម្ម

លោក សឹម សុរិយ៉ា-

អត្ថបទនេះ ចាប់ផ្តើមពីការវិវឌ្ឍន៍ និងការដាក់មជ្ឈត្តការក្នុងបញ្ញត្តិច្បាប់ យុត្តាធិការជារួមរបស់តុលាការ ព្រមទាំងបង្ហាញបញ្ញត្តិ និងយុត្តិសាស្ត្រស្តីពី ការចាត់ការរបស់តុលាការ ករណីភាគីមិនបាន ឬបានដាក់បណ្តឹងបញ្ជូនរឿងទៅមជ្ឈត្តការ។

## ១. ការវិវឌ្ឍន៍និងការដាក់មជ្ឈត្តការក្នុងបញ្ញត្តិច្បាប់

ការដោះស្រាយវិវាទពាណិជ្ជកម្មតាមមជ្ឈត្តការមានន័យថា ភាគីព្រមព្រៀងដោះស្រាយក្នុងលក្ខណៈឯកជនរើស ដោយខ្លួនឯងនូវបុគ្គលម្នាក់ ឬច្រើននាក់មកធ្វើជាអាជ្ញាកណ្តាល ឬមជ្ឈតករ ហើយសន្យាគោរពតាមសេចក្តីសម្រេចរបស់មជ្ឈត្តករ។ ពីមុនដំណើរការការនេះប្រព្រឹត្តដោយ មិនមានការការពារពីប្រព័ន្ធតុលាការតាមច្បាប់របស់រដ្ឋទេ តែក្រោយមកបណ្តារដ្ឋនានាបានបញ្ញត្តិឲ្យតុលាការមានយុត្តាធិការមួយចំនួនតែមានកម្រិតក្នុងបំណងការពារ ឆន្ទៈភាគីដែលបានព្រមព្រៀងធ្វើមជ្ឈត្តការផង ហើយរក្សាទុកនូវសមត្ថកិច្ចតុលាការមួយចំនួនស្របតាមរដ្ឋធម្មនុញ្ញផង។

មជ្ឈត្តការដោយលក្ខណៈស្វ័យភាពភាគីដូចខាងលើនេះ បានកើតមានរាប់ពាន់ឆ្នាំកន្លងមក ពីព្រោះបើភាគីមកតុលាការត្រូវប្រឈមនឹងគ្រោះថ្នាក់ និងចំណាយច្រើន ហើយតុលាការមិនបានផ្តល់សេវាឆាប់រហ័ស និងខ្វះជំនាញពាណិជ្ជកម្ម តាមតម្រូវការជាក់ស្តែងរបស់

- លោកសឹម សុរិយ៉ា ពីខែវិច្ឆិកាឆ្នាំ២០១៧ដល់បច្ចុប្បន្ន មាននាទីជា អ្នកប្រឹក្សាការនៃសាលាក្តីខ្មែរក្រហម និងជា Senior Associate នៃ ក្រុមហ៊ុន Meng & Associates។ មុននេះ គាត់ជាប្រធានក្រុមវិភាគការិយាល័យសហចៅក្រមស៊ើបអង្កេតនៃសាលាក្តីខ្មែរក្រហម ទីប្រឹក្សាបច្ចេកទេសនៃក្រុមប្រឹក្សាអាជ្ញាកណ្តាល និងជានាយករងនៃមជ្ឈមណ្ឌលឯកសារកម្ពុជា។ នៅក្នុងវិស័យជម្លត្តការពាណិជ្ជកម្ម គាត់បានទទួលចំណាត់ថ្នាក់ខ្ពស់បំផុតក្នុងចំណោមនិស្សិតសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រនិងសេដ្ឋកិច្ច (សភនស) ដែលចូលរួមប្រកួតប្រជែងកម្មវិធីសវនាការតុលាការប្រឌិត Willem Vis Moot Court ឆ្នាំ២០១៦។ លោកនិងនិស្សិត៤នាក់ទៀតបានបន្តទៅប្រកួតក្នុងកម្មវិធីនេះនៅទីក្រុងហុងកុង។ អនុសារណៈរបស់ក្រុមនិស្សិត*សភនស* បានទទួល រង្វាន់កិត្តិយសHonorable Mention របស់ Eric Bergsten Award។ លោកទទួលបរិញ្ញាបត្រនីតិសាស្ត្រឆ្នាំ២០១៧ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ បរិញ្ញាប័ត្រអប់រំភាសាអង់គ្លេស ពីIFL នៃសាកលវិទ្យាល័យភូមិន្ទភ្នំពេញឆ្នាំ១៩៩៤ និង អនុបណ្ឌិតទំនាក់ទំនងអន្តរជាតិពីសាកលវិទ្យាល័យយែលYale University ឆ្នាំ១៩៩៧ (អាហារូបករណ៍Fulbright និង Yale)។

ពាណិជ្ជករ។[1] ជាមួយគ្នានេះ ដោយសារតែស្វ័យភាពរបស់ភាគីក្នុងការរើសយកមជ្ឈត្តករ គឺបានមកពីការការព្រមព្រៀង និងការជឿជាក់របស់គេ ពាណិជ្ជករមិនរំពឹងថានឹងមានវិវាទច្រើនដែលដោះស្រាយមិនបាន ហើយត្រូវតវ៉ាមកដល់តុលាការនោះទេ។ តុលាការភាគច្រើនមិនមានយុត្តាធិការអនុវត្តសេចក្តីបង្គាប់របស់មជ្ឈត្តការទេ ហើយដាក់មជ្ឈត្តការឲ្យនៅក្រៅប្រព័ន្ធតុលាការតែម្តង រហូតមកនៅសតវត្សទី២០ ទើបមានចាប់ផ្តើមពីច្បាប់មជ្ឈត្តការសហព័ន្ធឆ្នាំ១៩២៥ របស់សហរដ្ឋអាមេរិក បន្តបន្ទាប់នៅអឺរ៉ុប និងនៅអាស៊ី។[2] ព្រះរាជាណាចក្រកម្ពុជា ក៏ដូចគ្នា។

នៅឆ្នាំ១៩៥៤ ព្រះមហាក្សត្រកម្ពុជាបានត្រាស់បង្គាប់ *ព្រះរាជក្រមស្តីពីតាំងបទបញ្ញាអំពីទម្រង់ និងផលនៃកិច្ចសន្យាសម្រុះឬអនុញ្ញាតឲ្យមាន ខ សម្រុះក្នុងរឿងជំនួញ* ចែងពីកម្មវត្ថុដែលមិនអាចធ្វើកិច្ចសម្រុះបាន(មាត្រា២) ជនរាល់រូបអាចធ្វើសម្រុះនូវសិទ្ធិរបស់ខ្លួនបាន (មាត្រា៣) សមត្ថកិច្ចរបស់តុលាការ (មាត្រា២១ដល់៣០)។ បានន័យថា តាំងពីឆ្នាំ១៩៥៤មក មានបញ្ញត្តិច្បាប់ដែលអនុញ្ញាតឲ្យជនរាល់រូបអាចធ្វើ<u>សម្រុះនូវសិទ្ធិ</u>របស់ខ្លួន ភាសាបច្ចុប្បន្នហៅថា កិច្ចព្រមព្រៀងរបស់ភាគីក្នុងការធ្វើមជ្ឈត្តការដោយមិនចាំបាច់ដោះស្រាយវិវាទរបស់ខ្លួនឆ្លងតាមតុលាការទេ លើកលែងតែយោងមាត្រា២ និងមាត្រា២១ដល់មាត្រា៣០ ក្នុងលក្ខណៈប្រហាក់ប្រហែលគ្នានឹងច្បាប់ស្តីពី មជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦ដែលអ្នកនិពន្ធសង្ខេបទាំងស្រុងដាក់ក្នុងផ្នែកខាងក្រោម។ មាត្រាទាំងនេះ បានបញ្ញត្តិស្របទៅនឹងរដ្ឋធម្មនុញ្ញកម្ពុជាមាត្រា១២៩ ថ្មី ដែលចែងថា *មានតែ<u>ចៅក្រមទេដែលមានសិទ្ធិជម្រះក្តី</u>។ <u>ចៅក្រមត្រូវបំពេញភារកិច្ចនេះដោយគោរពច្បាប់</u>យ៉ាងម៉ឺងម៉ាត់ និងឲ្យអស់ពីដួងចិត្ត និងសម្បជញ្ញៈរបស់ខ្លួន* ដោយសារ យោងបញ្ញត្តិទាំងនេះ ចៅក្រមនៅតែមានសិទ្ធិជម្រះក្តី ហើយយោងរដ្ឋធម្មនុញ្ញចៅក្រមក៏ត្រូវអនុវត្តតាមច្បាប់ដែរ ទន្ទឹមគ្នានោះមជ្ឈត្តករក៏អាចសម្រេចក្តីបានដែរ តាមកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ។

ដើម្បីជាឯកសារពិគ្រោះឲ្យឃើញរូបភាពទាំងមូលនៃ យុត្តាធិការរបស់តុលាការក្នុងមជ្ឈត្តការពាណិជ្ជកម្ម ផ្នែកខាងក្រោមនេះ បានសង្ខេបតាមខ្លឹមសារដើមរបស់ច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦។ ទោះជាយ៉ាងណា ការបកស្រាយទាំងឡាយ ត្រូវតែយោងអត្ថបទច្បាប់ដើមទាំងស្រុង។

---

[1] Austermiller, Steven. *ការដោះស្រាយទំនាស់ក្រៅប្រព័ន្ធតុលាការក្នុងប្រទេសកម្ពុជា.* American Bar Association, 2009. Printed in Cambodia, p. 138, para.1

[2] Id., p. 138-139

## ២. យុត្តាធិការរបស់តុលាការ ក្នុងការអនុវត្តកិច្ចព្រមព្រៀងមជ្ឈត្តការ

### យោងច្បាប់ស្តីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦

ជាទូទៅតុលាការមិនត្រូវអន្តរាគមន៍ឡើយ លើកលែងតែមានលក្ខខណ្ឌដូចក្នុងមាត្រាខាងក្រោម។ បណ្តាប្រទេសដែលបានទទួលឥទ្ធិពល ឬមានច្បាប់ស្រដៀងគ្នា ឬចម្លងយកច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិបានប្រកាន់គោលការណ៍ដូចព្រះរាជាណាចក្រកម្ពុជាដែរ ពោលគឺ តុលាការអន្តរាគមន៍ លុះត្រាមានវិការៈទាក់ទងនឹងនិតីភាពនៃ៖ សមត្ថភាព ឬសម្បទាភាគី អត្តិភាព និងកម្មវត្ថុកិច្ចសន្យាមជ្ឈត្តការ នីតិវិធីនិងសមាសភាពវេទិកាមជ្ឈត្តកម្ម សិទ្ធិក្នុងការបង្ហាញករណីរបស់ភាគី ការជូនដំណឹងដល់ភាគី និងវិសមិតភាពជាមួយនយោបាយសាធារណៈ យោងមាត្រា៤៤ និង៤៦នៃច្បាប់ស្តីពីមជ្ឈត្តការពាណិជ្ជកម្ម។ ប្រព័ន្ធច្បាប់ណាក៏ដោយ សុទ្ធតែលើកទឹកចិត្តឲ្យមានភាពទៀងទាត់ ភាពទុកចិត្ត និងការយកចិត្តទុកដាក់របស់តុលាការថ្នាក់ក្រោម កុំឲ្យវិវាទមកគរចាល់នៅតុលាការថ្នាក់លើ ហេតុដូចនេះ ហើយបានជា ក្នុងការពិនិត្យវិការៈនេះ តុលាការថ្នាក់លើ កំណត់យកស្តង់ដារ ជាទូទៅមិនពិនិត្យឡើងវិញនូវតម្លៃនៃការសម្រេចរបស់តុលាការថ្នាក់ក្រោម ឬវេទិកាមជ្ឈត្តកម្មនោះទេ បានន័យថា មិនលូកដៃដោយសារតែតុលាការថ្នាក់ក្រោម ឬវេទិកាមជ្ឈត្តកម្មដែលយល់ឃើញខុសពីខ្លួននោះឡើយ លើកលែងតែមានកំហុសជាក់ស្តែងនៅនឹងមុខច្បាស់ក្រឡែត លើបញ្ហាច្បាប់ ឬភាគីទាំងពីរព្រមឧទ្ធរណ៍ ឬបញ្ហានោះមានសារៈសំខាន់ជាសាធារណៈ ហើយការសម្រេចរបស់វេទិកាមជ្ឈត្តកម្មធ្វើឲ្យមានការសង្ស័យ។ ករណីលើកលែងនេះ មាននៅប្រព័ន្ធខមិនឡ យ៉ាងហោចណាស់នៅអង់គ្លេសនិងអូស្ត្រាលីដែរ។[3]

ពាក់ព័ន្ធនឹងការអនុវត្តកិច្ចព្រមព្រៀងមជ្ឈត្តការតាមមាត្រា៨ ករណីមានភាគីប្តឹងសុំបញ្ជូនទៅមជ្ឈត្តការ តុលាការមិនត្រឹមតែពិចារណាលើលក្ខណៈរបស់កិច្ចព្រមព្រៀង (សុពលភាពនៃកិច្ចព្រមព្រៀង ការប្រព្រឹត្តទៅ លទ្ធភាពដែលអាចយកមកអនុវត្តន៍បាន[4]តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងពិចារណាថា តើកម្មវត្ថុដែលប្តឹងចំពោះមុខតុលាការនោះ ស្ថិតក្នុងវិសាលភាពកិច្ចព្រមព្រៀងហើយស្របច្បាប់ឬយ៉ាងណា ព្រមទាំងគិតពីពេលកំណត់នៃការប្តឹងបញ្ជូននោះ

---

[3] ច្បាប់មជ្ឈត្តការអង់គ្លេសឆ្នាំ១៩៩៦ Section 69(1), 69(2), 69(3)។ សាលដីកាតុលាការជាន់ខ្ពស់អូស្ត្រាលី House v. The King (1936) 55 CLR 499។

[4]សម្រាប់អង្គហេតុឬកាលៈទេសៈផ្សេងៗដែលមិនបានបំពេញលក្ខណៈកិច្ចព្រមព្រៀងហើយដែលតុលាការមិនបញ្ជូនវិវាទទៅមជ្ឈត្តការ សូមអានUNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៣៨ដល់៤៣

ផងដែរ[5] មិនមានយុត្តិសាស្ត្រដូចៗគ្នាទេ ចំពោះស្តង់ដា ឬទំហំដែលតុលាការត្រូវពិនិត្យលក្ខណៈកិច្ចព្រមព្រៀង តាមសំណើភាគីសុំបញ្ជូនទៅមជ្ឈត្តការនោះ ពោលគឺមានលាយឡំទាំង ការបង្ហាញជាដំបូង[6] និងទាំងការពិនិត្យពិស្តារ ព្រមទាំងអាស្រ័យដោយប្រភេទបញ្ហាដែលភាគីម្ខាងទៀតលើកជំទាស់ការបញ្ជូននោះផងដែរ។[7]

**មាត្រា៥** តុលាការមិនត្រូវអន្តរាគមន៍ឡើយ លើកលែងតែបានបញ្ញត្តិក្នុងច្បាប់នេះ។

**មាត្រា៨(១)** តុលាការ ត្រូវបញ្ជូនភាគីទៅខាងមជ្ឈត្តកម្ម ក្នុងករណីៈ

- កម្មវត្ថុដែលប្តឹងតុលាការ ជាកម្មវត្ថុស្ថិតក្រោមកិច្ចព្រមព្រៀងមជ្ឈត្តកម្ម និង
- ភាគីម្ខាងបានប្តឹងមិនយឺតយ៉ាវជាងពេលខ្លួនបានដាក់សេចក្តីសន្និដ្ឋានបឋមស្តីពីកម្មវត្ថុនៃវិវាទ និង
- កិច្ចព្រមព្រៀងនោះ មានសុពលភាព និងអាចដាក់ឲ្យអនុវត្តបាន។

**មាត្រា៨(១)** តុលាការ មិនត្រូវបញ្ជូនភាគីទៅខាងមជ្ឈត្តកម្មទេ បើខ្លួនសម្រេចថាលក្ខខណ្ឌណាមួយខាងលើ មិនបានបំពេញ។

**មាត្រា៨(២)** តុលាការ អាចបញ្ជូនបញ្ហាមួយទៅឲ្យអង្គមជ្ឈត្តកម្មពិនិត្យបាន ទោះជាបញ្ហានោះ បានកំពុងផ្អាកដោយអង្គមជ្ឈត្តកម្មក៏ដោយ ក្នុងករណីៈ

- មានបណ្តឹងពាក់ព័ន្ធនឹងកម្មវត្ថុនៃកិច្ចព្រមព្រៀងមជ្ឈត្តកម្ម យោងមាត្រា៨ (១) និង
- ដំណើរការមជ្ឈត្តកម្មនៅតែចាប់ផ្តើមឬបន្ត។

**មាត្រា៩** តុលាការ អាចសម្រេចលើបណ្តឹងសុំវិធានការរក្សាការពារបណ្តោះអាសន្ន ហើយខ្លឹមសារនៃវិធានការរក្សាការពារនោះ មិនមានវិសមិតភាពជាមួយកិច្ចព្រមព្រៀងមជ្ឈត្តកម្មទេ ករណីភាគីបានប្តឹងដូចនេះមុនឬក្នុងពេលដំណើរការមជ្ឈត្តកម្ម។

---

[5] UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៤៣កឋាខណ្ឌលេខ២៨

[6] ការបង្ហាញជាដំបូង មានន័យថា មិនបាច់ពិចារណាពិស្តារ ហើយបើតាមហេតុផលសត្យានុម័ត តើមនុស្សទីបី ដែលមានហេតុផល គិតថា មានកិច្ចព្រមព្រៀងមជ្ឈត្តការ នោះឬទេ។

[7] Margaret L. Moses, "The Principles and Practices of International Commercial Arbitration," New York: Cambridge University Press, 2012, pp. 87-95, 211-229។ UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration, pp. 44-47

**មាត្រា១៩** (៤)(៣)តុលាការអាចចាត់វិធានការចាំបាច់តាមសំណើភាគីណាមួយក្នុងការបង្កើតវេទិកាមជ្ឈត្តកម្ម ក្នុងករណី ភាគីឬមជ្ឈត្តករ រើសនិងបង្កើតអង្គមជ្ឈត្តរមិនស្រប តាមខនៃកិច្ចព្រមព្រៀងភាគីនិងនីតិវិធីចែងក្នុងមាត្រា១៩(៤)(៣)

**មាត្រា២១** តុលាការ អាចសម្រេចដោយបិទផ្លូវតវ៉ាបានលើ បណ្តឹងជិតចិត្តមជ្ឈត្តករ ករណីវិធីជំទាស់ដែលភាគីបានព្រមព្រៀងគ្នា ឬវិធីនានាដែលមានយោងតាមមាត្រា២១ (២) មិនបានជោគជ័យ។

**មាត្រា២២** តុលាការ អាចចាត់ការតាមសំណើរបស់ភាគី ហើយសេចក្តីសម្រេចនោះ បិទផ្លូវតវ៉ា ចំពោះករណីមជ្ឈត្តករចប់អាណត្តិ ដោយមូលហេតុ និងនីតិវិធីណាមួយយោងតាម មាត្រា២១និង២២ ហើយភាគីមិនយល់ស្របចំពោះមូលហេតុទាំងនោះ ។

**មាត្រា២៤(១)** វេទិកាមជ្ឈត្តកម្មអាចសម្រេចលើយុត្តាធិការរបស់ខ្លួន ដោយផ្អែកលើ ទំហំនៃអំណាចដែលកិច្ចព្រមព្រៀងមជ្ឈត្តការបានផ្តល់ឲ្យ និងផ្អែកលើសុពលភាពនៃកិច្ចសន្យា

**មាត្រា២៤(៣)** វេទិកាមជ្ឈត្តកម្ម អាចសម្រេច ក្នុងនីតិវិធីមុនសវនាការ ឬក្នុងសេចក្តី បង្គាប់ចំពោះការតវ៉ាថា វេទិកាមជ្ឈត្តកម្មមិនមានយុត្តាធិការ ឬកំពុងចាត់ការហួសពីទំហំនៃ អំណាចរបស់ខ្លួនយោងនីតិវិធីមាត្រា២៤(២)។ ក្នុងករណីនីតិវិធីមុនសវនាការ បើវេទិកា មជ្ឈត្តកម្មបានសម្រេចថាខ្លួនមានយុត្តាធិការលើវិវាទនោះ ហើយមានភាគីណាមួយប្តឹងមក តុលាការ តុលាការត្រូវសម្រេចលើបណ្តឹងនោះថាវេទិកានោះមានយុត្តាធិការ ឬគ្មាន ហើយ សេចក្តីសម្រេចនោះត្រូវបិទផ្លូវតវ៉ា។

**មាត្រា៣៥** តុលាការ ក្នុងសមត្ថកិច្ចរបស់ខ្លួន តាមវិធានភស្តុតាងរបស់ខ្លួន អាចចាត់ការ តាមសំណើដែលភាគីស្នើឲ្យជួយរកភស្តុតាង។

**មាត្រា៤៤** សាលាឧទ្ធរណ៍ និងតុលាការកំពូលអាចសម្រេចទាត់ចោលសេចក្តីបង្គាប់ របស់វេទិការមជ្ឈត្តការតែក្នុងពីរករណីដូចខាងក្រោមៈ

ករណីទីមួយ ភាគីប្តឹង បានផ្តល់ភស្តុតាង ថាៈ

- មាត្រា៤៤(២)(ក)(១) ភាគីកិច្ចព្រមព្រៀងមានសម្បទាមិនគ្រប់គ្រាន់ ឬកិច្ច ព្រមព្រៀងមិនមានសុពលភាព យោងតាមច្បាប់ដែលភាគីបានជ្រើសរើសឲ្យ គ្រប់គ្រងលើកិច្ចព្រមព្រៀងនោះ ឬបើភាគីមិនបានចែង យោងច្បាប់នៃព្រះ រាជាណាចក្រកម្ពុជា ឬ
- មាត្រា៤៤(២)(ក)(២) ភាគីប្តឹងមិនត្រូវបានជូនដំណឹងត្រឹមត្រូវពីការតែងតាំង មជ្ឈត្តករ ឬពីដំណើរការមជ្ឈត្តកម្ម ឬមិនបានបង្ហាញដោយ ប្រសិទ្ធិភាពនូវ ករណីរបស់គាត់ ឬ

- មាត្រា៤៤(២)(ក)(៣) សេចក្តីបង្គាប់ បានដោះស្រាយវិវាទដែលខទាំងឡាយរបស់កិច្ចព្រមព្រៀងមិនបានគិតដល់ ឬដែលនៅក្រៅវង្វង់ខទាំងនោះ ឬមានបញ្ចូលសេចក្តីសម្រេចលើកម្មវត្ថុ ដែលស្ថិតក្រៅវិសាលភាពកិច្ចព្រមព្រៀង ករណីសេចក្តីសម្រេចខ្លះលើកម្មវត្ថុដែលបានដាក់សម្រាប់មជ្ឈត្តកម្ម និងមិនបានដាក់អាចបំបែកចេញពីគ្នាបាន ត្រូវទាត់ចោលតែផ្នែកដែលមិនដាក់ប៉ុណ្ណោះ ឬ
- មាត្រា៤៤(២)(ក)(៤) សមាសភាពនៃវេទិកាមជ្ឈត្តកម្ម នីតិវិធីមជ្ឈត្តកម្មមិនបានអនុលោមតាមកិច្ចព្រមព្រៀងរបស់ភាគី លើកលែងតែកិច្ចព្រមព្រៀងនោះផ្ទុយពីបញ្ញត្តិណាមួយនៃច្បាប់នេះដែលភាគីមិនអាចបដិសេធបាន ឬ គ្មានកិច្ចព្រៀងដូចនេះទេ មិនបានអនុលោមតាមច្បាប់នេះ ឬករណីទីពីរ សាលាឧទ្ធរណ៍ និងតុលាការកំពូលសម្រេចថា៖
- មាត្រា៤៤(២)(ខ)(១) កម្មវត្ថុនៃវិវាទមិនអាចដោះស្រាយបាន តាមមជ្ឈត្តកម្មយោងច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ
- មាត្រា៤៤(២)(ខ) ការទទួលស្គាល់សេចក្តីបង្គាប់នោះ នឹងផ្ទុយជាមួយគោលនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៤៤ និងមាត្រា៤៤(៤)** ភាគីអាចប្តឹងទាត់ចោលនូវសេចក្តីបង្គាប់របស់វេទិកាមជ្ឈត្តកម្ម ហើយសាលាឧទ្ធរណ៍ និងតុលាការកំពូល នៅពេលទទួលបណ្តឹងនោះ ករណីយល់ថាសមរម្យហើយភាគីមួយបានស្នើផ្អាក ត្រូវផ្អាកការនីតិវិធីទាត់ចោលនេះមួយរយៈតាមការកំណត់របស់សាលាឧទ្ធរណ៍ និងតុលាការកំពូលដើម្បីទុកឱកាសឲ្យវេទិកាមជ្ឈត្តកម្មបន្តនីតិវិធី ឬចាត់វិធានការណ៍ណាដែលវេទិកាមជ្ឈត្តកម្មយល់ថា នឹងលុបចោលនូវមូលដ្ឋានសម្រាប់ទាត់ចោល។

**មាត្រា៤៥** បញ្ញត្តិឲ្យតុលាការមានសមត្ថកិច្ច ទទួលស្គាល់ និងអនុវត្តសេចក្តីបង្គាប់ដោយមិនគិតពីប្រទេសដែលធ្វើសេចក្តីបង្គាប់។

**មាត្រា៤៦** សាលាឧទ្ធរណ៍ ដោយមិនគិតពីប្រទេសដែលធ្វើសេចក្តីបង្គាប់ អាចបដិសេធទទួលស្គាល់ឬអនុវត្តសេចក្តីបង្គាប់នោះ បានតែក្នុងពីរករណីដូចខាងក្រោម៖

- មាត្រា៤៦-១ (ក) ភាគីនៃកិច្ចព្រមព្រៀងយោងមាត្រា៧ មានសម្បាទាមិនគ្រប់គ្រាន់ ឬ កិច្ចព្រមព្រៀងនោះមិនមានសុពលភាព យោងច្បាប់ដែលភាគីបានជ្រើសរើសឲ្យគ្រប់គ្រងលើកិច្ចព្រមព្រៀងនោះ ឬបើភាគីមិនបានបញ្ជាក់ យោងតាមច្បាប់នៃព្រះរាជាណាចក្រកម្ពុជា ឬ

- មាត្រា៤៦-១ (ខ) ភាគីប្ដឹង មិនត្រូវបានជូនដំណឹងត្រឹមត្រូវពីការតែងតាំងមជ្ឈត្តករ ឬពីដំណើរការមជ្ឈត្តកម្ម ឬមិនបានបង្ហាញដោយប្រសិទ្ធិភាពនូវករណីរបស់គាត់ ឬ
- មាត្រា ៤៦-១(គ) សេចក្ដីបង្គាប់ បានដោះស្រាយវិវាទដែលខទាំងឡាយរបស់កិច្ចព្រមព្រៀងមិនបានគិតដល់ឬដែលនៅក្រៅវង្វង់ខទាំងនោះ ឬមានបញ្ចូលសេចក្ដីសម្រេចលើកម្មវត្ថុដែលស្ថិតក្រៅវិសាលភាពកិច្ចព្រមព្រៀង ករណីសេចក្ដីសម្រេចខ្លះលើកម្មវត្ថុដែលបានដាក់សម្រាប់មជ្ឈត្តកម្ម និងមិនបានដាក់ អាចបំបែកចេញពីគ្នាបានត្រូវទាត់ចោលតែផ្នែកដែលមិនដាក់ប៉ុណ្ណោះ ឬ
- មាត្រា ៤៦-១ (ឃ) សមាសភាពនៃវេទិកាមជ្ឈត្តកម្ម ឬនីតិវិធីមជ្ឈត្តកម្ម មិនបានអនុលោមតាមកិច្ចព្រមព្រៀងរបស់ភាគី ឬគ្មានកិច្ចព្រៀងដូចនេះទេ មិនបានអនុលោមតាមច្បាប់នៃដែនដីដែលមជ្ឈត្តកម្មនោះបានប្រព្រឹត្តទៅ ឬ
- មាត្រា ៤៦-១(ង) សេចក្ដីបង្គាប់នោះ មិនទាន់ចូលជាធរមានចងកាតព្វកិច្ចចំពោះភាគីនៅក្នុងប្រទេស ឬតាមច្បាប់នៃប្រទេសដែលសេចក្ដីបង្គាប់បានធ្វើឡើង ឬបានទាត់ចោល ឬផ្អាកដោយតុលាការក្នុងប្រទេសដែលសេចក្ដីបង្គាប់បានធ្វើឡើង ឬ
- ករណីទីពីរ សាលាឧទ្ធរណ៍សម្រេចថា៖
    - មាត្រា ៤៦-២ (ក) កម្មវត្ថុនៃវិវាទ មិនអាចដោះស្រាយបានតាមមជ្ឈត្តកម្មយោងច្បាប់នៃព្រះរាជាណាចក្រកម្ពុជាឬ
    - មាត្រា ៤៦-២ (ខ) ការទទួលស្គាល់សេចក្ដីបង្គាប់នោះ នឹងផ្ទុយជាមួយគោលនយោបាយសាធារណៈនៃព្រះរាជាណាចក្រកម្ពុជា

**មាត្រា៤៦** ករណីមានបណ្ដឹងទាត់ចោល ឬផ្អាកសេចក្ដីបង្គាប់ បានដាក់នៅតុលាការដូចយោងក្នុងកឋាខណ្ឌ៤៦-១ (ង) តុលាការដែលទទួលបណ្ដឹងសុំទទួលស្គាល់ ឬអនុវត្តអាចបើខ្លួនយល់ថាត្រឹមត្រូវផ្អាកសេចក្ដីសម្រេចរបស់ខ្លួន ហើយអាចតាមបណ្ដឹងរបស់ភាគីសុំទទួលស្គាល់សេចក្ដីបង្គាប់ចេញបញ្ជាឲ្យភាគីនោះផ្ដល់នូវកិច្ចធានាសមរម្យ។

## ៣. បញ្ហាទាក់ទងនឹងការចាត់ការរបស់តុលាការ ក្នុងករណីគ្មានបណ្ដឹងសុំឲ្យតុលាការបញ្ជូនវិវាទត្រឡប់ទៅមជ្ឈត្តការ ឬមានកិច្ចព្រមព្រៀងមជ្ឈត្តការ

*ប្រវត្តិបញ្ហា សមត្ថកិច្ចតុលាការ និង ការសម្របសិទ្ធិរបស់ប្រជាពលរដ្ឋមកទទួលយកមជ្ឈត្តការ*

ដោយសារប្រវត្តិមជ្ឈត្តការបានវិវត្តន៍ ពីដំណាក់កាលមិនមានច្បាប់ចែងច្បាស់លាស់ដូចតុលាការមកជាមានច្បាប់បញ្ញត្តិ ហើយមជ្ឈត្តការពាណិជ្ជកម្មក៏នៅក្មេងខ្ចីនៅឡើយនៅ

កម្ពុជា នាំឲ្យសារធារណជនមានទំនោរគិតថា តុលាការច្រើនតែរំលោភ ឬចាត់ការហួសពីតួនាទីរបស់ខ្លួនមកលើមជ្ឈត្តការ ខណៈដែលកិច្ចនោះ តាមពិតត្រឹមត្រូវស្របច្បាប់ បើពិនិត្យមើលច្បាប់ឲ្យបានច្បាស់លាស់។ ជាឧទាហរណ៍ នៅសិក្ខាសាលាអន្តរជាតិ នៅសាកលវិទ្យាល័យគ្រប់គ្រងឆ្នាំ២០១៦ អ្នកចូលរួមម្នាក់បានសួរទៅវាគ្មិនថាតើ ហេតុអ្វីបានជាតុលាការនៅតែបន្តកិច្ចនីតិវិធីទៀតនៅពេលបានឃើញរួចហើយថា មានកិច្ចសន្យារវាងភាគីថានឹងដោះស្រាយវិវាទតាមនៅមជ្ឈត្តការ។[8] ចម្លើយឆ្លើយថា មកពីភាគីមិនមានភាគីណាមួយបានប្តឹងឲ្យតុលាការបញ្ជូនវិវាទទៅដោះស្រាយនៅមជ្ឈត្តការវិញ។ ទោះជាការបកស្រាយត្រឹមត្រូវតាមច្បាប់ តែនៅពេលនោះ អ្នកចូលរួមហាក់ដូចមិនអស់ចិត្តថា តុលាការពិតជាបានយល់ច្បាស់ពីមជ្ឈត្តការ។

ស្រដៀងនឹងអ្នកចូលរួមនោះដែរ ក្រុមហ៊ុនអន្តរជាតិវិស័យច្បាប់ដ៏ធំមួយ ឈ្មោះ ន័រតុនរ៉ូស ហ្វុលប្រៃថ៍ (Norton Rose Fulbright) នៅឆ្នាំ២០១៣ បានចុះផ្សាយនាំអត្ថបទ ថា ពេលនោះមិនអាចនិយាយបានទេថា សញ្ញាណមជ្ឈត្តិការតាមរបៀបឯកជន មានការគាំទ្រយ៉ាងទូលំទូលាយពីប្រព័ន្ធតុលាការនៅកម្ពុជានោះទេ។ អ្នកនិពន្ធអត្ថបទនោះ យល់ថា “មួយថ្ងៃក្រោយពីបានរៀបចំពិធីសម្ពោធជាផ្លូវការនៃ មជ្ឈមណ្ឌលមជ្ឈត្តការជាតិនៃកម្ពុជាមានតុលាការខេត្តមួយ បានបដិសេធសំណើភាគីស្នើសុំផ្អាកនីតិវិធីតុលាការដើម្បីគាំទ្រដំណើរការមជ្ឈត្តការ ទោះបីជាមានកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការហើយចងកាតព្វកិច្ចក៏ដោយ”។ ទោះជា កាលនោះការយល់ដឹងនៅមានភាពចម្រូងចម្រាស អំពីសមត្ថកិច្ចរបស់តុលាការពាក់ព័ន្ធនឹងវិវាទដែលបាន ខ មជ្ឈត្តការ ក៏ដោយ ក៏មិនប្រាកដជាបង្ហាញថា តុលាការបានចាត់ការស្របច្បាប់នោះ ដែរ។[9] មកដល់បច្ចុប្បន្ន ឆ្នាំ២០១៨ មាននិស្សិត និងមជ្ឈត្តករ បានទទួលការសិក្សាច្រើនជាងមុនឆ្ងាយ ហើយចំនួនសំណុំរឿងមជ្ឈត្តការក៏កើនដល់ចំនួន១០ហើយ។ ចំពោះការលើកឡើងរបស់អ្នកនិពន្ធអត្ថបទខាងលើថា តុលា-ការបានបដិសេធសំណើភាគីស្នើសុំបញ្ជូនវិវាទទៅមជ្ឈត្តការនោះ តាមពិតក៏មានបញ្ញត្តិ និងយុត្តិសាស្ត្រគាំទ្រកិច្ចនោះដែរ។ អាស្រ័យហេតុនេះ បញ្ហាគឺត្រូវឆ្លើយនឹងសំណួរដូចខាងក្រោមៈ

---

[8] ខ្ញុំបានចូលរួមផ្ទាល់ ក្នុងសិក្ខាសាលានេះ នៅភ្នំពេញ។ *សិក្ខាសាលាលើកទី៤សម្រាប់និស្សិតកម្ពុជា កូរ៉េ និង អាមេរិក ស្តីអំពីច្បាប់និងការអភិវឌ្ឍន៍* នៅថ្ងៃទី៤ដល់៥ ខែមករាឆ្នាំ២០១៦ រៀបចំដោយ សាកលវិទ្យាល័យជាតិគ្រប់គ្រងនិង សាលាច្បាប់អន្តរជាតិនៃ សាកលវិទ្យាល័យ ហានដុង ។

[9] ពីព្រោះក្នុងឆ្នាំ២០១៥ ខ្ញុំបានសួរសាស្ត្រាចារច្បាប់ម្នាក់អំពីទំនាក់ទំនងរវាងតួនាទីមជ្ឈត្តករខាងវិស័យការងារ (អាជ្ញាកណ្តាល) និងតុលាការហើយគាត់បានលើកឡើងនូវបញ្ញត្តិមួយថា មានតែតុលាការទេ ទើបអាចជម្រះក្តីយោងតាមរដ្ឋធម្មនុញ្ញ ព្រមទាំងបានសម្គាល់ថា មជ្ឈត្តករមិនជំនាញផ្នែកភស្តុតាងឧទាហរណ៍ផ្នែកកុសលវិច័យជាដើម។ អ្នកចូលរួមម្នាក់ បានសំអាងលើបញ្ញត្តិដូចគ្នានេះដែរ នៅក្នុងការជជែកពិភាក្សាគ្នាយ៉ាងច្រើនលើប្រធានបទនេះ នៅឯសិក្ខាសាលាថ្នាក់ជាតិស្តីអំពីទំនាក់ទំនងវិជ្ជាជីវៈ កាលពីថ្ងៃទី២៧-២៨ខែកុម្ភៈឆ្នាំ២០១៧ ពាក់ព័ន្ធនឹងកម្មវត្ថុ លក្ខខណ្ឌ និងនីតិវិធី ដែលភាគីវិវាទអាចឧទ្ធរណ៍ទៅតុលាការ ។

*បញ្ហា:*

*តើការដែលតុលាការចាត់ការដោះស្រាយវិវាទ ដោយខ្លួនផ្ទាល់មិនបញ្ជូនទៅមជ្ឈត្តការ (ជាកិច្ចត្រឹមត្រូវ ស្របច្បាប់ទេ) ក្នុងករណីនៅសិក្ខាសាលាដែលមានករណីអង្គហេតុទាំងពីរខាងលើ៖*

1. តុលាការទទួលបណ្តឹងភាគីម្ខាងឲ្យចាត់ការវិវាទតាមផ្លូវតុលាការ
2. ភាគីម្ខាងទៀត មិនបានដាក់ចំពោះមុខតុលាការនូវបណ្តឹងសុំបញ្ជូនវិវាទទៅដោះស្រាយនៅមជ្ឈត្តការវិញ

*ក្នុងករណីអត្ថបទណ័រតុនរ៉ូស ដែលមានករណីអង្គហេតុទាំងពីរបានលើ៖*

1. តុលាការទទួលបណ្តឹងភាគីម្ខាងឲ្យចាត់ការវិវាទតាមផ្លូវតុលាការ
2. មានកិច្ចព្រមព្រៀងធ្វើមជ្ឈត្តការ

តុលាការបានចាត់ការស្របច្បាប់ករណីនៅសិក្ខាសាលា ដោយសារភាគីមិនបានប្តឹងយោងមាត្រា៨(១) នៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦ ដែលតម្រូវជាចាំបាច់ឲ្យភាគីប្តឹងតាមពេលកំណត់ ហើយបញ្ញត្តិដាច់ខាតនៃមាត្រានេះមិនផ្តល់ឆន្ទានុសិទ្ធិឲ្យតុលាការអាចបញ្ជូនមកមជ្ឈត្តការដោយខ្លួនឯងទៀត។ ករណីអត្ថបទណ័រតុនរ៉ូស តុលាការក៏បានចាត់ការស្របច្បាប់ដែរ បើតុលាការសម្រេចថា កម្មវត្ថុដែលប្តឹងមកតុលាការស្ថិតក្រៅវិសាលភាពកិច្ចព្រមព្រៀង ឬថាកិច្ចព្រមព្រៀងត្រូវចាត់ទុកជាមោឃៈ មិនអាចប្រតិបត្តិ ឬមិនមានលទ្ធភាព ក្នុងការអនុវត្តទៅបាន។[10]

## *ច្បាប់ដែលយកមកអនុវត្ត*

ដោយសារគោលដៅនៃមជ្ឈត្តការ ដូចជា ភាពរំពឹងទុកជាមុនបាន និង លទ្ធផលចុងក្រោយជៀសវាងការតវ៉ា យើងឃើញមានយុត្តិសាស្ត្រជាទូទៅ បានបកស្រាយមាត្រាពាក់ព័ន្ធយុត្តាធិការតុលាការន័យចង្អៀត តែមិនមែនមានន័យថា គ្មានសោះនោះទេ។ ខាងក្រោមនេះខ្ញុំនឹងលើកឡើងតែយុត្តិសាស្ត្រមួយចំនួនទាក់ទងលក្ខខណ្ឌខាងលើ ដែលតុលាការមិនបញ្ជូនវិវាទទៅមជ្ឈត្តការ។

ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៦ របស់ព្រះរាជាណាចក្រកម្ពុជាទទួលឥទ្ធិពលស្ទើរទាំងស្រុងពី ច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិឆ្នាំ១៩៨៦ ជាពិសេសគឺមាត្រា៨

[10] ចំពោះទំនាក់ទំនងលក្ខខណ្ឌទី៣និងទី៤ត្រូវមានទន្ទឹមគ្នា សូមអាន UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៤៣ កឋាខណ្ឌ២៨

(១) ដែលយកមកអនុវត្តក្នុងអត្ថបទនេះដូចគ្នាបេះបិត។ ការអនុវត្តមាត្រានេះ គឺស្ថិតក្នុងវិសាលភាពនៃបណ្តាច្បាប់ពាក់ព័ន្ធដែលមានសុពលភាពនៅកម្ពុជាមាន មាត្រា៦ និង៧នៃច្បាប់ស្តីពីការអនុម័ត និងអនុសញ្ញាអង្គការសហប្រជាជាតិស្តីពីការទទួលស្គាល់ និងអនុវត្តសេចក្តីបង្គាប់មជ្ឈត្តការអន្តរជាតិឆ្នាំ២០០១ ក៏មានសុពលភាព នៅព្រះរាជាណាចក្រកម្ពុជា មាត្រា៣៥៣នៃក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ២០០៦ អនុក្រឹត្យស្តីការការការរៀបចំនិងប្រព្រឹត្តទៅរបស់មជ្ឈមណ្ឌលជាតិនៃមជ្ឈត្តការផ្នែកពាណិជ្ជកម្មឆ្នាំ២០០៩។ អាស្រ័យហេតុនេះ បញ្ញត្តិ និងយុត្តិសាស្រ្តដែលមានលក្ខណៈ និងសុពលភាពដូចគ្នានៅបណ្តាប្រទេសផ្សេងៗ បានលើកយកពិភាក្សាទីនេះផងដែរ។[11]

*ច្បាប់ស្តីពីមជ្ឈត្តការផ្នែកពាណិជ្ជកម្ម ឆ្នាំ២០០៦*

**មាត្រា ៨** កិច្ចព្រមព្រៀងមជ្ឈត្តការ និងបណ្តឹងទាក់ទងកម្មវត្ថុចំពោះមុខតុលាការមាត្រា ៨(១) តុលាការចំពោះមុខខ្លួន មានបណ្តឹងអំពីបញ្ហាដែលជាកម្មវត្ថុកិច្ចព្រៀមព្រៀងមជ្ឈត្តការករណីមានភាគីមួយបានប្តឹងសុំបញ្ជូនមិនយឺតជាងពេលគាត់ដាក់សេចក្តីសន្និដ្ឋានកម្មវត្ថុនៃវិវាទ បញ្ជូនបណ្តាភាគីទៅមជ្ឈត្តការ លើកលែងតែតុលាការសម្រេចថា កិច្ចព្រមព្រៀងនោះចាត់ទុកជាមោឃៈ មិនអាចប្រតិបត្តិ ឬមិនមានលទ្ធភាព ក្នុងការអនុវត្តទៅបាន។

*ការវិភាគបញ្ហា*

តាមការអានអក្សរសាស្រ្តអត្ថបទ មាត្រា៨(១)មានន័យថា តុលាការ ត្រូវបញ្ជូនភាគីទៅខាងមជ្ឈត្តកម្ម ក្នុងលក្ខខណ្ឌទាំងបួនបានកើតឡើង ហើយមិនត្រូវបញ្ជូនទេ បើខ្វះលក្ខខណ្ឌណាមួយ។

ភាគីម្ខាងបានប្តឹងមកតុលាការ

1. ភាគីម្ខាងបានប្តឹងសុំបញ្ជូនទៅមជ្ឈត្តការ មិនយឺតយ៉ាវជាងពេលដាក់សេចក្តីសន្និដ្ឋានពីកម្មវត្ថុនៃវិវាទ
2. កម្មវត្ថុដែលប្តឹងតុលាការ ជាកម្មវត្ថុស្ថិតក្រោមកិច្ចព្រមព្រៀងមជ្ឈត្តកម្ម និង

[11] "Introductory Guide: Commericial Arbitration in Cambodia," *Bun & Associates Publication Series,* Phnom Penh: Bun & Associates, 2014, pp.1-11; Alex Larkin & Ly Sambo, "Recent Developments in Commercial Arbitration in Cambodia," *Asian Dispute Review,* Hong Kong: HKIAC, January 2015, pp. 12-15; Darwin Hem & Bo Chankoulika, "Commericial Arbitration in Cambodia," *BNG Legal Newsletter,* Phnom Penh: BNG Legal, February 2017, pp.1-3

3. តុលាការសម្រេចចាត់ទុកកិច្ចព្រៀមព្រៀងថា មិនមានមោឃភាព អាចប្រតិបត្តិ ឬមានលទ្ធភាពក្នុងការអនុវត្តទៅបាន[12]

អ្នកច្បាប់ជាទូទៅ បានចាត់ទុកមាត្រា៨-១ ជាវិធានដាច់ខាត បានន័យថា តុលាការដាច់ខាត ឬគ្មានឆន្ទានុសិទ្ធិទេ ត្រូវតែបញ្ជូនវិវាទទៅមជ្ឈត្តការ បើលក្ខណខណ្ឌ *ទាំងបួន* បានបំពេញ។ យុត្តិសាស្ត្របានចង្អុលថា បើខ្វះលក្ខខណ្ឌណាមួយតុលាការគ្មានកាតព្វកិច្ចបញ្ជូនវិវាទទៅមជ្ឈត្តការ។

*អំពីអង្គហេតុនៅសិក្ខាសាលា*

យើងឃើញថា អង្គហេតុដែលបានលើកឡើងនៅសិក្ខាសាលានោះ មិនបានបំពេញលក្ខខណ្ឌទី២ទេ ពោលគឺ តាម៨(១) ករណី មាន ខ ព្រមព្រៀងធ្វើមជ្ឈត្តការរួចហើយក៏ដោយ ក៏ភាគីណាមួយ ត្រូវប្តឹងចំពោះមុខតុលាការសុំបញ្ជូនវិវាទទៅមជ្ឈត្តការតែមិនបានភាគីណាបានប្តឹងនោះទេ។

យោងតាមការអត្ថាធិប្បាយយុត្តិសាស្ត្រមាត្រា៨ របស់គណៈកម្មាធិការច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ តុលាការមិនអាចចេញដីកាបញ្ជូនវិវាទទៅមជ្ឈត្តការបានទេ បើតុលាការមិនបានទទួលបណ្តឹងសុំបញ្ជូន។[13] តាមខ្លឹមសារឯកសារ *ការងាររៀបចំ* មាត្រា៨ និងការអធិប្បាយរបស់គណៈកម្មាធិការ លក្ខខណ្ឌដាច់ខាតនៃមាត្រានេះ តម្រូវឲ្យតុលាការត្រូវតែ ពោលគឺគ្មានឆន្ទានុសិទ្ធិទេ ត្រូវតែបញ្ជូនទៅមជ្ឈត្តការ បើបានបំពេញគ្រប់លក្ខខណ្ឌ ផ្ទុយមកវិញ ក៏គ្មានឆន្ទានុសិទ្ធិបញ្ជូនបណ្តឹងមកមជ្ឈត្តការវិញដែរ មិនមានបណ្តឹងសុំបញ្ជូន។[14]

តុលាការជាន់ខ្ពស់ផ្នែកពាណិជ្ជកម្មនៃប្រទេសក្រូអាត នៅថ្ងៃទី២៩ខែមេសាឆ្នាំ២០០១ បានសម្រេចក្នុងសំណុំរឿងលេខ Pz-5168/01 ថា បណ្តាភាគីក្នុងវិវាទចំពោះមុខតុលាការ អាចនឹងលះបង់នូវកិច្ចព្រមព្រៀងមជ្ឈត្តការផងដែរ តាមរយៈទង្វើរបស់ពួកគេ ពោលគឺទីមួយ

---

[12] ចំពោះទំនាក់ទំនងលក្ខខណ្ឌទី៣និងទី៤ត្រូវមានទន្ទឹមគ្នា សូមអាន UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៤៣ កឋាខណ្ឌ២៨

[13] UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៣៤កឋាខណ្ឌលេខ៤

[14] ឯកសារលេខ A/CN.9/264 សេចក្តីអត្ថាធិប្បាយវិភាគលើអត្ថបទព្រាងនៃច្បាប់គម្រូមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ មាត្រា៨ កឋាខណ្ឌ៣ មាននៅគេហទំព័រ http://www.uncitral.org/uncitral/en/commission/sessions/18th.html ។ NCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៣៧កឋាខណ្ឌ៧និង៨

ដើមបណ្ដឹងបានដាក់សេចក្ដីសន្និដ្ឋានទាមទារមកតុលាការ (មិនបានប្ដឹងពីមជ្ឈត្តការ) ហើយទីពីរ ចុងចម្លើយបានចូលក្នុងដំណាក់កាលតវ៉ាពីកម្មវត្ថុនៃវិវាទ មិនបានបដិសេធយុត្តាធិការពីដំបូងលុះដល់ពេលឧទ្ធរណ៍ទើបលើកពីបញ្ហាមជ្ឈត្តការ។ ក្នុងករណីនេះ តុលាការបន្តថា តុលាការអាចទទួលការតវ៉ាពីមជ្ឈត្តការ បានលុះត្រាតែចុងចម្លើយបានលើកឡើងបញ្ហានេះយ៉ាងយូរបំផុតត្រឹមនីតិវិធីត្រៀម ឬក្នុងសវនាការ មុនចូលដល់ការតវ៉ាអំពីកម្មវត្ថុនៃវិវាទ។ តុលាការដដែលបានចេញសេចក្ដីសម្រេចដូចគ្នាឈរលើមូលហេតុដូចគ្នា យ៉ាងហោចណាស់ក្នុងសំណុំរឿងពីរទៀត ឆ្នាំ២០០៤និង២០០៧។[15]

តុលាការហុងកុងតំបន់រដ្ឋបាលពិសេសរបស់ប្រទេសចិននៅថ្ងៃទី៣ខែមករាឆ្នាំ២០០៤ បានសម្រេចលក្ខណៈដូចខាងលើដែរ ក្នុងសំណុំរឿង Kolinker Industrial Equipment Ltd. ទល់នឹង Longhill Industries Ltd. & another។ តុលាការនេះ បានអនុលោមតាមច្បាប់មជ្ឈត្តការរបស់ខ្លួនដែលបញ្ញត្តិដូចមាត្រា៨ នៃច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិរបស់គណៈកម្មាធិការច្បាប់ពាណិជ្ជកម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ ហើយដោយភាគីខកខានមិនបានប្ដឹងសុំបញ្ជូនទៅមជ្ឈត្តការ មិនមានអ្វីហាមមិនឲ្យតុលាការបន្តកិច្ចចេញសាលក្រមនោះទេ។[16]

សាលាឧទ្ធរណ៍ប្រិចីសកូឡុមបៀ នៃប្រទេសកាណាដា នៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៩៨ ក្នុងសំណុំរឿង Nutrasweet Kelco Co. ទល់នឹង Royal-Sweet International Technologies Ltd. Partnership បានបដិសេធចុងចម្លើយដែលសុំបញ្ជូនវិវាទទៅមជ្ឈត្តការ ដោយសារទោះជាមានកិច្ចព្រមព្រៀងមជ្ឈត្តការ ចុងចម្លើយបានដាក់សេចក្ដីសន្និដ្ឋានមុនការសុំបញ្ជូនរួចទៅហើយ ដូចនេះ យោងមាត្រា៨ នៃច្បាប់ស្ដីពីមជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ភាគីនេះបានបាត់បង់សិទ្ធិក្នុងការយោងទៅលើ ខ នៃមជ្ឈត្តការទៀតហើយ។[17]

---

[15]CLOUT Case 657 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/hrv/clout_case_657_leg-1904.html

CLOUT Case 1071 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/hrv/clout_case_1071_leg-2609.html

[16]សាលក្រមថ្ងៃទី៣ខែមិថុនាឆ្នាំ២០០៤ សំណុំរឿងលេខ DCCJ005052/2002 ភាគី Kolinker Industrial Equipment Ltd. ទល់នឹង Longhill Industries Ltd. & another នៅគេហទំព័រ https://www.hongkongcaselaw.com/kolinker-industrial-equipment-ltd-v-longhill-industries-ltd-another/

[17] CLOUT Case 352 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_355_leg-1579.html

តុលាការជាន់ខ្ពស់ អនថារីយ៉ូ នៃប្រទេសកាណាដា នៅថ្ងៃទី៨ ខែតុលា ឆ្នាំ២០០២ បានសម្រេចដូចគ្នាដែរនៅក្នុងសំណុំរឿង United Laboratories, Inc. ទល់នឹង Abraham។ ចុងចម្លើយតវ៉ាមិនឲ្យតុលាការនេះបំពេញកិច្ចរបស់ខ្លួនទេ ដោយហេតុថា មានកិច្ចព្រមព្រៀងមជ្ឈត្តការរវាងភាគី។ ភាគីបានតទល់គ្នានៅចំពោះមុខតុលាការរដ្ឋអ៊ីលីណយ តែមិនបានលើកឡើងពីកិច្ចព្រមព្រៀងនេះទេ ហើយចុងចម្លើយនេះ អវត្តមានចំពោះមុខតុលាការអ៊ីលីណយទៀតផង រហូតដល់មានសាលក្រមកំបាំងមុខ។ តុលាការអនថារីយ៉ូសម្រេចថា មាត្រា៨ នៃច្បាប់មជ្ឈត្ត-ការពាណិជ្ជកម្មអន្តរជាតិដែលមានសុពលភាពនៅអនថារីយ៉ូ មិនបានផ្តល់កាតព្វកិច្ច ឬអំណាចឲ្យតុលាការ បញ្ជូនភាគីទៅមជ្ឈត្តការទេ ករណីភាគីណាមួយមិនបានស្នើទេនោះ។[18]

ហេតុផលខាងលើនេះ បង្ហាញថាលក្ខខណ្ឌទី២ មិនបានបំពេញទេ ដោយសារភាគីខកខានតវ៉ា ឬតវ៉ាមិនទាន់ពេលវេលា។ មានន័យថា ដូចករណីនៅសិក្ខសាលា តុលាការមិនបានរំលោភលើនីតិវិធី ឬបញ្ញត្តិច្បាប់ទេ ពីព្រោះច្បាប់អនុញ្ញាតឲ្យតុលាការបន្តកិច្ចខ្លួន កាលណាមានលក្ខខណ្ឌណាមួយមិនបានបំពេញ។

*អំពីអង្គហេតុក្នុងអត្ថបទណ័រតុនរ៉ូស ហ្វុលប្រៃថ៍*

ម្យ៉ាងវិញទៀត អត្ថបទ ន័រតុន រ៉ូស ហ្វុប្រៃយ៍ មិនបានបញ្ជាក់ថាមានអង្គហេតុភាគីបានប្តឹង ឬអត់ទេ តែទោះជាភាគីបានប្តឹងបំពេញលក្ខខណ្ឌទី២ ហើយមានកិច្ចព្រមព្រៀងដូចក្នុងអង្គហេតុទី៣ក៏ដោយ តែបើតុលាការសម្រេចថាកិច្ចព្រមព្រៀងនោះមិនបានបំពេញលក្ខខណ្ឌទី៣ ឬទី៤ខាងលើនេះ តុលាការក៏នៅតែមិនបានរំលោភច្បាប់ទេ ក្នុងការបន្តចាត់ការដោះស្រាយវិវាទដោយមិនបញ្ជូនទៅមជ្ឈត្តការនោះ។ លក្ខខណ្ឌនេះ បានបកស្រាយ និងយោងយុត្តិសាស្ត្រយ៉ាងច្រើន នៅក្នុងការអត្ថាធិប្បាយយុត្តិសាស្ត្រមាត្រា ៨ របស់គណៈកម្មាធិការច្បាប់ពាណិជ្ជ-កម្មអន្តរជាតិនៃអង្គការសហប្រជាជាតិ និងប្រភពផ្សេងៗ។[19]

<u>លក្ខខណ្ឌទី៣មិនបានបំពេញ៖ កម្មវត្ថុប្តឹងមកតុលាការស្ថិតនៅក្រៅវិសាលភាពកិច្ចព្រមព្រៀងមជ្ឈត្តការ</u>[20]

---

[18] CLOUT Case 1071 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_508_leg-.1733html

[19] UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration ទំព័រ៣៧ដល់៤៣។ Margaret L. Moses, "The Principles and Practices of International Commercial Arbitration," New York: Cambridge University Press, 2012, pp. 205-229

[20] សូមអានសំណុំរឿងទាំងឡាយដែលបានយោងនៅជើងទំព័រលេខ១៩៧ ទំព័រ៤៣ កឋាខណ្ឌ២៨ UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration

តុលាការយុត្តិធម៌អនថារីយ៉ូ ប្រទេសកាណាដា កាលពីថ្ងៃទី១០ ខែវិច្ឆិកាឆ្នាំ១៩៩៤ ក្នុងសំណុំរឿង T1T2 Limited Partnership ទល់នឹង Canada បានបដិសេធមិនបញ្ជូនទៅមជ្ឈត្តការ ក្នុងករណីទោះជាចុងចម្លើយបានប្តឹងបញ្ជូន ហើយមានវត្តមាន ខ មជ្ឈត្តការ តែដោយសារបញ្ហាដែលដើមបណ្តឹងទាមទារឲ្យដោះស្រាយ "ពាក់ព័ន្ធនឹងបញ្ហាច្បាប់" ដែលកិច្ចព្រមព្រៀងនោះបានចែងលើកលែង។[21]

សាលាឧទ្ធរណ៍ប្រីធីសកូឡុមបៀ នៃប្រទេសកាណាដា នៅថ្ងៃទី១៨ខែតុលាឆ្នាំ១៩៩៥ ក្នុងសំណុំរឿង Traff ទល់នឹង Evancic et al បានសម្រេចមិនបញ្ជូនវិវាទលើកម្មវត្ថុ ការលួចបន្លំទៅមជ្ឈត្តការទេ ក្នុងការណីមានកិច្ចព្រមព្រៀងមជ្ឈត្តការមានចុងចម្លើយបានប្តឹងសុំបញ្ជូនពីរកម្មវត្ថុគឺ ការលួចបន្លំ និងគណនេយ្យដែលចុងម្លើយយល់ថា សុទ្ធតែជាកម្មវត្ថុនៃកិច្ចព្រមព្រៀងនោះ។ តុលាការមិនយល់ស្របជាមួយចុងចម្លើយលើ ការលួចបន្លំ ដោយឈរលើមូលដ្ឋានថា មាត្រា៨(១) នៃច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិ ការលួចបន្លំមិនមែនជាកម្មវត្ថុនៃមជ្ឈត្តការទេ ដោយសារធាតុរបស់វាមិនអាចចុះកិច្ចសន្យាស្របច្បាប់បាននោះទេ ហើយសម្រេចថា ការទាមទារក្នុងបណ្តឹងនោះមិនស្ថិតក្នុងក្របខណ្ឌសុពលភាពនៃកិច្ចសន្យានោះ ឡើយ។[22]

សាលាឧទ្ធរណ៍អនថារីយ៉ូ ប្រទេសកាណាដា នៅថ្ងៃទី២៣ខែធ្នូឆ្នាំ២០០៨ ក្នុងសំណុំរឿង Patel ទល់នឹង Kanbay International Inc. បានសម្រេចថា ការទាមទាររបស់ដើមបណ្តឹងពាក់ព័ន្ធនឹងការបញ្ឈប់ពីតួនាទី មិនមានលក្ខណៈជាបញ្ហាពាណិជ្ជកម្មសមរម្យនឹងអនុវត្តច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិនោះទេ។ ដូចមុនៗ សាលាឧទ្ធរណ៍បានទទួលស្គាល់ថាបញ្ហាយុត្តាធិការជាធម្មតាគួរតែបញ្ជូនទៅខាងមជ្ឈត្តការជាមុន ទោះជាយ៉ាងណា បានសម្រេចថា ករណីវិវាទ បានបង្ហាញច្បាស់ក្រឡែតថាមិននៅក្នុងក្របខណ្ឌកិច្ចព្រមព្រៀងមជ្ឈត្តការជាក់លាក់នោះទេ សាលាឧទ្ធរណ៍គួរតែសម្រេចភ្លាមៗទៅតាមហ្នឹងដែរ។[23]

តុលាការកំពូល ប្រីចីសកូឡុមបៀ នៃប្រទេសកាណាដា កាលពីថ្ងៃទី២៨ ខែវិច្ឆិកា ឆ្នាំ១៩៩៨ ក្នុងសំណុំរឿង ODC Exhibit Systems Ltd. ទល់នឹង Lee, Expand International et al.

---

[21] CLOUT Case 355 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_355_leg-1579.html

[22] CLOUT Case 350 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_355_leg-1579.html

[23] CLOUT Case 1048 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_1048_leg-.2766html

បានសម្រេចមិនបញ្ជូនវិវាទទៅមជ្ឈត្តការ ដោយសារអំពើអនីត្យានុគោលមិនអាចជាកម្មវត្ថុនៃកិច្ចសន្យាមជ្ឈត្តកម្មបានទេ ដែលជាលក្ខខណ្ឌត្រូវបំពេញមុននឹងបញ្ជូនទៅបាន។[24]

<u>លក្ខខណ្ឌទី៤មិនបានបំពេញ៖ តុលាការសម្រេចចាត់ទុកកិច្ចព្រៀមព្រៀងជាមោឃៈ មិនអាចប្រតិបត្តិ ឬមិនមានលទ្ធភាព ក្នុងការអនុវត្តទៅបាន</u>[25]

តុលាការឧទ្ធរណ៍ចុងក្រោយ នៃតំបន់រដ្ឋបាលពិសេសហុងកុង ប្រទេសចិន កាលពីថ្ងៃទី២៨ ខែមេសាឆ្នាំ២០០៨ នៅក្នុងសំណុំរឿង Paquito Lima Buton ទល់នឹង Rainbow Joy Shipping Ltd. Inc. ត្រូវសម្រេចថា តើទាមទាររបស់ដើមបណ្តឹងត្រូវចាត់ការនៅតុលាការស្រុករបស់ហុងកុង ឬបញ្ជូនទៅមជ្ឈត្តការ យោងមាត្រា៨របស់ច្បាប់មជ្ឈត្តការពាណិជ្ជកម្មអន្តរជាតិរបស់អង្គការសហប្រជាជាតិ ក្រោយពីតុលាការស្រុកបានសម្រេចរួចហើយថា មានខមជ្ឈត្តការក្នុងកិច្ចសន្យាការងារ។ តុលាការឧទ្ធរណ៍ចុងក្រោយនេះ បានសម្រេចថា បញ្ញត្តិដាច់ខាតរបស់មាត្រា៨(១) មិនអាចប្រតិបត្តិទៅបានទេ កាលណាមានច្បាប់ផ្សេងដកសុពលភាពវា ចំពោះបញ្ហាវិវាទ ហើយថា ច្បាប់ស្តីពីសំណងកម្មករនិយោជិតត្រង់ផ្នែក១៨(១) បានប្រគល់សមត្ថកិច្ចផ្តាច់មុខទៅឲ្យតុលាការស្រុករបស់ហុងកុង ពាក់ព័ន្ធនឹងបញ្ហាសំណងកម្មករនិយោជិតទាំងអស់ លើកលែងតែមានករណីចែងច្បាស់លាស់ថាបានលើកលែង។[26]

តុលាការកំពូល ប្រ៊ីធីសកូឡុមបៀ នៃប្រទេសកាណាដា នៅថ្ងៃទី៩ខែតុលាឆ្នាំ២០០៩ ក្នុងសំណុំរឿង H & H Marine Engine Service Ltd. v. Volvo Penta of the Americas Inc. បានសម្រេចមិនបញ្ជូនវិវាទទៅមជ្ឈត្តការ ដោយសារភាគីមិនបានចុះកិច្ចសន្យាមជ្ឈត្តការពិតប្រាកដ ផ្អែកលើការបង្ហាញជាដំបូងពីភស្តុតាងឯកសារដែលបានដាក់។ នៅចំពោះមុខតុលាការកំពូលនេះ ដើមបណ្តឹងបដិសេធការបញ្ជូនទៅមជ្ឈត្តការ ចំណែកឯចុងចម្លើយសុំបញ្ជូនទៅ។ ចុងចម្លើយតវ៉ាថា បញ្ហាអត្ថិភាពរបស់កិច្ចសន្យាមជ្ឈត្តការជាអាទិភាពរបស់វេទិការមជ្ឈត្តកម្ម ប៉ុន្តែតុលាការកំពូលប្រ៊ីធីសកូឡុមបៀ បានលើកយុត្តិសាស្ត្រនៃតុលាការកំពូលកាណាដា ថាគោលការណ៍យុត្តាធិការស្វយ័តនោះ គឺវេទិកាមជ្ឈត្តកម្មមានអាទិភាពសម្រេចលើការជំទាស់

[24] CLOUT Case 65 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_65_leg-1166.html

[25] សូមអានសំណុំរឿងទាំងឡាយដែលបានយោងនៅជើងទំព័រលេខ១៥៩ដល់១៩៦ ពីទំព័រ៣៨ដល់៤៨ ទំព័រ៤៣ UNCITRAL 2012 Digest of Case Law on the Model Law on International Commercial Arbitration

[26] CLOUT Case 1073 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/hkg/clout_case_1073_leg-2735.html

យុត្តាធិការរបស់ខ្លួនជាមុនមែន ប៉ុន្តែមិនមែនក្នុងករណីដែលការជំទាស់ពាក់ព័ន្ធនឹងបញ្ហាច្បាប់ ឬបញ្ហាច្បាប់លាយឡំ បញ្ហាអង្គហេតុដែលត្រូវការ*ត្រឹមតែ*ការពិចារណាលើភស្តុតាងបន្តិចបន្តួចប៉ុណ្ណោះនោះទេ។[27]

សាលាឧទ្ធរណ៍អនថារីយ៉ូ ប្រទេសកាណាដា នៅថ្ងៃទី២៩ខែមេសាឆ្នាំ២០០៩ ក្នុងសំណុំរឿង Jean Estate ទល់នឹង Wires Jolley LLP បានទទួលស្គាល់ថា ជាធម្មតាវេទិកាមជ្ឈត្តកម្មត្រូវចាត់ការជាមុនចំពោះបណ្តឹងជំទាស់នឹងយុត្តាធិការរបស់ខ្លួន តែមានករណីលើកលែងតុលាការអាចចាត់ការភ្លាមៗនៅពេលដែលបណ្តឹងជំទាស់នោះពាក់ព័ន្ធ*តែនឹង*បញ្ហាច្បាប់ យោងតាមយុត្តិសាស្ត្រតុលាការកំពូលកាណាដា។ ឈរលើមូលហេតុនៃការសម្រេចផ្នែកច្បាប់នេះ សាលាឧទ្ធរណ៍នេះ បានសម្រេចថា វេទិកាមជ្ឈត្តការអាចដោះស្រាយចំពោះវិវាទនៃកិច្ចព្រមព្រៀងបង់ថ្លៃសេវាយថាហេតុបាន ប៉ុន្តែកាលណាមានបណ្តឹងមកតុលាការ តុលាការមានសមត្ថកិច្ចផ្តាច់មុខ យោងច្បាប់ជាធរមាន ត្រូវកំណត់ថា តើថ្លៃសេវានោះ សមរម្យ ឬយ៉ាងណា ហើយកិច្ចព្រមព្រៀងនោះត្រូវចាត់ទុកជាមោឃៈ ដោយសារភាគីមិនអាចចុះកិច្ចសន្យាគេចពីការពារ ឬអានុភាពរបស់ច្បាប់បានឡើយ។[28]

ដោយហេតុផលខាងលើនេះ ករណីមានកិច្ចព្រមព្រៀងមជ្ឈត្តការក៏ដោយ តុលាការនៅចាត់ការកិច្ចរបស់ខ្លួន ដោយស្របច្បាប់ កាលណាលក្ខខណ្ឌណាមួយមិនបានបំពេញ ដូចជាភាគីមិនបានប្តឹងបញ្ជូនទៅមជ្ឈត្តការ(លក្ខខណ្ឌទី២) ឬកម្មវត្ថុប្តឹងមកតុលាការមិនស្ថិតក្នុងវិសាលភាពកិច្ចព្រមព្រៀងមជ្ឈត្តការ (លក្ខខណ្ឌទី៣) ឬកិច្ចព្រមព្រៀងដែលភាគីអះអាងនោះត្រូវបានចាត់ទុកជាមោឃៈ ឬមិនអាចប្រតិបត្តិបាន ឬមិនមានលទ្ធភាព ក្នុងអនុវត្តទៅបាន (លក្ខខណ្ឌទី៤)។

## ៤. សេចក្តីសន្និដ្ឋាន

ជាសរុប សំអាងហេតុរៀបរាប់ខាងលើ បញ្ជាក់ថា តុលាការមិនប្រាកដថា បានប្រព្រឹត្តខុសគោលការណ៍ ឬច្បាប់ទេ បើគ្រាន់តែយោងលើអង្គហេតុដូចនៅក្នុងសិក្ខាសាលានិងនៅក្នុង

[27] CLOUT Case 1011 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_1011_leg-2763.html

[28] CLOUT Case 1044 នៅគេហទំព័រ http://www.uncitral.org/clout/clout/data/can/clout_case_1048_leg-.2766html សេចក្តីសម្រេច និងសាលដីកាទាំងស្រុងត្រង់ឋាខណ្ឌ៧និង២២

អត្ថបទន័រតុនរ៉ូសហ្វុលប្រែថ៍ ពោលគឺគ្រាន់តែដឹងថា នៅចំពោះមុខតុលាការភាគីមិនបានប្តឹងបញ្ជូន ឬមានកិច្ចព្រមព្រៀងមជ្ឈត្តកម្មនោះ។

អត្ថបទនេះ ក៏បានបង្ហាញផងដែរ នូវសមត្ថកិច្ចរបស់ចៅក្រម ព្រមទាំងសិទ្ធិរបស់ប្រជាពលរដ្ឋដែលជាពាណិជ្ជករ នៅក្នុងការវិវឌ្ឍន៍មជ្ឈត្តកម្មពាណិជ្ជកម្មក៏ដូចជាបណ្តាបញ្ញត្តិដែលពាក់ព័ន្ធរួម។

# ផ្នែករដ្ឋប្បវេណី

# ការសុំកូន

ដោយលោក ខន សុខេង[-]

## ជំពូកទី១ សុំកូនពេញលេញ

### ផ្នែកទី១: លក្ខណៈនៃសុំកូនពេញលេញ

សុំកូនពេញលេញសំដៅដល់សុំកូនដែលមានអានុភាពបង្កើតនូវទំនាក់ទំនងអចិន្ត្រៃយ៍ជាឪពុកម្តាយ និងកូន រវាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមនឹងកូនសុំ និងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងកូននឹងឪពុកម្តាយបង្កើត ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់ខ្លួន។ អាចនិយាយបានម្យ៉ាងថា ដោយបង្កើតសុំកូនពេញលេញ កូនសុំត្រូវទទួលបានឋានៈដូចគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹម និងត្រូវទទួលសិទ្ធិ និងករណីយកិច្ចដូចគ្នានឹងកូនបង្កើត នៅក្នុងទំនាក់ទំនងជាមួយឪពុកម្តាយចិញ្ចឹម បន្ថែមពីលើនេះ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើតត្រូវបញ្ចប់ដោយកូនសុំពេញលេញ លើកលែងចំពោះសហព័ទ្ធម្ខាងក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត។

យោងតាមការបកស្រាយខាងលើ យើងអាចនិយាយជារួមបានថា កាលណាបង្កើតសុំកូនពេញលេញនាំឲ្យមានស្ថានភាពពីរកើតឡើង ទី១ គឺបង្កើតនូវទំនាក់ទំនង ឬញាតិភាពរវាងកូនសុំជាមួយឪពុកម្តាយចិញ្ចឹមដូចជាកូនបង្កើត ពោលគឺបង្កើតសិទ្ធិ និងកាតព្វកិច្ចដូចកូននឹងឪពុកម្តាយបង្កើត។ ទី២ គឺបញ្ចប់ញាតិភាព ឬទំនាក់ទំនងជាមួយឪពុកម្តាយបង្កើតក៏ដូចជាញាតិលោហិតរបស់ឪពុកម្តាយបង្កើត ពោលគឺបញ្ចប់សិទ្ធិ និងកាតព្វកិច្ចជាឪពុកម្តាយបង្កើត។

### ផ្នែកទី២: លក្ខខណ្ឌនៃសុំកូនពេញលេញ

លក្ខណៈនេះមិនមែនមានតែចំពោះភាគីម្ខាងៗនោះទេ គឺមានទាំងចំពោះឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ក៏ដូចជាចំពោះកូនចិញ្ចឹមដែរ ហេតុនេះលក្ខខណ្ឌនេះនឹង

---

[-] អ្នកនិពន្ធបច្ចុប្បន្នធ្វើការជាឧបការីព្រឹទ្ធបុរស និងសាស្ត្រាចារ្យច្បាប់ នៅសាកលវិទ្យាល័យកម្ពុជា។ លោកបានបញ្ចប់ថ្នាក់អនុបណ្ឌិតច្បាប់ ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌដែលសហប្រតិការរវាង សាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច និងសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣។ លោកក៏ទទួលបាននូវសញ្ញាបត្រ High Diploma ផ្នែកនីតិភូមិបាល និងបេតិកភ័ណ្ឌពីសាកលវិទ្យាល័យហ្សង់មូឡាំង លីយ៉ុង ៣ ផងដែរ។ អ្នកនិពន្ធបានបញ្ចប់ថ្នាក់បរិញ្ញាបត្រច្បាប់ ពីសាកលវិទ្យាល័យភូមិន្ទនីតិសាស្ត្រ និងសេដ្ឋកិច្ច និងបរិញ្ញាត្របត្រភាសាអង់គ្លេស TEFL ពីសាកលវិទ្យាល័យធនធានមនុស្ស។

លម្អិតចំពោះភាគីទាំងសងខាង។

**កថាខ័ណ្ឌទី១: លក្ខខណ្ឌចំពោះឪពុកម្តាយចិញ្ចឹម ឬម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម:**

- សហព័ទ្ធ: បុគ្គលដែលក្លាយជាឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមត្រូវតែជាបុគ្គលដែលមានសហព័ទ្ធ។
- ការសហការ និងឯកភាព: ប្តី ឬប្រពន្ធតែម្ខាងមិនអាចក្លាយជាឪពុក ឬម្តាយចិញ្ចឹមបានឡើយ បើសហព័ទ្ធម្ខាងទៀតមិនមែនជាឪពុក ឬម្តាយចិញ្ចឹមនៃកូនសុំនោះ តែលើកលែងចំពោះសហព័ទ្ធក្លាយជាឪពុក ឬម្តាយចិញ្ចឹមនៃកូនបង្កើតរបស់សហព័ទ្ធម្ខាងទៀត[29]។
- អាយុរបស់ឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម: ឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹម ត្រូវមានអាយុចាប់ពី ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅ ហើយមានអាយុច្រើនជាងកូនចិញ្ចឹម ២០(ម្ភៃឆ្នាំ)យ៉ាងតិច[30]។

**កថាខ័ណ្ឌទី២: លក្ខខណ្ឌចំពោះកូនសុំពេញលេញ**

- ជាគោលការណ៍កូនសុំត្រូវមានអាយុយ៉ាងច្រើន ៨ (ប្រាំបី)ឆ្នាំ[31] ។
- មានអាយុតិចជាងឪពុកម្តាយចិញ្ចឹម ឬឪពុកចិញ្ចឹម ឬម្តាយចិញ្ចឹមយ៉ាងតិចណាស់ ២០(ម្ភៃ) ឆ្នាំ។

## ផ្នែកទី៣: អានុភាពនៃសុំកូនពេញលេញ

រាល់កិច្ចសន្យាតែងតែបង្កើតនូវសិទ្ធិ កាតព្វកិច្ច និងអានុភាព។ មិនខុសគ្នានោះទេ កិច្ចសន្យាសុំកូនបានភ្ជាប់ភាគីទាំងសងខាងគឺ ឪពុកម្តាយចិញ្ចឹម និងកូនសុំនូវអានុភាពមួយចំនួនដូចជា៖

- បញ្ចប់នូវញាតិភាពជាមួយឪពុកម្តាយបង្កើត: ក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារគ្មានបញ្ញត្តិណាមួយដែលចែងពីការបញ្ចប់សិទ្ធិ និងកាតព្វកិច្ចរវាងឪពុកម្តាយបង្កើតនឹងកូនសុំនោះទេ ប៉ុន្តែក្នុងមាត្រា ១០១៤ នៃក្រមរដ្ឋប្បវេណីបានចែងថា

---

[29] មាត្រា៤ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស

[30] មាត្រា ១០០៩ នៃក្រមរដ្ឋប្បវេណី ២០០៧

[31] មាត្រា ១០១០ នៃក្រមរដ្ឋប្បវេណី ២០០៧

"ញាតិភាពរវាងកូនស្មុំនឹងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះត្រូវបញ្ចប់ដោយស្មុំកូនពេញលេញ។ ប៉ុន្តែមិនយកអនុវត្តឡើយចំពោះញាតិភាពជាមួយឪពុកម្តាយម្ខាងទៀតនោះ"។

- ទទួលបានឋានៈស្មើគ្នានឹងកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមៈនៅពេលបង្កើតស្មុំកូនពេញលេញ វាបណ្តាលឲ្យកូនស្មុំទទួលបានសិទ្ធិ និងកាតព្វកិច្ចដូចកូនបង្កើតរបស់ឪពុកម្តាយចិញ្ចឹមនោះ។

ក្នុងមាត្រា១០១៥ នៃក្រមរដ្ឋប្បវេណីបញ្ញត្តិថា កូនស្មុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនរបស់ខ្លួនបាន។ ប៉ុន្តែក្នុងមាត្រា១១៤ នៃច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារឆ្នាំ១៩៨៩ បានចែងថា "កូនចិញ្ចឹមត្រូវយកត្រកូលនៃអ្នកស្មុំ"។ តើនេះមានន័យថាកូនស្មុំដាច់ខាតត្រូវតែយកនាមត្រកូលអ្នកស្មុំឬយ៉ាងណា?

កូនស្មុំត្រូវស្ថិតនៅក្រោមអំណាចរបស់ឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែបញ្ញត្តិនេះមិនយកមកអនុវត្តឡើយ ចំពោះស្មុំកូនបង្កើតនៃសហព័ទ្ធម្ខាងទៀតនោះ ពោលគឺកូនចិញ្ចឹមត្រូវស្ថិតនៅក្រោមអំណាចរបស់ឪពុកម្តាយទាំងពីរនាក់។

## ផ្នែកទី៤: ការកាត់កាល់ស្មុំកូនពេញលេញ

ក្នុងក្រមរដ្ឋប្បវេណីមិនបានឲ្យនិយមន័យនៃការកាត់កាល់នោះទេ តែបើក្រឡេកមើលក្នុងវចនានុក្រមរបស់សម្តេចព្រះសង្ឃរាជ **ជួន ណាត**បានកំណត់ថា បោះបង់លែងរាប់អានតទៅ ដូចនេះការកាត់កាល់ស្មុំកូនពេញលេញ ជាស្ថានភាពមួយដែលបញ្ចប់ញាតិភាពរវាងកូនស្មុំ និងឪពុកម្តាយបង្កើត។

### កថាខ័ណ្ឌទី១: លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនពេញលេញ

តុលាការជាអ្នកមានអំណាចសម្រេចលើការកាត់កាល់ភាគីនៃកូនស្មុំបាន បើយល់ឃើញថាការកាត់កាល់នេះមានភាពចាំបាច់ពិសេស ដើម្បីផលប្រយោជន៍របស់កូនស្មុំតាមពាក្យរបស់កូនស្មុំ ឪពុកម្តាយបង្កើត ឬតំណាងអយ្យការ។

ហើយការកាត់កាល់នេះអាចធ្វើទៅបានលុះត្រាតែក្នុងករណីដែលត្រូវនឹងចំណុចទាំងអស់ ដែលបានកំណត់ក្នុងចំណុចនីមួយៗខាងក្រោមនេះ៖

- បើមានការធ្វើបាបដោយឪពុកម្តាយចិញ្ចឹម បោះបង់កូនចោលដោយគំនិតទុច្ចរិត ឬហេតុផលផ្សេងៗទៀតដែលបំពានផលប្រយោជន៍របស់កូនស្មុំយ៉ាងធ្ងន់ធ្ងរ។

- ឪពុកម្តាយបង្កើតអាចគ្រប់គ្រងថែរក្សាដោយសមរម្យ។ នៅក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារក៏បានកំណត់ថា តុលាការប្រជាជនអាចបដិសេធកិច្ចសន្យាសុំកូនបានតាមពាក្យបណ្តឹងរបស់កូនចិញ្ចឹមរបស់ជនទាំងឡាយ ឬអង្គការផ្សេងៗទៀត ដែលធ្វើឡើងដើម្បីផលប្រយោជន៍របស់កូនចិញ្ចឹមនោះ។

បញ្ញត្តិដែលបានចែងក្នុងច្បាប់អាពាហ៍ពិពាហ៍ និងគ្រួសារ ឃើញថាមានភាពទូលំទូលាយជាង ដែលបានបើកទូលាយចំពោះឲ្យជនទាំងឡាយ និងអង្គការផ្សេងៗដាក់ពាក្យបណ្តឹងដើម្បីបដិសេធសុំកូននេះ ដែលអាចបន្ថែមការការពារដល់ប្រយោជន៍របស់កូនសុំមួយកម្រិតថែមទៀត។

## កថាខ័ណ្ឌទី២: អានុភាពនៃការកាត់កាល់សុំកូនពេញលេញ

នៅពេលកិច្ចសន្យាសុំកូនត្រូវបានផុតរលត់ដោយការកាត់កាល់នេះ វាបណ្តាលឲ្យមានអានុភាពផ្សេងៗចំពោះភាគីទាំងសងខាងនៃកិច្ចសន្យានេះ ពោលគឺឪពុកម្តាយចិញ្ចឹម និងកូនសុំ។ ញាតិភាពរវាងកូនចិញ្ចឹមសហព័ទ្ធរបស់ជននោះ បច្ឆាញាតិផ្ទាល់ និង សហព័ទ្ធរបស់បច្ឆាញាតិផ្ទាល់នោះ ជាមួយឪពុកម្តាយចិញ្ចឹម និងញាតិលោហិតរបស់ឪពុកម្តាយចិញ្ចឹមនោះត្រូវបានបញ្ចប់ដោយការកាត់កាល់ ឬលែងទទួលស្គាល់។ អានុភាពមួយផ្សេងទៀតគឺ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយបង្កើត ព្រមទាំងញាតិលោហិតរបស់ឪពុកម្តាយបង្កើតនោះ ដែលបានបញ្ចប់ដោយសុំកូនពេញលេញត្រូវបានកើតឡើងវិញចាប់ពីថ្ងៃកាត់កាល់។ ជារួមមកនៅពេលកាត់កាល់សុំកូនពេញលេញបណ្តាលឲ្យមានអានុភាពពីរយ៉ាងគឺ ទីមួយៈ វាបណ្តាលឲ្យញាតិភាពរវាងកូនសុំនិងឪពុកម្តាយចិញ្ចឹម ក៏ដូចជាញាតិលោហិតរបស់ឪពុកម្តាយនោះត្រូវបានបញ្ចប់។ ទីពីរៈញាតិភាពរវាងកូន និងឪពុកម្តាយបង្កើតក៏ដូចជាញាតិលោហិតនៃឪពុកម្តាយដែលពីមុនបានបញ្ចប់ដោយសុំកូនពេញលេញត្រូវបានបង្កើតឡើងដោយការកាត់កាល់នេះ។

## កថាខ័ណ្ឌទី៣: សិទ្ធិដឹងពីកំណើតរបស់កូនសុំពេញលេញ

កូនសុំពេញលេញដែលបានក្លាយជានីតិជន អាចទាមទារបង្ហាញនូវព័ត៌មានទំហំដែលចាំបាច់ចំពោះតុលាការ ដែលរក្សាទុកនូវសំណុំរឿងស្តីពីសុំកូនបាន។ នៅពេលសុំទាមទារនូវការបង្ហាញព័ត៌មានចាំបាច់នេះ ត្រូវគោរពតាមនីតិវិធីនៃតុលាការ។

## ជំពូកទី២ សុំកូនធម្មតា

### ផ្នែកទី១: លក្ខខណ្ឌនៃសុំកូនធម្មតា

- បុគ្គលដែលមានអាយុ២៥ (ម្ភៃប្រាំ) ឆ្នាំឡើងទៅអាចដាក់ពាក្យសុំកូនជាមួយនឹងបុគ្គលដែលនឹងក្លាយជាកូនសុំនៅតុលាការឲ្យបង្កើតសុំកូនធម្មតាបាន។
- បុគ្គលដែលនឹងក្លាយជាកូនសុំ មិនត្រូវជាបុព្វញាតិរបស់បុគ្គលដែលនឹងត្រូវក្លាយជាឪពុកម្តាយចិញ្ចឹម ហើយក៏មិនត្រូវជាបុគ្គលដែលមានអាយុច្រើនជាបុគ្គលឪពុកម្តាយចិញ្ចឹមដែរ[32]។
- ករណីដែលបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន អ្នកមានអំណាច ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ ត្រូវដាក់ពាក្យសុំសុំកូនជាមួយភាគីឪពុកម្តាយចិញ្ចឹម។
- ចំពោះបុគ្គលដែលមានសហព័ទ្ធ ការដាក់ពាក្យសុំនៃសុំកូនធម្មតា ត្រូវមានការយល់ព្រមពីសហព័ទ្ធម្ខាងទៀត។ លើសពីនេះបើកូនសុំជាអនីជន ការដាក់ពាក្យសុំត្រូវធ្វើជារួមជាមួយសហព័ទ្ធ និងម្ខាងទៀត។ ប៉ុន្តែបញ្ញត្តិមិនត្រូវអនុវត្តឡើយចំពោះករណីដែលយកកូនសហព័ទ្ធមកធ្វើជាកូនសុំ ឬករណីដែលសហព័ទ្ធម្ខាងទៀតមិនអាចបង្ហាញឆន្ទៈបាន។
- តុលាការអាចបង្កើតសុំកូនធម្មតាបាន លុះត្រាករណីដែលអាចបង្ហាញពីឆន្ទៈពិតប្រាកដរបស់ភាគីក្នុងការបង្កើតទំនាក់ទំនងរវាងឪពុកម្តាយនឹងកូន។
- តុលាការមិនត្រូវឲ្យបង្កើតសុំកូនឡើយ បើយល់ឃើញថាសុំកូនត្រូវបានបំពានក្នុងគោលបំណងរៀបអាពាហ៍ពិពាហ៍រវាងភេទផ្សេងគ្នា ឬភេទដូចគ្នា ឬគោលបំណងមិនត្រឹមត្រូវផ្សេងទៀត[33]។
- បើបុគ្គលដែលនឹងក្លាយជាកូនសុំជាអនីតិជន តុលាការអាចឲ្យបង្កើតសុំកូនបានលុះត្រាតែយល់ឃើញថាមានភាពចាំបាច់ពិសេស ដើម្បីប្រយោជន៍អនីតិជននោះ។

[32] មាត្រា ១០២១ នៃក្រមរដ្ឋប្បវេណី ២០០៧

[33] មាត្រា ១០២០ នៃក្រមរដ្ឋប្បវេណី ២០០៧

- បើឪពុកម្តាយរបស់អនីតិជននោះបានលែងលះគ្នាហើយ តុលាការត្រូវសួរយោបល់របស់ឪពុកម្តាយ ឬម្តាយដែលមានអំណាចមេបាដើម្បីវិនិច្ឆ័យ។
- ទោះបីជាអនីតិជននោះមិនទាន់ដល់ ១៥ឆ្នាំក៏ដោយ បើអនីតិជននោះអាចបង្ហាញឆន្ទៈរបស់ខ្លួនតុលាការត្រូវសួរយោបល់របស់អនីតិជននោះដើម្បីវិនិច្ឆ័យ
- ក្នុងករណីដែលអ្នកអាណាព្យាបាលសម្រាប់អនីតិជន ដាក់ពាក្យឲ្យបង្កើតសុំកូនដោយយកអនីតិជននៅក្រោមអាណាព្យាបាលរបស់ខ្លួនមកធ្វើជាកូនសុំ ឬករណីដែលអាណាព្យាបាលទូទៅដាក់ពាក្យសុំឲ្យបង្កើតសុំកូនបាន លុះត្រាតែក្នុងករណីដែលបានអនុវត្តត្រឹមត្រូវក្នុងការគ្រប់គ្រង ថែរក្សានៅក្រោមអាណាព្យាបាល និងការគ្រប់គ្រងទ្រព្យសម្បត្តិ[34]។

## ផ្នែកទី២:អានុភាពនៃសុំកូនធម្មតា

សុំកូនធម្មតាមានអត្ថប្រយោជន៍ជាច្រើនដូចជា ៖

- ទោះបីជាមានការបង្កើតសុំកូនធម្មតាក៏ដោយ ញាតិភាពរវាងកូនសុំ និងឪពុកម្តាយត្រូវបន្តអត្ថិភាព ហើយកូនសុំ និងឪពុកម្តាយង្កើតមានសិទ្ធិធ្វើសន្តតិកម្មគ្នាទៅវិញទៅមក។
- កូនសុំ និងឪពុកម្តាយបង្កើតមានសិទ្ធិទាមទារ និងករណីកិច្ចផ្គត់ផ្គង់អាហារកិច្កាតព្វកិច្ច។
- កូនសុំអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹម ឬនាមត្រកូលមុនសុំកូនបាន។
- ក្នុងករណីដែលកូនសុំជាអនីតិជន កូនសុំត្រូវស្ថិតនៅក្រោមអំណាចមេបារួមរបស់ឪពុកម្តាយចិញ្ចឹម។ ប៉ុន្តែក្នុងករណីដែលយកកូនបង្កើតរបស់សហព័ទ្ធមកធ្វើជាកូនសុំ កូនសុំនោះត្រូវស្ថិតនៅក្រោមអំណាអាណាព្យាបាលរួមរបស់ឪពុក ឬម្តាយចិញ្ចឹម និងសហព័ទ្ធនោះ។

---

[34] មាត្រា ១០០៨ នៃក្រមរដ្ឋប្បវេណី ២០០៧

## ផ្នែកទី៣:ការកាត់កាល់ស្មុំកូនធម្មតា

### កថាខ័ណ្ឌទី១:ពាក្យសុំឲ្យកាត់កាល់ស្មុំកូនធម្មតា

- ភាគីនៃស្មុំកូនអាចដាក់ពាក្យសុំទៅតុលាការ ឲ្យកាត់កាល់ស្មុំកូនធម្មតាបានក្នុងករណីដែលភាគីទាំងសងខាងព្រមព្រៀងអំពីការកាត់កាល់នោះ។
- ក្នុងករណីដែលកូនស្មុំជាអនីតិជន ពាក្យសុំកាត់កាល់ដែលបានធ្វើឡើងដោយមានការព្រមព្រៀងគ្នានោះ ត្រូវធ្វើឡើងដោយឪពុកម្តាយចិញ្ចឹម និងបុគ្គលដែលនឹងត្រូវក្លាយជាអ្នកតំណាងដែលច្បាប់បានកំណត់ក្រោយពេលកាត់កាល់។ តែបើកូនស្មុំដល់អាយុ ១៥ (ដប់ប្រាំ)ឆ្នាំហើយក៏ដោយ ត្រូវទទួលការយល់ព្រមពីកូនស្មុំនោះ។ ទោះបីជាអនីតិជននោះមិនទាន់ដល់អាយុអនីតិជន នោះអាចបង្ហាញឆន្ទៈរបស់ខ្លួន តុលាការត្រូវសួរយោបល់របស់អនីតិជននោះ
- ក្នុងករណីដែលឪពុកម្តាយបង្កើតរបស់កូនស្មុំបានលែងលះគ្នាហើយ ឪពុកម្តាយរបស់កូនស្មុំនោះត្រូវពិភាក្សា និងកំណត់ថា ឪពុក ឬម្តាយបង្កើតជាបុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបានៅក្រោយពេលកាត់កាល់។
- បើសិនជាការពិភាក្សាខាងលើពុំបានសម្រេច ឬពុំអាចពិភាក្សាបានទេ តុលាការត្រូវកំណត់បុគ្គលដែលត្រូវក្លាយជាអ្នកមានអំណាចមេបា ដោយគិតពិចារណាទៅលើផលប្រយោជន៍របស់កូនស្មុំ[35]។

### កថាខ័ណ្ឌទី២:លក្ខខណ្ឌនៃការកាត់កាល់ស្មុំកូនធម្មតា

ដើម្បីឲ្យការកាត់កាល់ស្មុំកូនធម្មតាប្រព្រឹត្តទៅបាន លុះត្រាតែមានមូលហេតុដូចខាងក្រោម៖

- ភាគីម្ខាងនៃកូនស្មុំអាចដាក់ពាក្យបណ្តឹងទាមទារឲ្យកាត់កាល់បានលុះត្រាតែ ៖
  - ❖ បើត្រូវបានបោះបង់ចោលដោយភាគីម្ខាងទៀតដោយទុច្ចរិត
  - ❖ បើមិនច្បាស់ក្នុងអំឡុងពេលយ៉ាងតិច ១(មួយ) ឆ្នាំ ថាភាគីម្ខាងទៀតមិននៅ ឬទទួលមរណៈភាព
  - ❖ បើមិនមានមូលហេតុធ្ងន់ធ្ងរផ្សេងទៀត ដែលបណ្តាលឲ្យមានការពិបាកក្នុងការបន្តស្មុំកូន។

---

[35] មាត្រា ១០២៨ នៃក្រមរដ្ឋប្បវេណី ២០០៧

- ក្នុងអំឡុងពេលដែលកូនស្មុំពុំទាន់ក្លាយជានីតិជន ឪពុកម្តាយចិញ្ចឹមមិនអាចដាក់ពាក្យបណ្តឹងសុំកាត់កាល់ចំពោះកូនស្មុំបានឡើយ។
- ទោះបីក្នុងករណីកូនស្មុំជាអនីតិជនក៏ដោយ ក៏កូនស្មុំអាចដាក់ពាក្យបណ្តឹងចំពោះឪពុកម្តាយចិញ្ចឹមបានដែរ ឲ្យតែបានគោរពលក្ខខណ្ឌដូចដែលបានកំណត់ខាងលើ។

**កថាខណ្ឌទី៣: អានុភាពនៃការកាត់កាល់កូនស្មុំធម្មតា**

- អានុភាពទាំងឡាយនៃស្មុំកូនធម្មតា ត្រូវបញ្ចប់ទៅអនាគតដោយការកាត់កាល់
- ក្រោយការកាត់កាល់ កូនស្មុំអាចទទួលបានវិញនូវនាមត្រកូលមុនស្មុំកូនក៏បាន ឬអាចប្រើនាមត្រកូលរបស់ឪពុកម្តាយចិញ្ចឹមក៏បាន។

**កថាខណ្ឌទី៤: ប្រៀបធៀបលក្ខណៈខុសគ្នារវាងស្មុំកូនពេញលេញ និងស្មុំកូនធម្មតា**

| ស្មុំកូនពេញលេញ | ស្មុំកូនធម្មតា |
|---|---|
| **លក្ខខណ្ឌ** | **លក្ខខណ្ឌ** |
| - ឪពុកម្តាយចិញ្ចឹមត្រូវមានអាយុចាប់ពី ២៥ឆ្នាំ<br>- មានអាយុ ច្រើនជាងកូនស្មុំ ២០ឆ្នាំ និងត្រូវមានសហព័ទ្ធ<br>- កូនស្មុំត្រូវមានអាយុតិចជាង ៨ ឆ្នាំ | - បុគ្គលដែលស្មុំកូនត្រូវមានអាយុចាប់ពី ២៥ឆ្នាំឡើងទៅអាចមាន ឬគ្មានសហព័ទ្ធ<br>- មិនកំណត់ឲ្យតែមានអាយុតិចជាងឪពុក ឬម្តាយចិញ្ចឹម ឬឪពុកម្តាយចិញ្ចឹម<br>- មិនបានកំណត់ |
| **អានុភាព** | **អានុភាព** |
| - មានអំឡុងពេលចិញ្ចឹមសាកល្បង<br>- បញ្ចប់ញាតិភាពរវាងកូនស្មុំនឹងឪពុកម្តាយបង្កើត | - រក្សាញាតិភាពនិងអាចធ្វើសន្តតិកម្មឲ្យគ្នាទៅវិញទៅមករវាង ឪពុកម្តាយបង្កើត និង ភាគីកូនស្មុំ។<br>- អាចទាមទារអាហារកិច្ចទៅវិញទៅមកបាន |

| កាត់កាល | កាត់កាល |
|---|---|
| - មិនអាចទាមទារអាហារកិច្ចទេ<br>- ភាគីសុំកូនអាចដាក់ពាក្យសុំកាត់ នោះជានីតិជន។<br>- កាត់កាលក្នុងករណីមានការធ្វើបាបយ៉ាងធ្ងន់ធ្ងរផ្សេងទៀត និងឪពុក ម្តាយបង្កើត មានសមត្ថភាពក្នុងការមើលថែកូនចិញ្ចឹមនោះ។ | - ដាក់ពាក្យរួមជាមួយឪពុកម្តាយចិញ្ចឹម និងកូនសុំ ឬអាណាព្យាបាលនៃកូនសុំ បើកូនសុំនោះជានីតិជន។<br>- អាចដាក់ពាក្យសុំកាត់កាល់បានបើត្រូវបោះបង់ដោយភាគីម្ខាងទៀតដោយទុច្ចរិត បើមិនច្បាស់ក្នុងអំឡុងពេលយ៉ាងតិចមួយឆ្នាំថាភាគីម្ខាងទៀតស្លាប់ ឬរស់។ |

## ជំពូកទី៣ ទិដ្ឋភាពទូទៅនៃសុំកូនអន្តរប្រទេស

### ១ - ទិដ្ឋភាពទូទៅនៃការសុំកូនអន្តរប្រទេស

ទិដ្ឋភាពទូទៅនៃសុំកូនអន្តរប្រទេស ត្រូវបានស្វែងតាមរយៈសញ្ញាណទូទៅនៃការសុំកូនអន្តរប្រទេស លើសពីនេះទៅទៀតបើភាគីទាំងអស់នៃសុំកូនអន្តរប្រទេសមិនគោរពច្បាប់ ភាគីនោះនឹងត្រូវទទួលរងនូវទណ្ឌកម្ម។

#### *ផ្នែកទី១: សញ្ញាណទូទៅនៃការសុំកូនអន្តរប្រទេស*

ដើម្បីសិក្សាអំពីសញ្ញាណទូទៅនៃសុំកូនអន្តរប្រទេស ជាបឋមត្រូវយល់អំពី:

##### ក. សារៈសំខាន់ចំពោះកូនសុំ

**សុំកូនអន្តរប្រទេស** បានផ្តល់សារៈសំខាន់ដល់ច្រើនលើសលប់ដល់ទារក ក៏ដូចជាកុមារកំព្រា ដើម្បីរកបាននូវគ្រួសារមួយដែលមានសុភមង្គល សេចក្តីស្រលាញ់ ការយកចិត្តទុកដាក់ ថែរក្សា ការអប់រំ ការយោគយល់ ព្រមទាំងនឹងមានអនាគតដ៏ល្អមួយ និង មានឧត្តមប្រយោជន៍ផ្សេងៗទៀត ដែលទារក និង កុមារកំព្រាទាំងនោះនឹងមិនអាចទទួលបាន ប្រសិនបើពួកគេរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្នុងគ្រួសារមួយមានជីវភាពទុរគត។ លើសពីនេះ

ទៅទៀតកុមារអាចទទួលបាននូវកិច្ចការពារពិសេស ទទួលបាននូវឱកាស និង លក្ខណៈងាយស្រួលទាំងក្នុងផ្លូវច្បាប់ និងតាមផ្លូវមធ្យោបាយផ្សេងៗទៀតដើម្បីអាចឲ្យមាន ការលូតលាស់ជាប្រក្រតីខាងផ្នែករាងកាយ សតិបញ្ញា សីលធម៌ ស្មារតី និងសង្គមនៅក្នុងលក្ខខណ្ឌ នៃសេរីភាព និងភាពថ្លៃថ្នូរ។

ប៉ុន្តែមិនមានន័យថា នៅពេលដែលកុមារត្រូវបានគេសុំទៅរស់នៅបរទេសទាំងនោះ សុទ្ធតែទទួលបានផលវិជ្ជមានទាំងអស់នោះទេ។ វាអាចមិនដូចអ្វីដែលបានរៀបរាប់ខាងលើ ប្រសិនបើគ្មាន **ច្បាប់ស្តីពីសុំកូនអន្តរប្រទេស** ការពារដោយហេតុថាច្បាប់នេះ គឺជាមូលដ្ឋានសម្រាប់ការគ្រប់គ្រង ទប់ស្កាត់ និងបង្ក្រាបនូវការបង្ខាំង ការជួញដូរ ការកេងប្រវ័ញ្ចលើមនុស្ស ឬការធ្វើជាភ្នាក់ងារកណ្តាល នៃការលក់ដូរមនុស្សដោយខុសច្បាប់ ដែលកើតចេញពីនីតិវិធីសុំកូនអន្តរប្រទេស។

### ខ. សារៈសំខាន់ចំពោះអ្នកសុំកូន

ចំពោះអ្នកដែលមិនមានបុត្រាបុត្រី អាចសុំកូនយកទៅចិញ្ចឹម ដើម្បីបង្កើតបានជាគ្រួសារដែលពេញលក្ខណៈមួយបាន។ ចំពោះអ្នកដែលមានកូនតែម្នាក់នៅក្នុងបន្ទុក ក៏អាចសុំកូនយកទៅចិញ្ចឹមបន្ថែមបានម្នាក់ទៀតបានដែរ(អាចសុំបានច្រើនជាងម្នាក់ ប្រសិនបើកូនសុំនោះមានបងប្អូនបង្កើត)។ ដើម្បីបង្កើនភាពអ៊ូអរ ឬសុភមង្គល នៅក្នុងគ្រួសារបានមួយកម្រិតថែមទៀត។

### គ. សារៈសំខាន់ចំពោះរដ្ឋ

ការសុំកូនអន្តរប្រទេសបានរួមចំណែកយ៉ាងសំខាន់ក្នុងការបន្តពង្រឹងគោលនយោបាយរបស់រាជរដ្ឋាភិបាល ក្នុងគោលដៅមនុស្សធម៌សុទ្ធសាធ ដើម្បីរកគ្រួសារល្អឲ្យកុមារ និងធានាឧត្តមភាពប្រយោជន៍របស់កុមារ ពង្រឹងពង្រីកកិច្ចសហប្រតិបត្តិការជាមួយប្រទេសនានា ដើម្បីទប់ស្កាត់ការជួញដូរកុមារ។ ជួយសម្រាលបន្ទុកដល់អាជ្ញាធរសាធារណៈ ក្នុងការថែទាំចំពោះកុមារដែលគ្មានគ្រួសារ និងគ្មានមធ្យោបាយទ្រទ្រង់ជីវិត។ ម្យ៉ាងទៀតក៏អាចជួយសម្រាលរដ្ឋចំពោះការចំណាយក៏ដូចជាការជួយឧបត្ថម្ភផ្សេងៗក្នុងការចិញ្ចឹមបីបាច់ទារក ឬកុមារកំព្រាដែលរស់នៅក្នុងមណ្ឌលកុមារកំព្រា។ លើសពីនេះទៅទៀតប្រសិនបើទារក ឬកុមារកំព្រាទាំងនោះមិនថាស្រី ឬប្រុសឡើយ ចម្រើនវ័យធំធាត់ដែលមានអាយុពី ១៧ឆ្នាំឡើងទៅ ពុំមានលទ្ធភាពសិក្សាទៅមុខទៀតបាន រដ្ឋត្រូវដោះស្រាយការងារឲ្យធ្វើតាមសមត្ថភាពគេជាក់ស្តែង។

ក្នុងករណីមានរៀបអាពាហ៍ពិពាហ៍ត្រូវបានអង្គភាពរដ្ឋ អំណាច/រាជធានី និងអង្គការមហាជន បង្គលក្ខណៈខាងស្មារតី និងសម្ភារៈ ។

### កថាខ័ណ្ឌទី១:និយមន័យ

ស្មុំកូនគឺជាកិច្ចសន្យាដែលចងបុគ្គលពីរនាក់ គឺម្នាក់ហៅថាឪពុកចិញ្ចឹម ឬ ម្ដាយចិញ្ចឹម ហើយម្នាក់ទៀត ហៅថាកូនចិញ្ចឹមឲ្យមានចំណងនឹងគ្នា ដូចជាបុគ្គភាពមានខាន់ស្លា ។

ស្មុំកូនអន្តរប្រទេសគឺជាការស្មុំទារក ឬកុមារកំព្រាសញ្ជាតិកម្ពុជា មានលំនៅដ្ឋានអចិន្ត្រៃយ៍នៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយប្ដីប្រពន្ធ ដែលរស់នៅក្នុងប្រទេសផ្សេងទៀត ដើម្បីកាត់យកទៅចិញ្ចឹមជាកូនហើយនិងទទួលស្គាល់ដោយច្បាប់របស់ប្រទេសនោះ។ ស្មុំកូនអន្តរប្រទេសអាចអនុញ្ញាតបានបន្ទាប់ពីអាជ្ញាធរកម្ពុជា បានប្រឹងប្រែងឲ្យអស់លទ្ធភាពក្នុងការបញ្ជូនកុមារទៅគ្រួសារកំណើតវិញ ឬក៏រកលក្ខណៈសម្បត្តិស្មុំកូនក្នុងស្រុកជាមុនរួចហើយ។ ស្មុំកូនអន្តរប្រទេសត្រូវបានគ្រប់គ្រងដោយច្បាប់ស្ដីពីស្មុំកូនអន្តរប្រទេស ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខក្រមលេខ នស/រកម/1209/024 ចុះថ្ងៃទី ០៣ ខែធ្នូ ឆ្នាំ ២០០៩ ហើយដែលប្រកាសជាប្រញាប់ផង។ ច្បាប់នេះត្រូវបានតាក់តែងឡើង ដោយពឹងផ្អែកទៅលើគោលការណ៍នៃកតិកាសញ្ញា និងអនុសញ្ញាអន្តរជាតិទាក់ទងនឹងកុមារ ព្រមទាំងក្រមនីតិវិធីរដ្ឋប្បវេណីឆ្នាំ ២០០៦ ក្រមរដ្ឋប្បវេណីឆ្នាំ ២០០៧ ច្បាប់ស្ដីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទឆ្នាំ ២០០៨ និងច្បាប់ពាក់ព័ន្ធមួយចំនួនទៀតជាជំនួយ។

### កថាខណ្ឌទី ២ គោលការណ៍ទូទៅនៃស្មុំកូនអន្តរប្រទេស

**ច្បាប់ស្ដីពីការស្មុំកូនអន្តរប្រទេស**បានកំណត់នូវគោលការណ៍ទូទៅមួយចំនួន ទាក់ទងនឹងការស្មុំកូនទៅរស់នៅឯបរទេស។ នៅក្នុងគោលការណ៍ទាំងនេះអ្នកតាក់តែងច្បាប់បានគិតដល់ឧត្តមប្រយោជន៍របស់កុមារជាចំបង ដែលបានកំណត់ដូចតទៅៈ

- កុមារត្រូវចំរើនការធំធាត់នៅក្នុងបរិយាកាសគ្រួសារ ដែលមានសុភមង្គល មានប្រពន្ធសេចក្ដីស្រលាញ់ និង ការយោគយល់ ដើម្បីឲ្យពួកគេមានការអភិវឌ្ឍពេញលេញនូវបុគ្គលិកលក្ខណៈរបស់ពួកគេ។
- ស្មុំកូនអន្តរប្រទេសអាចអនុញ្ញាតបានក្រោយពីអស់លទ្ធភាពផ្ដល់ការឧបត្ថម្ភគាំទ្រ ដើម្បីឲ្យកុមាររស់នៅក្នុងគ្រួសារកំណើត។

- ស្មុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបាន លុះត្រាជាស្មុំកូនពេញលេញ ដែលបង្កើតទំនាក់ទំនងរវាងអ្នកស្មុំនិងកូនស្មុំជាអចិន្ត្រៃយ៍ ដែលអាចផ្តល់នូវឋានៈ សិទ្ធិ និងកាតព្វកិច្ចដូចកូនបង្កើតរបស់ខ្លួន។
- រាល់សេចក្តីសម្រេច និងសកម្មភាពទាក់ទងនឹងដំណើរការស្មុំកូនអន្តរប្រទេស ត្រូវគិតគូរឲ្យបានច្រើនចំពោះឧត្តមប្រយោជន៍របស់កុមារ។
- តុលាការ និងអាជ្ញាធរមានសមត្ថកិច្ចដែលពាក់ព័ន្ធក្នុងដំណើរការស្មុំកូនអន្តរប្រទេសត្រូវធានាថា នៅកំពុងដំណើរការនីតិវិធីស្មុំកូន កុមារដែលមានសមត្ថភាពអាចដឹងខុសត្រូវត្រូវបានពិគ្រោះយោបល់ និងពន្យល់ណែនាំឲ្យបានត្រឹមត្រូវអំពីអានុភាពនានាដែលកើតចេញពីស្មុំកូននេះ ដោយគិតគូរដល់សេចក្តីប្រាថ្នា និងមតិរបស់កុមារដើម្បីឧត្តមប្រយោជន៍របស់កុមារ។
- ហាមធ្វើអាជីវកម្ម ឬ ធ្វើសកម្មភាពយកផលកម្រៃពីស្មុំកូនអន្តរប្រទេស ក្នុងករណីដូចខាងក្រោម ៖
  - អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើ ញុះញង់ដោយផ្ទាល់ដល់ឪពុកម្តាយឲ្យបោះបង់ទារកដែលកើតមកហើយ ឬក៏នឹងកើតដើម្បីប្រគល់កូនតាមរយៈស្មុំកូនអន្តរប្រទេស។
  - ករណីធ្វើជាអន្តរការីរវាងប្តីប្រពន្ធ ដែលចង់ស្មុំកូនយកចិញ្ចឹមតាមរយៈស្មុំកូនអន្តរប្រទេស និងឪពុក ឬម្តាយដែលចង់បោះបង់កូនដែលកើតមកហើយ ឬដែលនឹងកើត។
  - តាមរយៈស្ត្រីដែលព្រមពរពោះដើម្បីនឹងប្រគល់កូននោះទៅអ្នកស្មុំ។
  - អាជ្ញាធរមានសមត្ថកិច្ចដែលជាប់ពាក់ព័ន្ធក្នុងនីតិវិធីស្មុំកូនអន្តរប្រទេស ត្រូវធានាថាដំណើរការស្មុំកូនអន្តរប្រទេស មិនបណ្តាលឲ្យមានការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនស្របច្បាប់ត្រូវបង្ការមិនឲ្យមានការចាប់ពង្រាត់ និង ការលក់ និងការជួញដូរកុមារ ក្នុងពេលដំណើរស្មុំកូនអន្តរប្រទេស។ មានតែប្រាក់ចំណាយសោហ៊ុយ និងវិភាគទានដែលកំណត់ដោយបញ្ញត្តិនៃច្បាប់នេះដែលត្រូវបង់[36]។

---

[36] មាត្រា ៥ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ២០០៩

### *ផ្នែកទី២: លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស*

លក្ខខណ្ឌសម្រាប់សុំកូនអន្តរប្រទេស ត្រូវបានកំណត់យ៉ាងច្បាស់នៅក្នុង**ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស**ដែលមានទាំងលក្ខខណ្ឌចំពោះកូនសុំ(**កថាខណ្ឌទី១**)លក្ខខណ្ឌចំពោះឳពុកម្តាយបង្កើត ឬ អាណាព្យាបាល(**កថាខណ្ឌទី២**) និង លក្ខខណ្ឌចំពោះអ្នកសុំ(**កថាខណ្ឌទី៣**) ។

#### (១) អំពីកូនសុំ

#### ក. កុមារដែលមានអត្តសញ្ញាណត្រឹមត្រូវ

កុមារអាចជាកម្មវត្ថុនៃការសុំកូនអន្តរប្រទេសបាន ត្រូវតែមានលក្ខខណ្ឌដូចខាងក្រោមៈ

- កុមារមានសញ្ជាតិខ្មែរដែលមានលំនៅដ្ឋានអចិន្ត្រៃយ៍ក្នុងព្រះរាជាណាចក្រកម្ពុជា។
- កុមារអាយុក្រោម ៨(ប្រាំបី) ឆ្នាំ គិតត្រឹមថ្ងៃទទួលពាក្យសុំ លើកលែងតែក្នុងករណីកុមារត្រូវការនូវការថែទាំពិសេស ដែលអនុញ្ញាតបានដល់អាយុក្រោម១៨ឆ្នាំ ។
- ក្នុងករណីមានបងប្អូនបង្កើតច្រើននាក់ ហើយម្នាក់មានអាយុក្រោម ៨ (ប្រាំបី)ឆ្នាំ អាចអនុញ្ញាតឲ្យសុំកុមារនោះ រួមជាមួយនឹងបងប្អូនបង្កើតដែលមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ។
- កុមារកំពុងរស់នៅក្នុងមណ្ឌលកុមារកំព្រា ឬរស់នៅក្រោមការទុកដាក់សមស្របផ្សេងៗដែលត្រូវពិនិត្យដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- កុមារទាំងអស់នោះស្ថិតក្រោមអាណាព្យាបាលសម្រាប់អនីតជន ឬកុមារដែលស្ថិតនៅក្រោមអំណាចមេបាដែលមានស្ថានភាពលំបាកបំផុត។
- កុមារទាំងអស់នោះត្រូវបានប្រកាសថា អាចសុំជាកូនចិញ្ចឹមបានដោយអនុលោមតាមមាត្រា១៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ចុះថ្ងៃទី២៣ ខែតុលា ឆ្នាំ២០០៩ ដែលប្រកាសឲ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/១២០៩/០២៤។
- ក្នុងករណីសុំកូនដោយសាច់ញាតិ សុំកូនអាចអនុញ្ញាតបានចំពោះកុមារមានអាយុក្រោម ១៨(ដប់ប្រាំបី)ឆ្នាំ ដែលរស់នៅក្នុង ឬក្រៅមណ្ឌលកុមារកំព្រា ។

#### ខ. កុមារដែលពុំត្រូវបានគេស្គាល់អត្តសញ្ញាណ

ករណីកុមារត្រូវបានរកឃើញ និងបញ្ជូនមកហើយរកមិនឃើញឳពុកម្តាយ ឬសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន នោះប្រធានកុមារកំព្រាត្រូវជូនដំណឹងទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានីខេត្ត អំពីវត្តមានរបស់កុមារដែលបានចូលមកស្នាក់នៅក្នុងមណ្ឌលយ៉ាងយូរបំផុតរយៈពេល ៧ (ប្រាំពីរ)ថ្ងៃ នៃថ្ងៃធ្វើការគិតពីពេលដែលកុមារមកដល់

មណ្ឌល។ មន្ទីរទទួលបន្ទុកវិស័យសេដ្ឋកិច្ចរាជធានី/ខេត្ត ត្រូវជូនដំណឹងជាបន្ទាន់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចដើម្បីបញ្ចូលកុមារទៅក្នុងបញ្ជីស្តីពី កុមារដែលបានរាយការណ៍ថាត្រូវបានគេបោះបង់ចោល។

មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ត្រូវប្រឹងប្រែងគ្រប់លទ្ធភាពដើម្បីស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអាណាព្យាបាលសម្រាប់អនីតិជនជាមុននៅទូទាំងព្រះរាជាណាចក្រកម្ពុជា ដោយប្រើប្រាស់ប្រព័ន្ធផ្សព្វផ្សាយជាសាធារណៈទៅតាមលទ្ធភាព។ ជនណាដែលអះអាងខ្លួនជាឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ជននោះត្រូវបង្ហាញភស្តុតាងផ្សេងៗ ដែលបញ្ជាក់ថាខ្លួនមានជាប់ទាក់ទង ជាសាច់ញាតិ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនជាមួយកុមារស្របទៅតាមបទបញ្ញត្តិជាធរមាន[37]។

បន្ទាប់ពីផ្សព្វផ្សាយដំណឹងរយៈពេលប្រាំខែ នៅតែរកមិនឃើញឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ និងអាណាព្យាបាលសម្រាប់អនីតិជនជាមុននោះ មន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ត្រូវធ្វើរបាយការណ៍ស្តីពីការខិតខំប្រឹងប្រែងស្រាវជ្រាវនេះ ហើយត្រូវផ្ញើសារមួយច្បាប់ទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីចុះឈ្មោះកុមារ ទៅក្នុងសៀវភៅកត់ត្រាកុមារដែលត្រូវបោះបង់ចោល។

ចាប់ពីពេលដែលកុមារត្រូវបានរកឃើញ រហូតដល់តុលាការបានជ្រើសតាំងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ ប្រធានមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត គឺអ្នកអាណាព្យាបាលសម្រាប់អនីតិជនបណ្តោះអាសន្ន។

### គ. កុមារកំព្រាដែលមាន អ្នកមានអំណាចមេបាក្រលំបាក

ប្រសិនបើអ្នកអនុវត្តអំណាចមេបាដែលស្ថិតនៅក្នុងស្ថានភាពលំបាកបំផុត បានធ្វើការទុកដាក់កុមារឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកនោះ ត្រូវបញ្ចូលឈ្មោះកុមារទៅក្នុងសៀវភៅកត់ត្រាកុមារ ដែលត្រូវបានធ្វើការទុកដាក់ឲ្យនៅក្រោមការថែទាំរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច [១២] ។

### (២) ឪពុកម្តាយបង្កើត ឬអាណាព្យាបាល

#### ក) ការយល់ព្រមរបស់ឪពុកម្តាយបង្កើត ឬអាណាព្យាបាល

---

[37] មាត្រា ១០៨ នៃច្បាប់ស្តីពីស្មុំកូនអន្តរប្រទេស ២០០៩

ដំណើរការសុំកូនអន្តរប្រទេសអាចប្រព្រឹត្តទៅបាន លុះត្រាតែមានការយល់ព្រមច្បាស់លាស់និងពិតប្រាកដពីឪពុកម្តាយ ឬសាច់ញាតិនិងអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារតាមករណីដូចជាៈ

- ក្នុងករណីកុមារមានចំណងបុត្តភាពជាមួយឪពុកនិងម្តាយការយល់ព្រមត្រូវផ្តល់ដោយឪពុកនិងម្តាយរបស់កុមារនោះ។
- ក្នុងករណីដែលឪពុក ឬម្តាយណាមួយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវបានដកហូតអំណាចមេបាការយល់ព្រមត្រូវបានផ្តល់ដោយឪពុក ឬម្តាយតែម្ខាងដែលមានអំណាចមេបាជាការគ្រប់គ្រាន់។
- ក្នុងករណីដែលឪពុកម្តាយរបស់កុមារបានស្លាប់ ឬស្ថិតក្នុងស្ថានភាពដែលមិនអាចបង្ហាញឆន្ទៈបាន ឬត្រូវដកហូតអំណាចមេបាការយល់ព្រមត្រូវផ្តល់ដោយអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ។

ការយល់ព្រមខាងលើត្រូវផ្តល់ឲ្យដោយសេរី និងច្បាស់លាស់ដោយមិនត្រូវមានវិការៈណាមួយដូចជាការបង្ខិតបង្ខំការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្តល់ ឬការសន្យាផ្តល់ប្រាក់រង្វាន់សំណង ផលប្រយោជន៍ណាមួយ និងដោយបានដឹងច្បាស់ពីផលវិបាកនៃការយល់ព្រមរបស់ខ្លួនចំពោះសុំកូនអន្តរប្រទេស។

ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវទទួលនូវការពិគ្រោះយោបល់ពីភ្នាក់ងារសង្គមកិច្ចមានសមត្ថភាព ដែលបានទទួលការអនុញ្ញាតជាមុននឹងផ្តល់ការយល់ព្រម។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវប្រាប់យ៉ាងច្បាស់លាស់ដល់អ្នកដែលត្រូវផ្តល់ការយល់ព្រមអំពីអានុភាពនៃការយល់ព្រមការបញ្ចប់នូវបុត្តភាព ព្រមទាំងបញ្ចប់សិទ្ធិ និងកាតព្វកិច្ចជាអ្នកមានអំណាចមេបា ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជន និងត្រូវប្រាប់អំពីបែបបទនិងរយៈពេលបញ្ឈប់ការយល់ព្រមនេះ។ ភ្នាក់ងារសង្គមកិច្ចមានសមត្ថកិច្ចត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរអំពីការសម្ភាសន៍របស់ខ្លួនជាមួយឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតជនរបស់កុមារ។

ទោះក្នុងករណីណាក៏ដោយ ការយល់ព្រមត្រូវផ្តល់សក្ខីកម្មជាលាយលក្ខណ៍អក្សរនៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងទីលំនៅរបស់ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនជាការយល់ព្រមដោយសេរី និងច្បាស់លាស់ និងដោយមិនត្រូវមានវិការៈណាមួយឡើយ។ ម្យ៉ាងទៀតមេឃុំ ចៅសង្កាត់ត្រូវចាត់ចែងធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ

អំពីការយល់ព្រមនេះ ក្រោយពីបានពិនិត្យថាភ្នាក់ងារសង្គមកិច្ចបានពិគ្រោះយោបល់ជាមុនជាឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារនោះ និងបានគ្រប់យ៉ាងត្រឹមត្រូវអំពីអានុភាពនៃការយល់ព្រមនេះ។

### ខ) ការបញ្ឈប់ការយល់ព្រមលើសុំកូន

ឪពុកម្តាយ ឬឪពុក ឬម្តាយឬអ្នកអាណាព្យាបាលសម្រាប់អនីតជនរបស់កុមារ អាចបញ្ឈប់ការយល់ព្រមរបស់ខ្លួនវិញបាន រហូតដល់មានសេចក្តីសម្រេចរបស់តុលាការ ស្តីអំពីការសុំកូនជាស្ថាពរ។ ការបញ្ឈប់ការយល់ព្រមឪពុកម្តាយ ឬឪពុក ឬម្តាយឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននេះ អាចត្រូវធ្វើជាលាយលក្ខណ៍អក្សរ ឬដោយផ្ទាល់មាត់នៅចំពោះមុខមេឃុំ ឬចៅសង្កាត់ខាងលំនៅដ្ឋានរបស់ខ្លួន។ មេឃុំ ឬចៅសង្កាត់ខាងលំនៅដ្ឋានរបស់ឪពុកម្តាយឬឪពុកឬម្តាយឬអ្នកអាណាព្យាបាលសម្រាប់អនីតជនកុមារ ត្រូវធ្វើកំណត់ហេតុអំពីកិច្ចការនេះ ហើយត្រូវបញ្ជូនកំណត់ហេតុនេះទៅមន្ទីរទទួលបន្ទុកវិស័យសង្គមកិច្ចរាជធានី/ខេត្ត ប្រធានមណ្ឌលកុមារកំព្រាដែលពាក់ព័ន្ធ និងត្រូវប្រគល់កំណត់ហេតុចម្លងដែលមានសេចក្តីបញ្ជាក់នៅលើកំណត់ហេតុនោះទៅឲ្យឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជននោះ។

### គ) ការដកហូតអំណាចមេបាពីការយល់ព្រមដោយតុលាការ

ករណីឪពុកម្តាយ ឬឪពុកឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារបដិសេធការយល់ព្រម ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចប្តឹងឲ្យតុលាការប្រកាសការដកហូតអំណាចមេបាពី ឪពុកម្តាយ ឬឪពុក ឬម្តាយ ឬបញ្ឈប់អ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ និងជ្រើសតាំងអ្នកអាណាព្យាបាលថ្មីសម្រាប់អនីតិជនរបស់កុមារ ក្នុងករណីពិនិត្យឃើញថាការបដិសេធ ឬបញ្ឈប់ការយល់ព្រមនេះ ធ្វើឲ្យប៉ះពាល់ផលប្រយោជន៍របស់កុមារ ឬបណ្តាលឲ្យប៉ះពាល់ដល់សុខភាព ឬសីលធម៌របស់កុមារ។ ពាក្យបណ្តឹងទៅតុលាការត្រូវធ្វើក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការក្រោយពីឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារបដិសេធ ឬបញ្ឈប់ការយល់ព្រមរបស់ខ្លួន។

(៣) អំពីអ្នកសុំ

ចំពោះជនបរទេសដែលអនុញ្ញាតឲ្យសុំទារក ឬកុមារកំព្រាយកទៅចិញ្ចឹមជាកូននៅឯបរទេសបាន ត្រូវឆ្លើយតបនឹងលក្ខខណ្ឌមួយចំនួនដែលមានដូចតទៅៈ

- អ្នកសុំជាប្តីប្រពន្ធត្រូវមានអាយុចាប់ពី៣០(សាមសិប)ឆ្នាំ និងមានអាយុលើសកូនសុំយ៉ាងតិច២២(ម្ភៃពីរ)ឆ្នាំ និងយ៉ាងច្រើនបំផុត៤៥(សែសិបប្រាំ)ឆ្នាំ គិតត្រឹមកាលបរិច្ឆេទដាក់ពាក្យសុំកូន។
- ក្នុងករណីដែលអ្នកសុំមិនបានបំពេញតាមចំណុចដូចបានរៀបរាប់ខាងលើ ហើយក្នុងករណីសុំកូនឆ្លើយតបនឹងឧត្តមប្រយោជន៍របស់កុមារ សុំកូនអាចអនុញ្ញាតឲ្យបានក្នុងស្ថានភាពដូចតទៅៈ
  - … អ្នកសុំមានដើមកំណើតជាជនជាតិខ្មែរ សុំកុមារដែលជាសាច់ញាតិរបស់ខ្លួន ឬអ្នកសុំជាសហព័ទ្ធដែលសុំកូននៃសហព័ទ្ធម្ខាងទៀត។
  - … អ្នកសុំអាចសុំកុមារដែលត្រូវការថែទាំពិសេស ឬស្ថានភាពផ្សេងទៀតដែលបម្រើឧត្តមប្រយោជន៍របស់កុមារ។
- ក្នុងករណីអ្នកសុំមានប្តី ឬប្រពន្ធ ការសុំកូនត្រូវធ្វើដោយសហព័ទ្ធទាំងពីររួមគ្នា លើកលែងតែករណីដែលសហព័ទ្ធណាម្ខាងសុំបង្កើតនៃសហព័ទ្ធម្ខាងទៀត។
- ច្បាប់ជាតិរបស់អ្នកសុំនីមួយៗ និងច្បាប់ប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំបានទទួលស្គាល់ និងអនុញ្ញាតនូវបុត្តភាពនៃសុំកូនពេញលេញ។
- ប្រទេសនៃសញ្ជាតិ ឬប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍នៃអ្នកសុំ ត្រូវតែជាប្រទេសមានទំនាក់ទំនងការទូតជាមួយព្រះរាជាណាចក្រកម្ពុជា។
- អ្នកសុំត្រូវមានលក្ខណៈសម្បត្តិ និងលក្ខខណ្ឌជាសារវន្តសុំកូនស្របទៅតាមច្បាប់ប្រទេសនៃលំនៅដ្ឋានអចិន្ត្រៃយ៍។
- អ្នកសុំត្រូវតែជាជនពុំធ្លាប់ត្រូវបានផ្តន្ទាទោស ឬត្រូវកំពុងបានប្តឹងអំពីកំហុសទាក់ទងទៅនឹងកិរិយាមាយាទ ឬការប្រព្រឹត្តបទឧក្រិដ្ឋ ឬមជ្ឈិមណាមួយនៅក្នុងប្រទេសនៃសញ្ជាតិរបស់ខ្លួន ឬប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ ឬក្នុងប្រទេសណាមួយដែលខ្លួនបានស្នាក់នៅចុងក្រោយ។
- អ្នកសុំត្រូវតែជាអ្នកមានសមត្ថភាពផ្តល់ការថែទាំសមស្រប និងការគាំទ្រយ៉ាងចាំបាច់ដល់កូន។

- អ្នកសុំត្រូវបានអនុញ្ញាតឲ្យសុំកូនបានលុះត្រាតែអ្នកសុំកូនគ្មានកូន ឬមានកូនតែម្នាក់នៅក្នុងបន្ទុក។ អ្នកសុំកូនកូនអាចសុំបានតែម្នាក់ប៉ុណ្ណោះ លើកលែងតែកុមារដែលមានបងប្អូនបង្កើតអាចអនុញ្ញាតឲ្យសុំច្រើននាក់បាន។

## *ផ្នែកទី៣: ទណ្ឌកម្ម*

ច្បាប់ស្តីពីការសុំកូនអន្តរប្រទេស ត្រូវបានបង្កើតឡើងមិនត្រឹមតែកំណត់អំពីគោលការណ៍លក្ខខណ្ឌនីតិវិធី ទម្រង់បែបបទ និងអានុភាពនៃសុំកូនអន្តរប្រទេសនោះទេ ច្បាប់នេះព្រមទាំងបានកំណត់អំពីការផ្តន្ទាទោសដល់រាល់បទល្មើសពាក់ព័ន្ធទៅនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស ដែលត្រូវផ្តន្ទាទោសដោយយោងតាមច្បាប់ និងច្បាប់បញ្ញត្តិជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ជាគោលការណ៍នៅគ្រប់ករណី នៃបទល្មើសទាំងឡាយនឹងទទួលរងនូវទណ្ឌកម្មព្រហ្មទណ្ឌ ឬទណ្ឌកម្មរដ្ឋប្បវេណី ឬអាចទទួលរងទណ្ឌកម្មព្រហ្មទណ្ឌផង និងសំណងរដ្ឋប្បវេណីផង ឬការប្រកាសនូវទោសផ្សេងៗទៀត អាស្រ័យទៅតាមស្ថានទម្ងន់ទោសរបស់ជនល្មើស។

- ទណ្ឌកម្មព្រហ្មទណ្ឌ: ទោសដាក់ពន្ធនាគារ
- ទណ្ឌកម្មរដ្ឋប្បវេណី: ទោសពិន័យជាប្រាក់
- ទោសដាក់ពន្ធនាគារផង និង ទោសពិន័យជាប្រាក់ ហើយរួមទាំងការប្រកាសនូវទោស[38] បន្ថែម គឺ:
    - … ការដកសិទ្ធិខ្លះជាពលរដ្ឋ សម្រាប់រយៈពេលយ៉ាងច្រើន៥ឆ្នាំ។
    - … ការបិទផ្សាយសេចក្តីសម្រេចផ្តន្ទាទោសសម្រាប់រយៈពេលយ៉ាងច្រើន២ខែ[39]។
    - … ការផ្សាយសេចក្តីសម្រេចផ្តន្ទាទោសនៅក្នុងទំព័រសារព័ត៌មាន។
    - … ការផ្សាយសចក្តីសម្រេចផ្តន្ទាសទោស តាមគ្រប់មធ្យោបាយទូរគមនាគមន៍សោតទស្សន៍ សម្រាប់រយៈពេល៨ថ្ងៃយ៉ាងច្រើន។

---

[38] មាត្រា ៥៣ នៃក្រមព្រហ្មទណ្ឌ ២០០៩

[39] មាត្រា ៦៨ នៃក្រមព្រហ្មទណ្ឌ ២០០៩

ដោយមិនទាន់គិតដល់ទោសប្បញ្ញត្តិដែលមានចែងនៅក្នុងច្បាប់ជាធរមាន ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចព្យួរ ឬដកហូតការទទួលស្គាល់ ឬបដិសេធការទទួលស្គាល់ ទីភ្នាក់ងារសុំកូនអន្តរប្រទេសសាជាថ្មី ប្រសិនបើមានភស្តុតាងបង្ហាញឲ្យឃើញថា ទីភ្នាក់ងារសុំកូនអន្តរប្រទេសជាប់ពាក់ព័ន្ធនឹងអំពើណាមួយដូចតទៅៈ

- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃ ញុះញង់ដោយផ្ទាល់ឲ្យឪពុកម្ដាយ ឬ ឪពុក ឬ ម្ដាយ បោះបង់ទារកដែលកើតហើយ ឬដែលនឹងកើត ដើម្បីឲ្យនឹងប្រគល់កូនតាមរយៈ សុំកូន អន្តរប្រទេស។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងឪពុកម្ដាយ ឬឪពុក ឬម្ដាយដែលចង់បោះបង់កូន ដែលកើតមកហើយ ឬដែលនឹងកើត។
- អំពើប្រព្រឹត្តក្នុងគោលដៅចង់បានកម្រៃធ្វើជាអន្តរការីរវាងប្ដីប្រពន្ធដែលចង់សុំកូនយកមកចិញ្ចឹមតាមរយៈសុំកូនអន្តរប្រទេស និងស្ត្រីយល់ព្រមពពោះដើម្បីនឹងប្រគល់កូននោះទៅឲ្យអ្នកសុំ។
- អំពើក្លែងបន្លំ ឬសមគំនិតក្លែងបន្លំស្ថានភាពលំបាកបំផុត ដើម្បីទទួលបានការយល់ព្រមពីឪពុកម្ដាយបង្កើតឬឪពុកបង្កើត ឬម្ដាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារ។
- អំពើរៀបចំឲ្យមានការយល់ព្រមរបស់ឪពុកម្ដាយ ឬឪពុក ឬម្ដាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនកុមារដោយការបង្ខិតបង្ខំ ការគំរាមកំហែង ការឆបោក ឬការបញ្ចុះបញ្ចូលតាមរយៈការផ្ដល់ ឬសន្យាផ្ដល់ប្រាក់ រង្វាន់ សំណង ឬផលប្រយោជន៍ណាមួយ។
- ការបញ្ចេញសំណុំឯកសារ និង កំណត់ហេតុទាំងអស់ ឬមួយផ្នែកទាក់ទងនឹងករណីសុំកូនអន្តរប្រទេសជាក់លាក់ណាមួយ ដោយគ្មានការអនុញ្ញាតពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ឬតុលាការមានសមត្ថកិច្ច។
- ការបង្កាប់ ឬការទទួលដោយផ្ទាល់ ឬដោយប្រយោលនូវថ្នូរប្រាក់កាស ទំនិញ ឬសេវាដោះដូរនឹងការបម្រុងទុកកុមារណាមួយសម្រាប់សុំកូន។
- ការផ្ដល់ប្រាក់កាស ទំនិញ ឬសេវាទៅឲ្យមន្ត្រី ឬអ្នកណាមួយនៃរដ្ឋបាលសុំកូនអន្តរប្រទេស ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច អាជ្ញាធរកណ្ដាលទទួលខុសត្រូវកិច្ចការ

សុំកូនអន្តរប្រទេស ឬមន្ត្រីពាក់ព័ន្ធផ្សេងទៀត ដើម្បីឲ្យផ្តល់នូវសិទ្ធិជាអាទិភាពនៅក្នុងនីតិវិធីសុំកូនអន្តរប្រទេសដល់អ្នកសុំ។

- ការផ្សាយពាណិជ្ជកម្ម ឬការបោះពុម្ពផ្សាយនូវអត្តសញ្ញាណ ឬរូបថតរបស់កុមារណាមួយដែលជាកម្មវត្ថុសុំកូន ក្នុងគោលបំណងបញ្ចុះបញ្ចូលបុគ្គលណាមួយឲ្យដាក់ពាក្យសុំកូន។
- ការចាត់តាំង ឬចាត់តាំងអ្នកតំណាងណាមួយ ដោយមិនមានការឯកភាពពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។
- ការចូលរួមក្នុងការរៀបចំការផ្គូរផ្គង ឬការទាក់ទងគ្នារវាងអ្នកសុំឪពុកម្តាយបង្កើត ឬឪពុកបង្កើត ឬម្តាយបង្កើត ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារក្នុងគោលបំណងកំណត់ទុកជាមុននូវកុមារណាមួយដែលនឹងត្រូវសុំ។
- ការរំលោភបំពានដល់បទប្បញ្ញត្តិនៃច្បាប់នេះ បទដ្ឋានអប្បបរមា នៃការថែទាំជំនួសចំពោះកុមារ និងបទប្បញ្ញត្តិផ្សេងទៀតជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងព្រះរាជាណាចក្រកម្ពុជា ត្រូវតែជាភ្នាក់ងារដែលបានទទួលការអនុញ្ញាត ពីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចនៃព្រះរាជាណាចក្រកម្ពុជា និងពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល ព្រមទាំងមានទិសដៅមិនស្វែងរកផលចំណេញ និងបានបំពេញនូវលក្ខខណ្ឌដែលមានចែងក្នុងបទប្បញ្ញត្តិច្បាប់ដែលទាក់ទងនឹងនីតិបុគ្គលមិនយកចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណៈនៃទីភ្នាក់ងារនេះ។ បើមិនដូច្នោះទេ ទីភ្នាក់ងារនោះត្រូវពិន័យជាអន្តរការណ៍ជាប្រាក់ពី១.000.000(មួយលាន)រៀលទៅ១0.000.000(ដប់លាន)រៀល។ ការដាក់ពិន័យអន្តរការណ៍ ជាសមត្ថកិច្ចរបស់ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ប្រាក់ពិន័យអន្តរការណ៍នេះត្រូវបង់ចូលក្នុងមូលនិធិសម្រាប់ទ្រទ្រង់វិស័យសុខុមាលភាពកុមារ។

ក្នុងករណីទីភ្នាក់ងារ មិនព្រមបង់ប្រាក់ពិន័យអន្តរការណ៍នេះទេ ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអាចបញ្ជូលសុំណុំរឿងទៅតុលាការ។

## ២- អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូនអន្តរប្រទេស

**អាជ្ញាធរមានសមត្ថកិច្ចក្នុងកិច្ចការសុំកូន៖** សុំកូនអន្តរប្រទេសត្រូវបានធ្វើឡើង តាមរយៈ អាជ្ញាធរមានសមត្ថកិច្ច ដូចជា អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស រដ្ឋបាលសុំកូនអន្តរប្រទេស និងទីភ្នាក់ងារសុំកូនអន្តរប្រទេស។

### ផ្នែកទី១ -អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

នៅក្នុងផ្នែកនេះយើងនឹងសិក្សាអំពីតួនាទី ភារកិច្ចរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរ។

#### កថាខណ្ឌទី១ : តួនាទីភារកិច្ចរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស

ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច បំពេញតួនាទីជាអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសដែលមានតួនាទី និងភារកិច្ចដូចតទៅ៖

- រៀបចំ និងត្រួតពិនិត្យគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាក់ទងនឹងការសម្រេច លើកិច្ចការសុំកូនអន្តរប្រទេស។
- ធ្វើសហប្រតិបត្តិការ និងធ្វើការសម្របសម្រួលលើការប្រាស្រ័យទាក់ទងគ្នានឹងកិច្ចការសុំកូនជាមួយក្រសួង ស្ថាប័ន និង ទីភ្នាក់ងារដែលមានសមត្ថកិច្ចដោះស្រាយសុំកូនអន្តរប្រទេសនៅក្នុងព្រះរាជាណាចក្រកម្ពុជា និងជាមួយអាជ្ញាធរកណ្តាល និងអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេសនៃប្រទេសទទួល។
- ចាត់វិធានការសមស្របដើម្បីបង្ការ និងទប់ស្កាត់ការទទួលផលកម្រៃផ្នែកហិរញ្ញវត្ថុដោយមិនសមស្រប ឬផលចំណេញផ្សេងៗទៀតដែលទាក់ទងទៅនឹងសុំកូនអន្តរប្រទេស។
- រៀបចំបណ្តុះបណ្តាលជំនាញកិច្ចការសុំកូនអន្តរប្រទេសដល់មន្ត្រីពាក់ព័ន្ធ
- ពិនិត្យលើសំណើររបស់រដ្ឋបាលសុំកូនអន្តរប្រទេស ទាក់ទងនឹងករណីសុំកូនអន្តរប្រទេសនីមួយៗតាមការចាំបាច់។
- ធ្វើអធិការកិច្ចលើកិច្ចការសុំកូនអន្តរប្រទេស គ្មានជនណាអាចរារាំង បង្អាក់ ឬជ្រៀតជ្រែកក្នុងការអធិការកិច្ចដែលបានធ្វើឡើងត្រឹមត្រូវតាមច្បាប់នោះឡើយ
- បំពេញភារកិច្ចផ្សេងៗទៀត ដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចយល់ថាចាំបាច់សម្រាប់អនុវត្តកិច្ចការសុំកូនអន្តរប្រទេស ដោយអនុលោមទៅតាមច្បាប់ និងបទបញ្ញាជាធរមាននៃព្រះរាជាណាចក្រកម្ពុជា។

### កថាខណ្ឌទី២:គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស

គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេស មានការិយាល័យលេខាធិការដ្ឋានមួយជាជំនួយការ

#### ក. សមាសភាព

គណៈកម្មាធិការកណ្តាលសុំកូនអន្តរប្រទេសមានសមាសភាពដូចតទៅ[40]៖

- រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និង យុវនីតិសម្បទា ជាប្រធាន
- រដ្ឋលេខាធិការក្រសួងស.អ.យទទួលបន្ទុកវិស័យសុខុមាលភាពកុមារ ជាអនុប្រធាន
- មន្ត្រីជំនាញលើវិស័យសុខុមាលភាពកុមាររបស់ក្រសួងស.អ.យ ជាសមាជិក
- អនុរដ្ឋលេខាធិការក្រសួងស.អ.យទទួលបន្ទុកវិស័យសុខុមាលភាពកុមារ ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានបច្ចេកទេស ជាសមាជិក
- អគ្គនាយកនៃអគ្គនាយកដ្ឋានកិច្ចការរដ្ឋបាល និង ហិរញ្ញវត្ថុ ជាសមាជិក
- អគ្គាធិការនៃអគ្គលេខាធិការដ្ឋាន ជាសមាជិក
- អគ្គលេខាធិការ ក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីកុមារ ជាសមាជិក
- អ្នកជំនាញការជាតិ លើវិស័យសុខុមាលភាពកុមារ ជាសមាជិក
- ប្រធាននាយកដ្ឋាន សហប្រតិបត្តិការអន្តរជាតិ ជាសមាជិក
- ប្រធាននាយកដ្ឋានសុខុមាលភាពកុមារ និង ជាប្រធានរដ្ឋបាលសុំកូនអន្តរប្រទេសជាអគ្គលេខាធិការ

**ខ នីតិវិធីធ្វើការ៖** នីតិវិធីធ្វើការរបស់គណៈកម្មាធិការអាជ្ញាកណ្តាលសុំកូនអន្តរប្រទេសរួមមាន៖

- បើកសម័យប្រជុំ ដើម្បីផ្តល់យោបល់លើករណីសុំកូននីមួយៗ និងពិនិត្យផ្តល់យោបល់ក្នុងការរៀបចំត្រួតពិនិត្យក្នុងការអនុវត្តគោលនយោបាយ ច្បាប់ បទបញ្ញា និងនីតិវិធីទាំងឡាយដែលទាក់ទងនឹងសុំកូនអន្តរប្រទេស និងអនុវត្តកិច្ចការដូចមានចែងខាងលើ។

[40] ប្រកាសរបស់ក្រសួងស.អ.យ លេខៈ៣០៩សអយ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១០

បើយល់ថាចាំបាច់ គណៈកម្មាធិការនេះក៏អាចអញ្ជើញតំណាងក្រសួង ស្ថាប័ន អង្គការ និង ជនពាក់ព័ន្ធដទៃទៀតឲ្យចូលរួមផ្តល់យោបល់ផងដែរ។

- រាល់កិច្ចប្រជុំត្រូវដឹកនាំដោយប្រធាន ឬប្រធានស្តីទីនៃគណៈកម្មាធិការ។ រីឯការសម្រេចដែលយកជាការបាន លុះត្រាតែមានការចូលរួមយ៉ាងតិច ៥០%+១ ។ ក្នុងករណីមានសម្លេងស្មើគ្នា នោះសម្លេងប្រធាននឹងមានឧត្តមានុភាព។

- ត្រូវអនុវត្តបទបញ្ជាផ្ទៃក្នុងរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាធរមាន និងត្រូវកំណត់បន្ថែមនូវបទបញ្ជាផ្ទៃក្នុងរបៀបធ្វើការងារ ព្រមទាំងទំនាក់ទំនងដឹកនាំរបស់អាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ចំពោះរដ្ឋបាលសុំកូនអន្តរប្រទេសកាតព្វកិច្ចរបស់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេសចំពោះមុខក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

### ផ្នែកទី ២ - រដ្ឋបាលសុំកូនអន្តរប្រទេស

ការរៀបចំ និងការប្រព្រឹត្តទៅរបស់រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

#### ១) សមាសភាព

រដ្ឋបាលសុំកូនអន្តរប្រទេសដឹកនាំដោយប្រធានមួយរូប ហើយបែងចែកជាបីផ្នែក ដែលផ្នែកនីមួយៗមានប្រធាន ០១ រូប មានឋានៈស្មើប្រធានការិយាល័យ និងអនុប្រធានមួយចំនួនជាជំនួយការដែលមានឋានៈស្មើនឹងអនុប្រធានការិយាល័យ។

សមាសភាពថ្នាក់ដឹកនាំ និងមន្ត្រីគ្រប់ជាន់ថ្នាក់នៃរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវមានលក្ខណៈសម្បត្តិ ០៥ យ៉ាងគឺ ៖

- មានបទពិសោធន៍ការងារសង្គមកិច្ច ជាពិសេសការងារសុំកូន។
- បានទទួលការបណ្តុះបណ្តាលវគ្គសេវាសង្គមកិច្ច តាមកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- មានបទពិសោធន៍ផ្នែកច្បាប់។
- មានសមត្ថភាពកុំព្យូទ័រ និងភាសាបរទេស ជាពិសេសភាសា អង់គ្លេស និងបារាំង។
- ជាមន្ត្រីក្របខណ្ឌរដ្ឋរបស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។

## ២) តួនាទី ភារកិច្ចរបស់រដ្ឋបាលសុំកូនអន្តរប្រទេស

រដ្ឋបាលសុំកូនអន្តរប្រទេស[41]សរសេរកាត់ថា **រ.ស.អ** ជាភាសាអង់គ្លេស International Country Adoption Administration « I.C.A.A » ជាសេនាធិការឲ្យសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។ រដ្ឋបាលសុំកូនអន្តរប្រទេសជាអង្គភាពចំណុះនាយកដ្ឋានសុខុមាលភាពកុមារដឹកនាំដោយប្រធានមួយរូបដែលជាប្រធាននាយកដ្ឋានសុខុមាលភាពកុមារ និងមានអនុ-ប្រធានមួយចំនួនជាជំនួយការ។

រដ្ឋបាលសុំកូនអន្តរប្រទេសមានតួនាទី និង ភារកិច្ចដូចតទៅៈ

- រៀបចំថែរក្សាបញ្ជីសម្ងាត់ និងសំណុំឯកសារកុមារដែលមានលក្ខណសម្បត្តិសមស្របសម្រាប់សុំកូនអន្តរប្រទេស។

- វាយតម្លៃស្ថានភាពកុមារទាំងអស់ដែលមានឈ្មោះក្នុងបញ្ជីសម្ងាត់ ដើម្បីកំណត់ទម្រង់នៃការចិញ្ចឹមថែទាំសមស្របបំផុត និងធានាថាកុមារទាំងនោះទទួលបានការថែទាំតាមតម្រូវការ។

- ប្រឹងប្រែងឲ្យអស់លទ្ធភាពសម្រាប់ការថែទាំជាអចិន្ត្រៃយ៍ នៅតាមគ្រួសារក្នុងប្រទេសសិនមុននឹងដាក់ឲ្យដំណើរការសុំកូនអន្តរប្រទេស។

- ទទួលពាក្យ និងចាត់ការពាក្យសុំ ព្រមទាំងឯកសារពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសរបស់អ្នកសុំ។

- ផ្គូរផ្គងអ្នកសុំជាមួយកុមារដែលមានលក្ខណៈសម្បត្តិសមស្រប។

- ផ្តល់ដំណឹងដល់អាជ្ញាធរកណ្តាល ឬ អាជ្ញាធរមានសមត្ថកិច្ច ឬ ទីភ្នាក់ងារសុំកូនអន្តរប្រទេសទទួលការអនុញ្ញាតពីប្រទេសអំពីនីតិវិធីសុំកូន និងការអភិវឌ្ឍនៃករណីសុំកូន។

- សម្របសម្រួលការប្រគល់កុមារទៅឲ្យអ្នកសុំ និង ការរៀបចំឯកសារដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសរបស់អ្នកសុំ។

- ផ្តល់សេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារអ្នកសុំ និងគ្រួសារបង្កើតតាមការចាំបាច់។

- ផ្តល់មតិយោបល់ជូនអាជ្ញាធរកណ្តាលសុំកូនប្រទេសអំពីការផ្តល់ ឬការដកហូតការអនុញ្ញាតឲ្យទីភ្នាក់ងារប្រតិបត្តិការសុំកូនអន្តរប្រទសនៅកម្ពុជា។

---

[41] ប្រកាសរបស់ក្រសួងស.អ.យ លេខៈ៣០៩សអយ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ ២០១០

- ធ្វើអធិការកិច្ច និងលើកសំណើសុំការសម្រេចពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស ដើម្បីចាត់វិធានការព្រមាន ឬ ផាកពិន័យចំពោះបុគ្គល ឬ អង្គភាពប្រព្រឹត្តល្មើសច្បាប់ពាក់ព័ន្ធនឹងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។

- ពិនិត្យផ្តល់យោបល់គ្រប់សំណុំលិខិត នៃសុំកូនអន្តរប្រទេសមុននឹងដាក់ជូនប្រធានគណៈកម្មាធិការ និងរដ្ឋមន្ត្រីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីមានមូលដ្ឋានសម្រេច។

- ដោះស្រាយការងាររដ្ឋបាល និងផ្គត់ផ្គង់ដល់គណៈកម្មាធិការអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស។

- បំពេញភារកិច្ចផ្សេងៗទៀតស្របតាមច្បាប់បញ្ញត្តិជាធរមាន និងតាមការប្រគល់អំណាចពីអាជ្ញាធរកណ្តាលសុំកូនអន្តរប្រទេស និងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិ-សម្បទា។

### ផ្នែកទី៣ - អំពីទីភ្នាក់ងារអន្តរប្រទេស

ដើម្បីក្លាយជាទីភ្នាក់ងារសុំកូនអន្តរប្រទេសបាន ទីភ្នាក់ងារនោះត្រូវតែបំពេញឲ្យបាននូវលក្ខណៈសម្បត្តិដូចមានចែងនៅក្នុងច្បាប់ស្តីសុំកូនអន្តរប្រទេស ហើយបន្ទាប់មកត្រូវដាក់ពាក្យសុំធ្វើប្រតិបត្តិការជាទីភ្នាក់ងារសុំកូនអន្តរប្រទេស និងចុងបញ្ចប់ប្រតិបត្តិការរបស់ទីភ្នាក់ងារសុំកូននឹងត្រូវកំណត់ដោយអាជ្ញាធរមានសមត្ថកិច្ច ។

#### ១: លក្ខណសម្បត្តិរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេស

ដើម្បីសុំការអនុញ្ញាត ធ្វើប្រតិបត្តិការសុំកូនអន្តរប្រទេសពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានៅកម្ពុជានោះទីភ្នាក់ងារនេះត្រូវមានលក្ខណៈសម្បត្តិដូចតទៅៈ

- មានការអនុញ្ញាតពីស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួល។
- ទីភ្នាក់ងារនីមួយៗ ត្រូវបានតាមបទប្បញ្ញត្តិជាធរមានរបស់ព្រះរាជាណាចក្រ-កម្ពុជាទាក់ទងនីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញ សមាគម ឬអង្គការមិនមែនរដ្ឋាភិបាល ឬបទប្បញ្ញត្តិពាក់ព័ន្ធផ្សេងទៀតទាក់ទងនឹងលក្ខណសម្បត្តិនៃទីភ្នាក់ងារនោះ។
- ទីភ្នាក់ងារដែលធ្វើប្រតិបត្តិការក្នុងដំណើរការសុំកូនអន្តរប្រទេស នៅក្នុងប្រទេសកម្ពុជាមិនត្រូវបានអនុញ្ញាតឲ្យបើក ឬយកមណ្ឌលកុមារកំព្រាធ្វើជាប្រភពដើម្បីផ្គត់ផ្គង់ទារក និងកុមារកំព្រាឡើយ។

- ទីភ្នាក់ងារសុំកូនត្រូវចុះកិច្ចសន្យាស្តីពីប្រតិបត្តិការសុំកូនអន្តរប្រទេស និងបំពេញបែបបទផ្សេងទៀតតាមការកំណត់របស់ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា។
- មានអ្នកដឹកនាំ និងបុគ្គលិកដែលមានសមត្ថភាពប្រកបដោយគុណធម៌ និងសីលធម៌ ព្រមទាំងបានទទួលការបណ្តុះបណ្តាល និងមានបទពិសោធន៍ការងារក្នុងវិស័យសុំកូនអន្តរប្រទេស។

## ២: ការដាក់ពាក្យសុំធ្វើប្រតិបត្តិការជាទីភ្នាក់ងារសុំកូនអន្តរប្រទេស

**ក. ការដាក់ពាក្យសុំ៖** ពាក្យសុំការអនុញ្ញាតធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេសនៅព្រះរាជាណាចក្រកម្ពុជាដែលដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវភ្ជាប់មកជាមួយនូវសំណុំឯកសារដូចខាងក្រោម ៖

- ពាក្យសុំការអនុញ្ញាតដោយមានការយល់ព្រម និងទទួលស្គាល់ពីក្រសួងការបរទេសកម្ពុជា
- ឯកសារសង្ខេបអំពីប្រវត្តិ និងសកម្មភាពរបស់ទីភ្នាក់ងារ
- ច្បាប់ចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ ពីប្រទេសទទួលរបស់ខ្លួនស្តីពី "ការអនុញ្ញាតឲ្យបើកទីភ្នាក់ងារនេះ"
- ច្បាប់ចម្លងដែលមានបញ្ជាក់ភាពត្រឹមត្រូវ ពីប្រទេសទទួលរបស់ខ្លួនស្តីពី "លិខិតចុះបញ្ជីទាក់ទងនីតិបុគ្គលមិនស្វែងរកប្រាក់ចំណេញ"
- លក្ខន្តិកៈ និងបទបញ្ជាផ្ទៃក្នុងរបស់ទីភ្នាក់ងារ
- ជីវប្រវត្តិសង្ខេបនិងរូបថតរបស់សមាជិកក្រុមប្រឹក្សាភិបាល ឬគណៈគ្រប់គ្រង
- ជីវប្រវត្តិសង្ខេបរបស់បុគ្គលដែលបានទទួលការអនុញ្ញាតិឲ្យធ្វើជាអ្នកតំណាងទីភ្នាក់ងារចំពោះកិច្ចការសុំកូនអន្តរប្រទេស។ អ្នកតំណាងទាំងនោះមិនត្រូវឲ្យមានលើសពីពីរនាក់ ហើយក៏មិនមែនជានាយក នាយករង ឬបុគ្គលិកនៃមណ្ឌលកុមារកំព្រានៅក្នុងព្រះរាជាណាចក្រកម្ពុជាណាមួយឡើយ។

- ឯកសារនានាដែលបញ្ជាក់ថា អ្នកតំណាងទីភ្នាក់ងារគ្មានជាប់ឈ្មោះក្នុងបញ្ជីថ្កោលទោសនៅប្រទេសដើមរបស់ខ្លួន និងក្នុងប្រទេសក្រោយដែលខ្លួនរស់នៅប្រទេសខុសគ្នា។
- កិច្ចព្រមព្រៀងទ្វេភាគី ស្តីពីកិច្ចសហប្រតិបត្តិការ លើវិស័យសុំកូនអន្តរប្រទេស រវាងប្រទេសកម្ពុជាជាមួយនឹងប្រទេសរបស់ទីភ្នាក់ងារសុំកូនអន្តរប្រទេសក្នុងករណីដែលប្រទេសនោះមិនមែនរដ្ឋជាភាគី នៃអនុសញ្ញាក្រុងឡាអេស្តីពីការការពារកុមារ និងសហប្រតិបត្តិការទាក់ទងនឹងសុំកូនអន្តរប្រទេសទេ។
- របាយការណ៍ហរិញ្ញវត្ថុដែលបានធ្វើសវនកម្មដោយឯករាជ្យរួច និងកិច្ចព្រមព្រៀងផ្តល់ជំនួយមនុស្សធម៌ ឬការជួយឧបត្ថម្ភដល់កុមារកំព្រានានានៅក្នុងព្រះរាជាណាចក្រកម្ពុជា។
- តម្រូវការផ្សេងដែលក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាយល់ថាចាំបាច់ដូចមានចែងនៅក្នុងនីតិវិធីទាក់ទងនឹងការផ្តល់ការអនុញ្ញាត។

**ខ. នីតិវិធីរដ្ឋបាល៖** ពាក្យសុំមួយច្បាប់និងសំណុំលិខិតនៃការសុំអនុញ្ញាត (ច្បាប់ចម្លង) ធ្វើជាទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានចេញដោយអាជ្ញាធរមានសមត្ថកិច្ចរបស់ខ្លួនត្រូវផ្ញើជូនស្ថានទូត ឬស្ថានតំណាងប្រចាំនៅកម្ពុជា។

ក្នុងរយៈពេលហុកសិបថ្ងៃបន្ទាប់ពីបានទទួលពាក្យអនុញ្ញាត ធ្វើជាភ្នាក់ងារសុំកូនអន្តរប្រទេសក្រសួងសង្គមកិច្ចអតីតយុទ្ធជន និងយុវនីតិសម្បទាត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅទីភ្នាក់ងារវិញ អំពីការសម្រេចជាផ្លូវការរបស់ខ្លួន។ បើបដិសេធនោះក្រសួងក៏ត្រូវបញ្ជាក់អំពីមូលហេតុឲ្យបានច្បាស់លាស់ដែរ។

មានតែអ្នកតំណាងដែលមានឈ្មោះក្នុងសំណុំឯកសារពាក្យសុំតែប៉ុណ្ណោះ ដែលមានសិទ្ធិធ្វើជាអ្នកតំណាងទីភ្នាក់ងារនៅក្នុងដំណើរការសុំកូនអន្តរប្រទេស។ ក្នុងករណីអ្នកតំណាងដែលបានទទួលការអនុញ្ញាត ត្រូវជំនួសដោយអ្នកផ្សេងនោះ ទីភ្នាក់ងារត្រូវដាក់ពាក្យសុំទៅក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាដើម្បីសុំការអនុញ្ញាតសារជាថ្មី។

ការអនុញ្ញាតឲ្យធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេស មានរយៈពេលតែពីរឆ្នាំប៉ុណ្ណោះ ហើយអាចឲ្យបន្តបានដរាបណាសេវារបស់ទីភ្នាក់ងារស្មុំកូនអន្តរប្រទេសនៅតែចាំបាច់ ដោយភ្នាក់ងារនេះត្រូវដាក់ពាក្យសុំជាថ្មី។

### ៣: អាជ្ញាធរផ្តល់ការអនុញ្ញាតឲ្យទីភ្នាក់ងារស្មុំកូនអន្តរប្រទេស

ចំនួនទីភ្នាក់ងារមកពីប្រទេសទទួលនីមួយៗ ដែលអនុញ្ញាតឲ្យផ្តល់សេវានេះនៅកម្ពុជា ត្រូវបានកំណត់ដោយកិច្ចព្រមព្រៀងរួមគ្នារវាងក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាជាមួយនឹងអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលនោះ។

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទានិងស្ថាប័នមានសមត្ថកិច្ចនៃប្រទេសទទួលគឺជាអាជ្ញាធរមានសមត្ថកិច្ច ក្នុងការអនុញ្ញាតឲ្យទីភ្នាក់ងារស្មុំកូនអន្តរប្រទេសមានសិទ្ធិធ្វើប្រតិបត្តិការស្មុំកូនអន្តរប្រទេសនៅក្នុងប្រទេសកម្ពុជា។

### ៣: នីតិវិធីស្មុំកូនអន្តរប្រទេស

នីតិវិធីស្មុំកូនអន្តរប្រទេសមាន ០៣ ដំណាក់កាលគឺ នីតិវិធីរដ្ឋបាលនៃការស្មុំកូនអន្តរប្រទេស(**ផ្នែកទី១**) នីតិវិធីតុលាការ (**ផ្នែកទី២**) និងចំណាត់ការក្រោយពីបញ្ចប់នីតិវិធីស្មុំកូនអន្តរប្រទេស (**ផ្នែកទី៣**)។

### ផ្នែកទី១ -នីតិវិធីរដ្ឋបាលនៃការស្មុំកូនអន្តរប្រទេស

នីតិវិធីរដ្ឋបាលនៃការស្មុំកូនអន្តរប្រទេសគឺ គ្រប់គ្រងឯកសាររបស់កុមារមានលក្ខណៈសម្បត្តិសម្រាប់ស្មុំកូនអន្តរប្រទេស (**កថាខណ្ឌទី១**) ហើយពិនិត្យលើពាក្យសុំកូន(**កថាខណ្ឌទី២**) បន្ទាប់មករៀបចំផ្គូរផ្គងលក្ខណៈសម្បត្តិរវាងកុមារ និងអ្នកស្មុំ(**កថាខណ្ឌទី៣**) ព្រមទាំងចាត់ចែងពីសោហ៊ុយលើការស្មុំកូន (**កថាខណ្ឌទី៤**)។

### កថាខណ្ឌទី១:ការគ្រប់គ្រងសំណុំឯកសាររបស់រដ្ឋបាលស្មុំកូនអន្តរប្រទេស

រដ្ឋបាលស្មុំកូនអន្តរប្រទេស ត្រូវរៀបចំសំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារម្នាក់ៗ ដែលមានលក្ខណៈសម្បត្តិសម្រាប់ស្មុំកូនអន្តរប្រទេសរួមមាន ព័ត៌មានចាំបាច់អំពីអត្តសញ្ញាណរបស់កុមារភាពអាចសុំជាកូនចិញ្ចឹម សាវតារជាតិរបស់កុមារ បរិយាកាសសង្គមរបស់កុមារ ប្រវត្តិគ្រួសាររបស់កុមារ ប្រវត្តិសុខភាពរបស់កុមារ ប្រវត្តិសុខភាពគ្រួសាររបស់កុមារ និងសេចក្តីពិសេសណាមួយរបស់កុមារ។

ក្នុងករណីកុមារត្រូវបានបោះបង់ចោល រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថា ការខិតខំប្រឹងប្រែងដើម្បីស្វះស្វែងរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារត្រូវបានធ្វើរួចហើយ។

រដ្ឋបាលសុំកូនអន្តរប្រទេសក៏ត្រូវធានាផងដែរ រាល់ការយល់ព្រមចាំបាច់ទាំងឡាយត្រូវបានធ្វើឡើងស្របតាមបទបញ្ញត្តិនានានៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ។

សំណុំឯកសារផ្ទាល់ខ្លួនរបស់កុមារ រាប់បញ្ចូលទាំងភស្តុតាងបង្ហាញពីការយល់ព្រម និង/ឬការខិតខំប្រឹងប្រែងដើម្បីរកឪពុកម្តាយ ឬឪពុក ឬម្តាយ ឬសាច់ញាតិ ឬអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារផងដែរ[42]។

### កថាខណ្ឌទី ២ : ការពិនិត្យពាក្យសុំ

ការពិនិត្យពាក្យសុំរបស់អ្នកសុំកូន គឺពិនិត្យទៅលើឯកសារមួយចំនួនដែលមានដូចជាៈ

- ភស្តុតាងដែលបញ្ជាក់ថា អាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់ខ្លួន ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារកូនអន្តរប្រទេសនៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ចាត់ទុកថា អ្នកសុំមានលក្ខណៈសម្បត្តិ និងមានភាពសមស្របសម្រាប់សុំកូនដោយផ្អែកទៅលើការវាយតំលៃ លើជីវប្រវត្តិផ្ទាល់ខ្លួននិងប្រវត្តិគ្រួសារ ប្រវត្តិសុខភាព បរិយាកាសគ្រួសារ មូលហេតុសុំកូន និងលទ្ធភាពនៃការទទួលបន្ទុករ៉ាប់រងចំពោះសុំកូនអន្តរប្រទេស។
- ព័ត៌មានចាំបាច់ទាក់ទងនឹងការឆ្លើយតបទៅនឹងលក្ខខណ្ឌនានា ដែលមានចែងនៅក្នុងច្បាប់ស្តីពីសុំកូនអន្តរប្រទេស។
- ព័ត៌មានទាក់ទងនឹងអត្តសញ្ញាណរបស់អ្នកសុំ ដែលក្នុងនោះរួមមានឯកសារទាក់ទងនឹងអត្រានុកូលដ្ឋាន។
- ព័ត៌មានទាក់ទងនឹងលក្ខណៈសម្បត្តិផ្សេងៗរបស់កុមារ ដែលអ្នកសុំអាចនឹងមានលក្ខណសម្បត្តិថែទាំបាន។
- ភស្តុតាងទទួលបានពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចនៃប្រទេសទទួលដែលបញ្ជាក់ថា នៅពេលពាក្យសុំកូនរបស់ខ្លួនត្រូវបានយល់ព្រមហើយ កូនសុំនោះត្រូវបានអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍ក្នុងប្រទេសទទួល។

[42] មាត្រា ២២ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

រាល់ឯកសារទាំងអស់ដែលបានរៀបចំខាងលើ ត្រូវបញ្ជូនមកក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ តាមរយៈអាជ្ញាធរកណ្តាល ស្ថានទូត ឬស្ថានតំណាងនៃប្រទេសទទួលប្រចាំនូវព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជាក់ភាពត្រឹមត្រូវនៃឯកសារទាំងនោះ។ ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិត្រូវពិនិត្យផ្តល់យោបល់ និងត្រូវបញ្ជូនឯកសារសុំកូនអន្តរប្រទេសទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេល១៥(ដប់ប្រាំ)ថ្ងៃនៃថ្ងៃធ្វើការគិតពីថ្ងៃទទួលពាក្យសុំពីក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវឆ្លើយតបជាលាយលក្ខណ៍អក្សរទៅអ្នកសុំ តាមរយៈអាជ្ញាធរកណ្តាលនៃប្រទេសដើមរបស់អ្នកសុំ ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬតាមទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍ ដោយបញ្ជាក់ថាខ្លួនបានទទួលពាក្យសុំកូន។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវពិនិត្យសំណុំលិខិតសុំកូនក្នុងរយៈពេល៦០(ហុកសិប)ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីថ្ងៃដែលក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចទទួលលិខិតសុំកូនដូចបានរៀបរាប់ខាងលើនេះ។ ក្នុងករណីសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ហើយរដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជាក់ថាអ្នកសុំបានបំពេញលក្ខខណ្ឌត្រឹមត្រូវតាមច្បាប់នេះហើយ។

ក្នុងករណីដែលសំណុំលិខិតដាក់ជូនរដ្ឋបាលសុំកូនអន្តរប្រទេសមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនដំណឹងទៅឲ្យអ្នកសុំជាលាយលក្ខណ៍អក្សរអំពីឯកសារដែលនៅខ្វះ ឬមិនទាន់ត្រឹមត្រូវ តាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលបានទទួលការអនុញ្ញាតនៃប្រទេសទទួល។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យសំណុំលិខិតសុំកូន ក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការ បន្ទាប់ពីទទួលបានឯកសារដែលខ្វះ ឬកែតម្រូវរួច។

ក្នុងករណីអ្នកសុំខកខានមិនបានផ្តល់ឯកសារដែលនៅខ្វះ ឬមិនទាន់ត្រឹមត្រូវក្នុងរយៈពេល ៦០(ហុកសិប)ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃរដ្ឋបាលសុំកូនអន្តរប្រទេសជូនដំណឹងអំពីឯកសារដែលមិនទាន់គ្រប់គ្រាន់ ឬមិនទាន់ត្រឹមត្រូវ នោះពាក្យសុំកូនអន្តរប្រទេសត្រូវទុកជាមោឃៈ។ ក្នុងករណីបដិសេធពាក្យសុំ ក្រសួងទទួលបន្ទុកសង្គមកិច្ច ត្រូវមានបញ្ជាក់អំពីមូលហេតុជាលាយលក្ខណ៍អក្សរ។

### កថាខណ្ឌទី៣: ការផ្ទៀងផ្ទាត់លក្ខណសម្បត្តិរវាងកុមារ និងអ្នកសុំ

ប្រសិនបើសំណុំលិខិតមានលក្ខណៈគ្រប់គ្រាន់ និងត្រឹមត្រូវ ហើយអ្នកសុំបានបំពេញទៅតាមលក្ខខណ្ឌនៃច្បាប់នេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិនិត្យពិចារណាទៅលើសំណុំឯកសាររបស់កុមារទាំងឡាយ ដែលមានលក្ខណៈសម្បត្តិសម្រាប់សុំកូនអន្តរប្រទេសបាន និងត្រូវផ្ទៀងផ្ទាត់អំពីលក្ខណៈសម្បត្តិរបស់អ្នកសុំណា ដែលត្រូវគ្នាល្អបំផុតនឹងលក្ខណៈសម្បត្តិរបស់កុមារ។

ក្នុងការផ្ទៀងផ្ទាត់ ដោយគិតគូរដល់ឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាឲ្យបានសមស្របទៅលើអត្ថប្រយោជន៍ នៃការបន្តឲ្យមានការបីបាច់ថែរក្សាកុមារដូចពេលមានកន្លងមក ព្រមទាំងពិចារណាទៅលើសាវតាសង្គម ជាតិពន្ធ សាសនា និងវប្បធម៌របស់កុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវផ្ញើសំណុំឯកសាររបស់កុមារដែលត្រូវបានផ្ទៀងផ្ទាត់ រួមទាំងភស្តុតាងដែលបង្ហាញថា រាល់ការចាំបាច់នានា ត្រូវបានទទួលរួចហើយ និងមូលហេតុដែលខ្លួនកំណត់ទុកដាក់កុមារ ជាមួយអ្នកសុំនោះទៅអាជ្ញាកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីពិនិត្យ និងបញ្ជូនទៅអ្នកសុំ ដោយមិនចាំបាច់ជូនដំណឹងអំពី អត្តសញ្ញាណឪពុកម្តាយ ឬឪពុក ឬម្តាយ ឬអ្នកអាណាព្យាបាលសម្រាប់អនីតិជនរបស់កុមារឡើយ លើកលែងតែក្នុងករណីសុំកូនដោយសាច់ញ ាតិ។

### ក. ការឆ្លើយតបរបស់អ្នកសុំ

អ្នកសុំត្រូវឆ្លើយតបទៅរដ្ឋបាលសុំកូនអន្តរប្រទេសជាលាយលក្ខណ៍អក្សរ អំពីការយល់ព្រមទទួលយកកុមារដែលបានផ្ទៀងផ្ទាត់ឲ្យតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសប្រទេសទទួល។

- ក្នុងករណីអ្នកសុំមិនបានឆ្លើយតប មករដ្ឋបាលសុំកូនអន្តរប្រទេស ក្នុងរយៈពេលហុកសិបថ្ងៃនៃថ្ងៃធ្វើការទេ អាចចាត់ទុកបានថាអ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន ហើយរដ្ឋបាលសុំកូនអន្តរប្រទេសអាចផ្ទៀងផ្ទាត់កុមារនោះឲ្យទៅអ្នកសុំផ្សេងទៀតបាន។ ចំណែកឯប្រាក់ចំណាយ សោហ៊ុយ និងវិភាគទានទាក់ទងនឹងការដាក់ពាក្យសុំមិនត្រូវបានបង្វិលឲ្យវិញឡើយ។

- ក្នុងករណីអ្នកសុំបានឆ្លើយតបថា មិនទទួលយកកុមារដែលផ្គូរផ្គង ឲ្យខ្លួននៅលើកទីមួយទេ អ្នកសុំនោះអាចស្នើសុំឲ្យរដ្ឋបាលសុំកូនអន្តរប្រទេស ផ្គូរផ្គងកុមារជាលើកទីពីរបាន ប៉ុន្តែមិនអនុញ្ញាតឲ្យធ្វើជាលើកទីបីឡើយ។

- ចំពោះអ្នកសុំដែលមិនបានឆ្លើយតបក្នុងរយៈពេលកំណត់ហុកសិបថ្ងៃខាងលើនោះទេ អ្នកសុំនោះអាចដាក់ពាក្យសុំកូនសារជាថ្មីស្របតាមនីតិវិធីនៃច្បាប់ស្តីពីសុំកូនអន្តរប្រទេសនេះ ប៉ុន្តែក្នុងការសម្រេចអំពីការសុំឲ្យមានការផ្គូរផ្គងសាជាថ្មី ឬការទទួលពាក្យសុំកូនសារជាថ្មីនេះ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវពិចារណាអំពីមូលហេតុដែលអ្នកសុំខកខានមិនបានឆ្លើយតប ឬឆ្លើយតបថាមិនមានបំណងសុំកុមារដែលបានផ្គូរផ្គងពីលើកមុននាពេលកន្លងមក។

### ខ. ការរៀបចំឲ្យមានការជួបគ្នារវាងកុមារ និងអ្នកសុំ

បន្ទាប់ពីអ្នកសុំបានបញ្ជាក់ការយល់ព្រមរបស់ខ្លួនហើយ អាជ្ញាធរកណ្តាលនៃប្រទេសទទួលបានយល់ព្រមលើការសម្រេចនេះ រដ្ឋបាលសុំកូនអន្តរប្រទេសតាមរយៈអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលត្រូវរៀបចំឲ្យមានការជួបគ្នារវាងអ្នកសុំ និងកុមារដែលបានផ្គូរផ្គងរួចហើយ។

ការជួបគ្នានេះ ត្រូវប្រព្រឹត្តទៅតាមកាលបរិច្ឆេទមួយសមស្របសម្រាប់អ្នកសុំ និងរដ្ឋបាលសុំកូនអន្តរប្រទេស និងត្រូវមានវត្តមានមន្ត្រីសង្គមកិច្ចមានសមត្ថកិច្ចមួយរូបផង។ ការជួបគ្នានេះត្រូវធ្វើក្នុងរយៈពេលហុកសិបថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីកាលបរិច្ឆេទទទួលការយល់ព្រមពីអ្នកសុំ។ ក្នុងករណីអ្នកសុំមិនមកក្នុងរយៈពេលដូចបានកំណត់នេះដោយគ្មានមូលហេតុត្រឹមត្រូវ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវចាត់ទុកថា អ្នកសុំបានបញ្ឈប់ពាក្យសុំរបស់ខ្លួន។

មុនការជួបគ្នារវាងអ្នកសុំ និងកុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធ្វើសម្ភាសន៍អ្នកសុំ និងធានាថាអ្នកសុំ និងកុមារត្រូវបានរៀបចំខ្លួនជាស្រេចតាមរយៈការពិគ្រោះយោបល់ ការផ្លាស់ប្តូរព័ត៌មានការផ្លាស់ប្តូររូបថត និងវិធានការចាំបាច់ផ្សេងទៀតដើម្បីការជួបគ្នានេះ។

ករណីមានសហព័ទ្ធ បើសហព័ទ្ធណាម្ខាងមិនអាចមកបាន សហព័ទ្ធនោះត្រូវធ្វើលិខិតប្រគល់សិទ្ធិឲ្យទៅសហព័ទ្ធម្ខាងទៀតធ្វើជាតំណាងរបស់ខ្លួន ដើម្បីធ្វើសកម្មភាពក្នុងការសុំកូននោះ។ លិខិតប្រគល់សិទ្ធិត្រូវមានការបញ្ជាក់ពីអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចរបស់ប្រទេសទទួល។

### គ. ការសាកសួរយោបល់របស់កុមារ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសាកសួរយោបល់របស់កុមារដែលអាចដឹងខុសត្រូវ បានព្រមទាំងប្រាប់កុមារឲ្យបានដឹងអំពីអានុភាពដែលអាចកើតចេញពីសុំកូននេះ ហើយត្រូវស្តាប់កុមារបញ្ចេញមតិយោបល់របស់ខ្លួន ដោយគ្មានវត្តមានរបស់ភាគីផ្សេងទៀតឡើយ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវយល់ដឹងឲ្យបានច្បាស់អំពីទស្សនៈកុមារលើរាល់បញ្ហាដែលពាក់ព័ន្ធដល់សុំកូនក្នុងនោះមានជាអាទិ៍ ការជ្រើសរើសអ្នកសុំ ហើយមតិយោបល់របស់កុមារត្រូវយកទៅគិតគូរពិចារណាដោយផ្អែកទៅតាមវ័យ និងកម្រិតយល់ដឹងរបស់កុមារ។ សំអាងស្តីពីការយល់ព្រមរបស់កុមារត្រូវធ្វើជាលាយលក្ខណ៍អក្សរ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវធ្វើកំណត់ហេតុជាលាយលក្ខណ៍អក្សរ អំពីការសម្ភាសន៍ និងការជួបគ្នាខាងលើនេះ។

### ឃ. ការសម្រេចលើការសុំកូន

ក្នុងករណីរដ្ឋបាលសុំកូនអន្តរប្រទេសពិនិត្យឃើញថា អ្នកសុំ និងកុមារ បំពេញបាននូវលក្ខណៈវិនិច្ឆ័យ និងលក្ខណៈសម្រាប់សុំកូនអន្តរប្រទេស ហើយសុំកូននេះពិតជាបានឆ្លើយតបទៅនឹងឧត្តមប្រយោជន៍របស់កុមារ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវផ្តល់មតិយោបល់ជាវិជ្ជមានក្នុងរយៈពេលប្រាំពីរថ្ងៃនៃថ្ងៃធ្វើការបន្ទាប់ពីការជួបគ្នារវាងអ្នកសុំ និងកុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវដាក់សំណុំលិខិតទាំងនេះ ជូនរដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីធ្វើការពិនិត្យ និងផ្តល់អនុសាន៍លើដំណើរការសុំកូន។

ក្រោយពីទទួលអនុសាន៍លើដំណើរការសុំកូនពីរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ចអ្នកសុំត្រូវសហការជាមួយអាជ្ញាធរកណ្តាលឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួលដាក់ពាក្យសុំកូន ដែលបានផ្ទៀងផ្ទាត់រួចតាមរយៈរដ្ឋបាលសុំកូនអន្តរប្រទេស ទៅសាលាដំបូងរាជធានីភ្នំពេញដើម្បីសុំដីកាសម្រេចសុំកូន។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវបញ្ជូនពាក្យសុំកូនទៅសាលារាជធានីភ្នំពេញ ដោយភ្ជាប់មកជាមួយនូវសំណុំឯកសាររបស់កុមារ និងអ្នកសុំ ព្រមទាំងអនុសាន៍របស់រដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ក្នុងរយៈពេលប្រាំពីរថ្ងៃនៃថ្ងៃធ្វើការ គិតពីថ្ងៃបរិច្ឆេទទទួលពាក្យសុំ។ ឯកសារទាំងអស់ត្រូវបកប្រែជាភាសាខ្មែរ និងមានការបញ្ជាក់ពីរដ្ឋបាលសុំកូនអន្តរប្រទេស។

ក្នុងករណីអ្នកសុំមិនបានដាក់ពាក្យសុំក្នុងរយៈពេលហុកសិបថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីទទួលអនុសាន៍របស់រដ្ឋមន្ត្រីទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវចាត់ទុកថាអ្នកសុំនោះបានបញ្ឈប់ពាក្យសុំរបស់ខ្លួន[43]។

### កថាខណ្ឌទី៤: សោហ៊ុយលើការសុំកូន

#### ក.សោហ៊ុយចំពោះរដ្ឋបាលសុំកូនអន្តរប្រទេស

អ្នកសុំត្រូវបង់ប្រាក់ចំណាយ សោហ៊ុយ និងវិភាគទាននានា សម្រាប់ជួយឧបត្ថម្ភជម្រើសនានានៃការថែទាំជំនួស និងការជួយឧបត្ថម្ភទូទៅដល់មណ្ឌលកុមារកំព្រារបស់រដ្ឋទូទាំងប្រទេស និងកម្រៃសេវាចាំបាច់ផ្សេងៗទៀតទាក់ទងនឹងសុំកូនអន្តរប្រទេសដែលនឹងកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងរដ្ឋមន្ត្រីក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ក្រៅពីនេះមិនត្រូវយកប្រាក់សោហ៊ុយសុំកូនពីអ្នកសុំ ឬទីភ្នាក់ងាររបស់អ្នកសុំកូន។ មិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន បង់ថ្លៃសោហ៊ុយសុំកូនទៅតាមកុមារម្នាក់ៗ ឬ ទៅតាមសោហ៊ុយសុំកូនមួយ ដែលនឹងត្រូវបញ្ជូនទៅឲ្យមណ្ឌលកុមារកំព្រាណាមួយ ឬមិនអនុញ្ញាតឲ្យអ្នកសុំកូន ឬទីភ្នាក់ងាររបស់អ្នកសុំកូន ធ្វើការផ្តល់សោហ៊ុយ អំណោយ ឬការទូទាត់ទោះបីក្នុងរូបភាពណាក៏ដោយ ទៅឲ្យមណ្ឌលកុមារកំព្រាដែលកុមារកំព្រានៅទីនោះត្រូវបានសុំយកទៅចិញ្ចឹម ឬទៅឲ្យបុគ្គលិក នាយក ឬសមាជិកនៃគណៈគ្រប់គ្រង ទោះជាដោយផ្ទាល់ ឬដោយប្រយោលក្តី។

#### ខ.សោហ៊ុយដែលកំណត់ដោយតុលាការ

អ្នកសុំត្រូវបង់ប្រាក់សរុបចំនួន១.០០០.០០០(មួយលាន)រៀល ដើម្បីទ្រទ្រង់សោហ៊ុយដាក់ពាក្យសុំ ការពិនិត្យភស្តុតាង ការចេញដីកាសម្រេច ការបញ្ជូនឯកសារ ការផ្សព្វផ្សាយសេចក្តីជូនដំណឹង ការស្រាវជ្រាវអង្គហេតុ និងសកម្មភាពខាងនីតិវិធីផ្សេងៗទៀត ដែលទាក់ទងនឹងកិច្ចការសុំកូនអន្តរប្រទេស។ តុលាការត្រូវបង្គាប់ឲ្យអ្នកសុំបង់ចំនួនទឹកប្រាក់នោះជាមុន។ ក្នុងករណីដែលសោហ៊ុយចាំបាច់ដែលបានកំណត់ខាងលើនេះ លើសពី ១.០០០.០០០(មួយលាន)រៀល តុលាការអាចកំណត់ចំនួនសោហ៊ុយបន្ថែមបង្គាប់ឲ្យអ្នកសុំបង់សោហ៊ុយបន្ថែមនោះមុនរីឯចំនួនទឹកប្រាក់នេះមិនបង្វិលជូនវិញទេ[44]។

---

[43] មាត្រា ៣៣ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

[44] មាត្រា ៣៥ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស ២០០៩

### ផ្នែកទី២ -នីតិវិធីតុលាការ

មានតែសាលាដំបូងរាជធានីភ្នំពេញមួយប៉ុណ្ណោះ ដែលមានយុត្តាធិការលើរឿងក្ដីសុំកូនអន្តរប្រទេស។ ហើយតុលាការនេះត្រូវយកបទប្បញ្ញត្តិស្ដីពី នីតិវិធីរឿងក្ដីរដ្ឋប្បវេណី ដែលមិនមែនជាបណ្ដឹងមកអនុវត្តចំពោះនីតិវិធីតុលាការ ទាក់ទងនឹងសុំកូនអន្តរប្រទេសលើកលែងតែមានបទប្បញ្ញត្តិពិសេស ដូចមានចែងក្នុងច្បាប់នេះ។ដូចនេះនីតិវិធីរបស់តុលាការគឺពិនិត្យទៅលើសំណុំឯកសារ **(កថាខណ្ឌទី១)** និងធ្វើការសម្រេចសេចក្ដី **(កថាខណ្ឌទី២)** ព្រមទាំងកំណត់អំពីការប្ដឹងទាស់**(កថាខណ្ឌទី៣)**។

#### ១) ការពិនិត្យទៅលើសំណុំឯកសារ

ជាគោលការណ៍សំណុំឯកសារ និងរបាយការណ៍ដាក់ជូនតុលាការ ដោយក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ត្រូវសន្មតជាភស្ដុតាងនៃអង្គហេតុពិត ទាក់ទងនឹងលក្ខណសម្បត្តិសុំកូនរបស់កុមារ និងភាពសមស្របសម្រាប់សុំកូនរបស់អ្នកសុំ លើកលែងតែមានភស្ដុតាងផ្ទុយបញ្ជាក់។

ក្នុងករណីចាំបាច់ តុលាការអាចបង្គាប់ឲ្យអ្នកតំណាងរដ្ឋបាលសុំកូនអន្តរប្រទេសមកបំភ្លឺបន្ថែមអំពីលទ្ធផលនៃការស្រាវជ្រាវ និង អនុសាសន៍របស់រដ្ឋមន្ត្រី ក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ទាក់ទងនឹងករណីសុំកូនអន្តរប្រទេស រួមទាំងឯកសាររបាយការណ៍ និងភស្ដុតាង ជាឯកសារពាក់ព័ន្ធ ដែលគាំទ្រលទ្ធផលនៃការស្រាវជ្រាវខាងលើ។

តុលាការត្រូវត្រួតពិនិត្យចំពោះឯកសារពាក់ព័ន្ធនឹងសុំកូនអន្តរប្រទេសដូចជា ៖

- លក្ខណៈវិនិច្ឆ័យឬលក្ខខណ្ឌទាំងអស់នៃសុំកូនអន្តរប្រទេសត្រូវបានបំពេញ
- ការពិគ្រោះយោបល់ជាចាំបាច់នានាត្រូវបានធ្វើមុននឹងផ្ដល់ការយល់ព្រម
- ការយល់ព្រមចាំបាច់នានាត្រូវបានផ្ដល់ ដោយគោរពខ្លឹមសារនៃច្បាប់ស្ដីពីសុំកូនអន្តរប្រទេស
- មានការពិចារណាត្រឹមត្រូវលើ គ្រប់លទ្ធភាពក្នុងការទុកដាក់កុមារនៅ ក្នុងព្រះរាជាណាចក្រកម្ពុជា
- អាជ្ញាធរកណ្ដាល ឬអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសដែលបានទទួលការអនុញ្ញាតនៃ ប្រទេសទទួលយល់ព្រមលើការទុកដាក់កុមារ
- កុមារនឹងត្រូវអនុញ្ញាតឲ្យចូលទៅរស់នៅជាអចិន្ត្រៃយ៍នៅក្នុងប្រទេសទទួល

- ស្នើសុំកូនអន្តរប្រទេសនេះពិតជាមានឧត្តមភាពសម្រាប់កុមារ[45]។

## ២) ការសម្រេចសេចក្តីរបស់តុលាការ

តុលាការសម្រេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងស្នើសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់ការទាមទារហេតុផលដោយផ្ទាល់មាត់ឡើយ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកស្នើសុំ ឬអ្នកតំណាង ឬមានអ្នកមានអំណាចមេបាម្ខាង ឬទាំងពីរ ឬអាណាព្យាបាលសម្រាប់អនីតិជនសម្រាប់កុមារ អ្នកតំណាងទីភ្នាក់ងារស្នើសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ[46]។

តុលាការត្រូវលើកយកសំណុំរឿងស្នើសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល៣០(សាបសិប)ថ្ងៃ នៃថ្ងៃធ្វើការបន្ទាប់ពីបានទទួលពាក្យស្នើសុំកូន។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកស្នើសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។ ដីកាសម្រេចនេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់ក្នុងមាត្រា៤០ នៃច្បាប់ស្តីពីស្នើសុំកូនអន្តរប្រទេស។

ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពររហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹងជំទាស់នោះ[47]។

## ៣) នីតិវិធីនៃការប្តឹងជំទាស់

### ក. រយៈពេលនៃការប្តឹងជំទាស់

ក្នុងករណីដែលបុគ្គល អាចប្តឹងជំទាស់ជាជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើបណ្តឹង ជំទាស់ត្រូវធ្វើឡើងក្នុងអំឡុងពេល ១៥ (ដប់ប្រាំ) ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃដែលខ្លួនទទួលបានការជូនដំណឹងអំពីដីកាសម្រេច។

[45] មាត្រា ៣៧ នៃច្បាប់ស្តីពីស្នើសុំកូនអន្តរប្រទេស ២០០៩

[46] មាត្រា ៣៨ នៃច្បាប់ស្តីពីស្នើសុំកូនអន្តរប្រទេស ២០០៩

[47] មាត្រា ៣៩ នៃច្បាប់ស្តីពីស្នើសុំកូនអន្តរប្រទេស ២០០៩

ក្នុងករណីបុគ្គលអាចប្តឹងជំទាស់ មិនមែនជនដែលត្រូវទទួលបានការជូនដំណឹងអំពីដីកាសម្រេចខាងលើ បណ្តឹងជំទាស់ត្រូវធ្វើឡើងអំឡុងពេល ១៥ (ដប់ប្រាំ)ថ្ងៃ នៃថ្ងៃធ្វើការគិតពីថ្ងៃដែលអ្នកសុំបានទទួលការជូនដំណឹងអំពីដីកាសម្រេច។ អំឡុងពេល១៥ថ្ងៃ មិនអាចពន្យាពេលបានឡើយនៅក្នុងករណីទាំងពីរខាងលើនេះ។

### ខ. សមត្ថកិច្ចយុត្តាធិការលើបណ្តឹងជំទាស់

បុគ្គលមានសិទ្ធិ ឬផលប្រយោជន៍របស់ខ្លួន ត្រូវបានបំពេញដោយដីកាសម្រេច លើពាក្យសុំកូនអន្តរប្រទេស អាចប្តឹងជំទាស់ទៅសាលាឧទ្ធរណ៍ចំពោះដីកាសម្រេចនោះបាន។ សាលាឧទ្ធរណ៍ត្រូវលើកយកពាក្យបណ្តឹងជំទាស់នោះមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល៣០(សាមសិប)ថ្ងៃ នៃថ្ងៃធ្វើការមិនអាចប្តឹងជំទាស់ទៀតបានឡើយ។

## ផ្នែកទី ៣ - ចំណាត់ការក្រោយពីបញ្ចប់នីតិវិធីសុំកូនអន្តរប្រទេស

រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវជូនដំណឹងអំពីការប្រព្រឹត្តទៅ នៃនីតិវិធីសុំកូន វិធានការដែលអាជ្ញាធរមានសមត្ថកិច្ចបានចាត់ការ និងការវិវត្តន៍នៃការសុំកូននៅគ្រប់ដំណាក់កាលរបស់នីតិវិធីសុំកូនឲ្យបានទៀងទាត់ទៅតាមអ្នកសុំតាមរយៈអាជ្ញាធរមានសមត្ថកិច្ច ឬទីភ្នាក់ងារសុំកូនអន្តរប្រទេស ដែលទទួលបានការអនុញ្ញាតក្រោយពីដីកាសម្រេចរបស់តុលាការចូលជាស្ថាពរ ក្រសួងទទួលបន្ទុកកិច្ចការសង្គម ត្រូវជូនដំណឹងទៅក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិអំពីការសម្រេចនេះ។ នៅពេលដែលនីតិវិធីសុំកូនអន្តរប្រទេសត្រូវបានបញ្ចប់ក្រសួងទទួលបន្ទុកកិច្ចការសង្គមត្រូវចេញលិខិតបញ្ជាក់ជាផ្លូវការ។ ដូចនេះក្រោយពីនីតិវិធីសុំកូនត្រូវបានបញ្ចប់ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវរៀបចំកុមារប្រគល់ទៅឲ្យអ្នកសុំតាមដានស្ថានភាពកុមារ និងការរៀបចំទុកដាក់សំណុំឯកសារសុំកូន ហើយក្នុងករណីកូនសុំទទួលបាននីតិភាពរដ្ឋបាលសុំកូនអន្តរប្រទេសត្រូវអនុញ្ញាតឲ្យកូនសុំនោះ មើលសំណុំលិខិតសុំកូនរបស់ខ្លួនបាន។

### កថាខណ្ឌទី១: ការប្រគល់កុមារឲ្យអ្នកសុំ

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវរៀបចំប្រគល់កុមារ និង លិខិតបញ្ជាក់ស្តីពីការប្រគល់កូនជាផ្លូវការទៅអ្នកសុំ។ រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវជួយសម្រួលជាមួយអាជ្ញាធរមានសមត្ថកិច្ចក្នុងការរៀបចំ និងផ្តល់នូវលិខិតឆ្លងដែន ទិដ្ឋាការ និងឯកសារចាំបាច់នានាដើម្បីឲ្យកុមារធ្វើដំណើរចូលទៅប្រទេសលំនៅដ្ឋានអចិន្ត្រៃយ៍របស់អ្នកសុំ។

ការធ្វើដំណើររបស់កុមារទៅកាន់ប្រទេសទទួល ត្រូវអមដំណើរដោយអ្នកសុំ។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានាថាការផ្ទេរត្រូវធានាថា កុមារទៅកាន់ប្រទេសទទួលប្រព្រឹត្តទៅក្នុងកាលៈទេសៈមានសុវត្ថិភាព ដោយមានការគិតគូរដល់សេចក្តីត្រូវការនានារបស់កុមារ។

រដ្ឋបាលសុំកូនអន្តរប្រទេស ត្រូវសម្របសម្រួលជាមួយអាជ្ញាធរកណ្តាល ឬអាជ្ញាធរមានសមត្ថកិច្ចទទួលបន្ទុកសុំកូនអន្តរប្រទេស ឬទីភ្នាក់ងារសុំកូនអន្តរប្រទេសនៃប្រទេសទទួល ដើម្បីផ្តល់ ឬសម្របសម្រួលសេវាក្រោយសុំកូនសមស្របដល់កុមារ គ្រួសារចិញ្ចឹម និង គ្រួសារបង្កើតតាមការចាំបាច់។

## កថាខណ្ឌទី២: ការតាមដានស្ថានភាពកុមារ

តុលាការសម្រេចក្តីអំពីរឿងក្តីដែលទាក់ទងនឹងសុំកូនអន្តរប្រទេស ដោយពុំចាំបាច់ឆ្លងកាត់ការទាមទារហេតុផលដោយផ្ទាល់មាត់ឡើយ។

ក្នុងករណីមានភាពចាំបាច់ដាច់ខាតត្រូវបំភ្លឺអង្គហេតុពាក់ព័ន្ធ តុលាការអាចអញ្ជើញអ្នកសុំ ឬអ្នកតំណាង ឬមានអ្នកមានអំណាចមេបាម្ខាង ឬទាំងពីរ ឬអាណាព្យាបាលសម្រាប់អនីតិជនសម្រាប់កុមារ អ្នកតំណាងទីភ្នាក់ងារសុំកូនអន្តរប្រទេសពាក់ព័ន្ធ និងសាក្សីផ្សេងទៀត ដើម្បីផ្តល់ភស្តុតាងជាលាយលក្ខណ៍អក្សរ ឬ ដោយផ្ទាល់មាត់ទាក់ទងនឹងអត្ថិភាព ឬនត្ថិភាពនៃអង្គហេតុ។

តុលាការត្រូវលើកយកសំណុំរឿងសុំកូនអន្តរប្រទេសមកវិនិច្ឆ័យ និងចេញដីកាសម្រេចក្នុងរយៈពេល៣០ថ្ងៃនៃថ្ងៃធ្វើការ បន្ទាប់ពីបានទទួលពាក្យសុំកូន។ តុលាការត្រូវបញ្ជូនដីកាសម្រេចនេះទៅអ្នកសុំ អ្នកតំណាងដែលច្បាប់បានកំណត់របស់កូន និងក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច។

ដីកាសម្រេចនេះ មិនត្រូវចូលជាស្ថាពរនៅមុនពេលផុតអំឡុងពេលសម្រាប់ការប្តឹងជំទាស់ដែលបានកំណត់ក្នុងមាត្រា ៤០ នៃច្បាប់ស្តីពីសុំកូនអន្តរប្រទេស។ ក្នុងករណីមានការប្តឹងជំទាស់ចំពោះដីកាសម្រេចនេះ ដីកាសម្រេចនេះមិនត្រូវចូលជាស្ថាពរ រហូតដល់ពេលមានដីកាសម្រេចអំពីបណ្តឹង ជំទាស់នោះ។

## កថាខណ្ឌទី៣: ការទុកដាក់សំណុំឯកសារសុំកូន

រដ្ឋបាលសុំកូនអន្តរប្រទេស និង សាលាដំបូងរាជធានីភ្នំពេញ ត្រូវរក្សាសំណុំឯកសារសុំកូនអន្តរប្រទេស ក្នុងរយៈពេល ៦០ (ហុកសិប) ឆ្នាំ គិតពីកាលបរិច្ឆេទ ដែលដីកាសម្រេចសុំ

កូនអន្តរប្រទេសនោះចូលជាស្ថាពរ។

សំណុំឯកសារ កំណត់ហេតុទាំងអស់ទាក់ទងនឹងសុំកូនអន្តរប្រទេស ជាក់លាក់ណាមួយ ទោះជារក្សាទុកនៅតុលាការរដ្ឋបាលសុំកូនអន្តរប្រទេស ទីភ្នាក់ងារសុំកូនអន្តរប្រទេស មណ្ឌលកុមារកំព្រា និងអ្នកជំនាញផ្សេងទៀត ដែលពាក់ព័ន្ធនឹងនីតិវិធីសុំកូនអន្តរប្រទេសត្រូវរក្សាទុកជាសម្ងាត់។ ក៏ប៉ុន្តែសំណុំឯកសារ និងកំណត់ហេតុ ឬព័ត៌មានទាំងឡាយណាដែលមាននៅក្នុងសំណុំឯកសារ និងកំណត់ហេតុទាំងនោះ អាចនឹងត្រូវបញ្ចេញទៅតាមការស្នើសុំ ឬការបង្គាប់ជាលាយលក្ខណ៍អក្សររបស់អាជ្ញាធរមានសមត្ថកិច្ច នៅក្នុងព្រះរាជាណាចក្រកម្ពុជា ក្នុងករណីមានតម្រូវការទាក់ទងនិងករណី ឬនីតិវិធីតុលាការដែលកំពុងតែប្រព្រឹត្តទៅ ឬកាលៈទេសៈពិសេសដទៃទៀត។

### កថាខណ្ឌទី៤ : ការអនុញ្ញាតឲ្យកូនសុំមើលសំណុំលិខិតសុំកូន

ឪពុកម្ដាយចិញ្ចឹម អាចដាក់ពាក្យសុំទៅក្រសួងទទួលបន្ទុកវិស័យសង្គមកិច្ច ដើម្បីសុំច្បាប់ចម្លងនៃសំណុំលិខិត ដែលរួមមានអត្តសញ្ញាណរបស់ឪពុកម្ដាយរបស់កូនសុំ ក្រោយដីកាសម្រេចសុំកូនរបស់តុលាការចូលជាស្ថាពរ។ កូនសុំដែលដល់អាយុដឹងខុសត្រូវគ្រប់គ្រាន់ អំពីផលវិបាកនៃការដឹងអត្តសញ្ញាណរបស់ឪពុកម្ដាយបង្កើតបាន ដោយធ្វើការស្នើសុំជាលាយលក្ខណ៍អក្សរមកអាជ្ញាធរកណ្ដាលនៃព្រះរាជាណាចក្រកម្ពុជា ក្នុងករណីការមើលនេះជាឧត្តមប្រយោជន៍របស់កូនសុំ។ កូនសុំដែលឈានចូលអាយុនីតិភាពមានសិទ្ធិមើលសំណុំឯកសារ និងកំណត់ហេតុទាក់ទងនិងអត្តសញ្ញាណខ្លួន។ រដ្ឋបាលសុំកូនអន្តរប្រទេសត្រូវធានា កូនសុំទទួលបានការពិគ្រោះយោបល់សមស្រប មុននឹងមើលព័ត៌មាននៅក្នុងសំណុំលិខិតរបស់ខ្លួន៕

# សកម្មភាពរបស់គណៈមេធាវី

# ១. ទំនាក់ទំនងជាតិ និងអន្តរជាតិ

## ១.១ ទំនាក់ទំនងជាតិ

លោកមេធាវី សួន វិសាល ប្រធានគណៈមេធាវី រួមទាំងក្រុមប្រឹក្សាគណៈមេធាវី បានចូលជួបសំដែងការគួរសមជាមួយឯកឧត្តម អ៊ឹម ឈុនលឹម ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា។

នារសៀលថ្ងៃច័ន្ទ ៨រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី០៧ ខែឧសភា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃ ព្រះរាជាណាចក្រកម្ពុជា រួមទាំងក្រុមប្រឹក្សាគណៈមេធាវីបានចូលជួបសំដែងការគួរសមជាមួយ**ឯកឧត្តម អ៊ឹម ឈុនលឹម** ប្រធានក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា នៅអាគារ (ស) វិមានរដ្ឋចំការមន។



## កិច្ចប្រជុំលើកដំបូងជាមួយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីកាគណៈរដ្ឋមន្ត្រី

នៅព្រឹកថ្ងៃច័ន្ទ ០៦រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី០៤ ខែមិថុនា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវី ដឹកនាំក្រុមប្រឹក្សា និងអគ្គលេខាធិការគណៈមេធាវី ដែលជាក្រុមការងារធ្វើវិសោធនកម្មច្បាប់ស្តីពីលក្ខន្តិកៈមេធាវីបានចូលរួមប្រជុំលើកដំបូងជាមួយ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងយុត្តិធម៌ ឯកឧត្តមរដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម និងតំណាងក្រុមប្រឹក្សាអ្នកច្បាប់នៃទីស្តីកាគណៈរដ្ឋមន្ត្រី ដែលផ្តោតសំខាន់លើការការពារផលប្រយោជន៍វិជ្ជាជីវៈមេធាវីនៅកម្ពុជា ការបង្កើនប្រសិទ្ធិភាពនៃការផ្តល់សេវាច្បាប់នៅកម្ពុជា និងការធ្វើឲមានតុល្យភាពរវាងមេធាវីជាតិ និងមេធាវីអន្តរជាតិ។ កិច្ចប្រជុំលើកដំបូងនេះបានសម្រេចបង្កើតក្រុមការងារបច្ចេកទេសមួយ ដើម្បីធ្វើកិច្ចការនេះឲ្យមានប្រសិទ្ធភាព និងបានទាន់ពេលវេលា។





## ១.២ ទំនាក់ទំនងអន្តរជាតិ

### កិច្ចប្រជុំរវាងគណៈមេធាវី និងប្រធានសមាគមន៍ មេធាវីប្រចាំខេត្តហ្គ័ងស៊ី ប្រទេសចិន

នាថ្ងៃទី១៤កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៨ ខែឧសភា ឆ្នាំ២០១៨ លោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតិឱ្យលោកមេធាវី Huang Zhiwen ប្រធានសមាគមន មេធាវីប្រចាំខេត្តហ្គ័ងស៊ី ប្រទេសចិនចូលជួបសំណេះសំណាល និងសម្តែងការគួរសមនៅទីស្នាក់ការគណៈមេធាវី ។ ក្នុងជំនួបនេះដែរ លោកមេធាវី **សួន វិសាល** បានជម្រាបជូន គណៈប្រតិភូនៃទីក្រុងហ្គ័ងស៊ី អំពីភាពរីកចម្រើននៃគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ពីមួយឆ្នាំទៅមួយឆ្នាំ ហើយលោកមេធាវី Huang Zhiwen ក៏បានជម្រាបជូនលោកមេធាវី **សួន វិសាល** អំពីការប្រព្រឹត្តទៅ និងការវិវត្តន៍នានានៃសមាគមមេធាវីចិនផងដែរ។

ទន្ទឹមនឹងនេះ លោក Huang Zhiwen ប្រធានសមាគមមេធាវីប្រចាំខេត្តហ្គ័ងស៊ី ប្រទេសចិន បានអញ្ជើញលោកប្រធានគណៈមេធាវី និងសហការីទៅទស្សនកិច្ចនៅខេត្តស្វ័យយ័តហ្គ័ងស៊ី។ ក្នុងកិច្ចបញ្ចប់នៃជំនួបនេះ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា និងសមាគម

មេធាវីប្រចាំខេត្តហ្គ័ងស៊ីបានឯកភាពគ្នាជាបឋមលើកិច្ចសហប្រតិបត្តិការ "ផ្លូវមួយខ្សែក្រវ៉ាត់មួយ" សម្រាប់នាពេលអនាគតផងដែរ។



## គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា មានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំសមាគមច្បាប់អាស៊ាន

គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា មានកិត្តិយសទទួលធ្វើជាម្ចាស់ផ្ទះនៃកិច្ចប្រជុំសមាគមច្បាប់អាស៊ាននៅខេត្តសៀមរាបពីថ្ងៃព្រហស្បតិ៍ ០៩ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ០៧ ដល់ថ្ងៃសៅរ៍ ១១ រោច ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី ០៩ ខែ មិថុនា ឆ្នាំ២០១៨។

មុនកិច្ចប្រជុំនេះ នៅវេលាម៉ោង ០៤ រសៀល ថ្ងៃទី ០៧ ខែមិថុនា ឆ្នាំ ២០១៨ គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជាដែលមានលោកមេធាវី **សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធានបានទទួលជួបប្រធានសមាគមច្បាប់អាស៊ាននៃបណ្តាប្រទេសអាស៊ាន រួមមាន ហ្វីលីពីន សឹង្ហបុរី ថៃ ម៉ាឡេស៊ី ឥណ្ឌូនេស៊ី និងភូមា ដើម្បីជម្រាបជូនពីការយកចិត្តទុកដាក់របស់រាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជាក្នុងការបង្កើតសមាគមច្បាប់អាស៊ានកម្ពុជា ដើម្បីឆ្លើយតបទៅនឹងការធ្វើ សមាហរណកម្មកម្ពុជាទៅក្នុងក្របខណ្ឌអាស៊ាន និងពិភពលោក។ ជាការឆ្លើយតប ប្រធានសមាគមច្បាប់នៃបណ្តាប្រទេសអាស៊ាន

បានថ្លែងការកោតសរសើរចំពោះ គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា ជាពិសេសរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា ដែលបានខិតខំបង្កើតឱ្យមានគណៈកម្មាធិការជាតិនៃ សមាគមច្បាប់អាស៊ាននេះឡើងនៅចុងឆ្នាំ២០១៧ ស្របពេលដែលប្រទេសអាស៊ានទាំងអស់បាននឹងកំពុងអនុវត្តសកម្មភាពការងារនេះយ៉ាងសកម្ម។ គួសបញ្ជាក់ថា កាលពីថ្ងៃទី ២៣ សីហា ឆ្នាំ២០១៧ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានចុះហត្ថលេខាលើអនុក្រឹត្យលេខ ១២៤ អនក្រ.បក ចុះថ្ងៃទី៣ ខែសីហា ឆ្នាំ២០១៧ ដើម្បីបង្កើតគណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជា ដែលមានប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ជាប្រធាន អនុប្រធាន អចិន្ត្រៃយ៍ និងសមាជិកមួយចំនួនតាមការចាំបាច់។

គណៈកម្មាធិការជាតិនៃសមាគមច្បាប់អាស៊ានកម្ពុជានេះ ជាសេនាធិការឱ្យរាជរដ្ឋាភិបាលក្នុងការបង្ហាញពីទិដ្ឋភាពច្បាប់របស់កម្ពុជាលើឆាកអន្តរជាតិ ជម្រុញការអភិវឌ្ឍន៍សេដ្ឋកិច្ចរបស់កម្ពុជា និងទាក់ទាញវិនិយោគគិន។







*កិច្ចប្រជុំសមាគមច្បាប់អាស៊ានកម្ពុជា*

ប្រធានការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តសៀមរាបបានជួបសំណេះសំណាលជាមួយប្រធានសមាគមមេធាវីប្រចាំខេត្តហ្គ័ងស៊ី ប្រទេសចិន និងចែករំលែកបទពិសោធន៍ការងារ

នាថ្ងៃទី១៥កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែឧសភា ឆ្នាំ២០១៨ លោកមេធាវី **ឈរ លីថៃ** ប្រធានការិយាល័យប្រតិភូគណៈមេធាវីប្រចាំខេត្តសៀមរាបបានអនុញ្ញាតឲ្យលោកមេធាវី Huang Zhiwen ប្រធានសមាគមមេធាវីប្រចាំខេត្តហ្គ័ងស៊ី ប្រទេសចិនបានចូលជួបសំណេះសំណាល និងចែករំលែកបទពិសោធន៍ ការងារទៅវិញទៅមក ជាពិសេសអំពីជំនួយផ្នែកច្បាប់ជូនជនក្រីក្រ។ កិច្ចប្រជុំនេះបានបញ្ចប់ដោយស្មារតីទទួលខុសត្រូវខ្ពស់។



## ២. សកម្មភាពផ្សព្វផ្សាយច្បាប់តាមរយៈសិក្ខាសាលា

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងអង្គការសេរីភាពអាស៊ី (Liberty Asia) រៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពី "នីតិវិធី នៃការការពារក្តី លើករណីជួញដូរមនុស្ស និងការកេងប្រវ័ញ្ច"

នាថ្ងៃច័ន្ទ ១រោច ខែពិសាខ ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២ ត្រូវនឹងថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជានិងអង្គការសេរីភាពអាស៊ី (Liberty Asia) រៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពី "នីតិវិធី នៃការការពារក្តីលើករណីជួញដូរមនុស្ស និង ការកេងប្រវ័ញ្ច" ក្រោមអធិបតីភាពលោកមេធាវី **ព្រហ្ម ទិចិត្រអរុទ្ធរា** អគ្គលេខាធិការនៃ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា។



## សិក្ខាសាលាក្រោមប្រធានបទ "ការចូលរួមរបស់អ្នកអនុវត្តច្បាប់ និងស្ថាប័នហិរញ្ញវត្ថុក្នុងការ ប្រឆាំងការជួញដូរមនុស្ស"

នាថ្ងៃព្រហស្បតិ៍ ៥ កើត ខែស្រាពណ៍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១៦ ខែសីហា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយអង្គការសេរីភាព អាស៊ី (Liberty Asia) និងអង្គការតម្លាភាពកម្ពុជា បានរៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តី ពី"ការចូលរួមរបស់អ្នកអនុវត្តច្បាប់ និងស្ថាប័នហិរញ្ញវត្ថុក្នុងការប្រឆាំងការជួញដូរមនុស្ស" នៅ សណ្ឋាគាសាន់វេ ក្រោមអធិបតីភាពលោកមេធាវី **ព្រហ្ម ទិចិត្រអរុទ្ធរា** អគ្គលេខាធិការនៃគ ណៈមេធាវី។ សិក្ខាសាលានេះ មានការចូលរួមធ្វើបទបង្ហាញដោយអ្នកស្រី **ណយ សុធារី** ទីប្រឹក្សាច្បាប់ អង្គការសេរីភាពអាស៊ី (Liberty Asia) , អ្នកស្រី Serena Lillywhite នាយក

ប្រតិបត្តិ អង្គការតម្លាភាពអន្តជាតិអូស្ត្រាលី, អ្នកស្រី Kristin Rosella ពី អង្គការសេរីភាពអាស៊ី និងលោកមេធាវី សុក **សំអឿន**។






## បាឋកថា "ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ"

នាថ្ងៃសៅរ៍១២កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៦ ខែឧសភា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា មានកិត្តិយសដ៏ខ្ពង់ខ្ពស់ដែលឯកឧត្តម **បណ្ឌិត ឱម យ៉ិនទៀង** ទេសរដ្ឋមន្ត្រី និងជាប្រធានអង្គភាពប្រឆាំងអំពើពុករលួយ បានផ្ដល់នូវបាឋក ថា"ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ" ដល់កម្មសិក្សាការីសុក្រឹតការវិជ្ជាជីវៈមេធាវីវគ្គទី៥។

នៅក្នុងឱកាសនេះដែរ លោក**មេធាវី សួន វិសាល** ប្រធានគណៈមេធាវីបានធ្វើរបាយការណ៍ជូន គណៈអធិបតីអំពីការវិវត្តន៍ថ្មីៗដែលគណៈមេធាវីបានសម្រេចបាន ព្រមទាំងលើកឡើងពីការចូលរួមរបស់មេធាវី ក្នុងការប្រយុទ្ធប្រឆាំងអំពើពុករលួយនៅក្នុងព្រះរាជាណាចក្រកម្ពុជា។ នៅក្នុងបាឋកថាដ៏មានសារសំខាន់នេះ ឯកឧត្តមទេសរដ្ឋមន្ត្រីបានលើកនូវចំណុចសំខាន់ៗអំពីតួនាទីរបស់អង្គភាពប្រឆាំងអំពើពុករលួយ និងប្រសិទ្ធភាពនៃការងាររបស់ស្ថាប័នទាំងមូលដើម្បីលុបបំបាត់អំពើពុករលួយ។



*បាឋកថា "ច្បាប់ស្ដីពីការប្រឆាំងអំពើពុករលួយ"*

### សិក្ខាសាលាក្រោមប្រធានបទ "បណ្តឹងតវ៉ារបស់តតិយជន" ធ្វើបទបង្ហាញដោយលោកមេធាវី អ៊ឺវ ប៉ូលី និងលោក MAEDA YUTA (ជំនាញការជប៉ុនប្រចាំ JICA)

នាថ្ងៃអាទិត្យ ១៣កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៧ ខែឧសភា ឆ្នាំ២០១៨ គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា សហការជាមួយវិភាគទានច្បាប់ បានរៀបចំសិក្ខាសាលា ក្រោមប្រធានបទស្តីពី "បណ្តឹងតវ៉ារបស់តតិយជន" ក្រោមអធិបតីភាព លោកមេធាវី កុយ នាម អគ្គលេខាធិការរងនៃគណៈមេធាវី។

សិក្ខាសាលានេះ មានការចូលរួមធ្វើបទបង្ហាញដោយលោកមេធាវី អ៊ឺវ ប៉ូលី និងលោក ចៅក្រម MAEDA YUTA (ជំនាញការជប៉ុនប្រចាំJICA) ធ្វើនៅមជ្ឈមណ្ឌលសហប្រតិបត្តិការ កម្ពុជា-កូរ៉េ (CKCC) ក្នុងបរិវេណសាកលវិទ្យាល័យភូមិន្ទភ្នំពេញ៕



## ៣. កិច្ចប្រជុំប្រតិភូមេធាវីរាជធានី/ខេត្តប្រចាំត្រីមាស

### កិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ក្រោមអធិបតីភាពលោកមេធាវី សួន វិសាល ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

នាថ្ងៃសុក្រ ០២រោច ឆ្នាំច សំរឹទ្ធិស័ក ព.ស. ២៥៦២ ត្រូវនឹងថ្ងៃទី២៩ ខែមិថុនា ឆ្នាំ ២០១៨ នៅទីស្នាក់ការគណៈមេធាវី បានរៀបចំកិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត ក្រោមអធិបតីភាពលោក**មេធាវី សួន វិសាល** ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដើម្បីពិភាក្សាការងារប្រតិភូប្រចាំត្រីមាស។





*កិច្ចប្រជុំប្រតិភូគណៈមេធាវីប្រចាំរាជធានី-ខេត្ត នៅគណៈមេធាវី*

# ៤. សេចក្ដីជូនដំណឹង និងសេចក្ដីសម្រេចផ្សេងៗក្នុងត្រីមាសទី២

## ៤.១ សេចក្ដីណែនាំ ស្ដីពី ការធ្វើលិខិតបញ្ជាក់អតីតភាពការងាររបស់ជំនួយការមេធាវី

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា

ប្រធានគណៈមេធាវី
មេធាវី សួន វិសាល
ក្រុមប្រឹក្សាគណៈមេធាវី
១-មេធាវី សាំង ចន្ទ្ធៈ
២-មេធាវី អ៊ឹង តិរិយា
៣-មេធាវី កែវ ជី
៤-មេធាវី អ៊ុំ ម៉ុនី
៥-មេធាវី ឡេង សំអូ
៦-មេធាវី ជា សុភក្ត្រ
៧-មេធាវី សាត់ ជួយ
៨-មេធាវី ផាន ផាលិត
៩-មេធាវី ជូ ចាន់នីរ៉ា
១០-មេធាវី កេង សុផាន់ណា
១១-មេធាវី អ៊ី ឧសភា
១២-មេធាវី សេង សុខលីម
១៣-មេធាវី លីម សុខណ្ណា
១៤-មេធាវី ឈឹម វិរៈ
១៥-មេធាវី សំ សុភក់
១៦-មេធាវី ឈួន ហេងឌួ
១៧-មេធាវី ប៊ូ វិតារ៉េ
១៨-មេធាវី សី គីម
១៩-មេធាវី លឹម ម៉ិលសូត
២០-មេធាវី លីម ច័ន្ទលីដា
២១-មេធាវី កែ វិសាល
២២-មេធាវី ហុង លីហួង
២៣-មេធាវី ង៉ា ពិសី
២៤-មេធាវី ជា ហុងរី
២៥-មេធាវី សៅ ឥណ្ណា
២៦-មេធាវី អ៊ុង ទិវាចន្ទ
២៧-មេធាវី ណើ សម្បត្តិ

លេខ ១៦១០ /គម.សណេន/១៨

ថ្ងៃព្រហស្បតិ៍ ៩កើត ខែបឋមាសាឍ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២១ ខែមិថុនា ឆ្នាំ២០១៨

**សេចក្ដីណែនាំ**

**ស្ដីពី**

**ការធ្វើលិខិតបញ្ជាក់អតីតភាពការងាររបស់ជំនួយការមេធាវី**

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាសូមធ្វើការណែនាំដល់ប្រធានក្រុមហ៊ុនមេធាវី ប្រធានក្រុមមេធាវី និងប្រធានការិយាល័យមេធាវី ទូទាំងរាជធានី-ខេត្ត ជ្រាបថា គណៈមេធាវីបានទទួលលិខិតលេខ៥២០ ម.ហ.ក/១៨ ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៨ របស់មហាអយ្យការអមសាលាឧទ្ធរណ៍ ដែលតម្រូវឱ្យលិខិតបញ្ជាក់អតីតភាពការងាររបស់បេក្ខជនដែលដាក់ពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី មានការបញ្ជាក់ឱ្យបានច្បាស់នូវលេខ ថ្ងៃ ខែ ឆ្នាំ ឈ្មោះ ហត្ថលេខា (ច្បាប់ដើម) ភ្ជាប់មកជាមួយពាក្យសុំចូលប្រកបវិជ្ជាជីវៈមេធាវី ដើម្បីបំពេញលក្ខខណ្ឌស្នើសុំផ្ដល់យោបល់លើការសុំចូលប្រកបវិជ្ជាជីវៈមេធាវី ពីឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍។

បានទទួលការណែនាំនេះ សូម ប្រធានក្រុមហ៊ុនមេធាវី ប្រធានក្រុមមេធាវី និងប្រធានការិយាល័យមេធាវី មេត្តាចូលរួមអនុវត្តឱ្យមានប្រសិទ្ធភាព។

**គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**
**ប្រធាន**

មេធាវី សួន_វិសាល

**ចម្លងជូន៖**
-ឯកឧត្ដមអគ្គព្រះរាជអាជ្ញាអមសាលាឧទ្ធរណ៍
"ដើម្បីជូនជ្រាប"
-ឯកសារ-កាលប្បវត្តិ

## ៤.២ សេចក្តីជូនដំណឹងស្តីពី ទំរង់របាយការណ៍បញ្ចប់កម្មសិក្សាថ្មី

សេចក្តីជូនដំណឹងស្តីពី ទម្រង់របាយការណ៍បញ្ចប់កម្មសិក្សាថ្មី

សូមចុចតំណភ្ជាប់ខាងក្រោមដើម្បីមើលទំរង់របាយការណ៍បញ្ចប់កម្មសិក្សាថ្មី ៖ https://goo.gl/okorL3

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា


ប្រធានគណៈមេធាវី

មេធាវី សួន វិសាល

ក្រុមប្រឹក្សាគណៈមេធាវី

១-មេធាវី សាំង ចន្ទណ:

២-មេធាវី អ៊ុង ភីរ៉ុណ

៣-មេធាវី កែត យី

៤-មេធាវី អ៊ុច ប៊ុលី

៥-មេធាវី ខៀវ សំបុរ

៦-មេធាវី ជា សុគន្ធ

៧-មេធាវី សាន់ ជួយ

៨-មេធាវី ផាន ផានិត

៩-មេធាវី ជូ ចាន់ធីរ៉ា

១០-មេធាវី កេង សុម៉ាលា

១១-មេធាវី ម៉ី នសតា

១២-មេធាវី សេង សុខឃីម

១៣-មេធាវី លឹម សុវណ្ណា

១៤-មេធាវី ឈឹម តិរម្យ

១៥-មេធាវី សំ សុគង់

១៦-មេធាវី នង មាឧទ្ធ

១៧-មេធាវី ម៉ូ ចិតាពៅ

១៨-មេធាវី លី ភឹង

១៩-មេធាវី យឹម ចិស្សុត

២០-មេធាវី លឹម ច័ន្ទលីដា

២១-មេធាវី កៃ វិសាល

២២-មេធាវី ហូ លីហុង

២៣-មេធាវី ឆ៉ា ពិសី

២៤-មេធាវី ជា ហុងរី

២៥-មេធាវី សៅ កញ្ញា

២៦-មេធាវី ម៉ុង មិមានច័ន្ទរ៉ា

២៧-មេធាវី ឈី សម្បត្តិ


លេខ ១៣៧៥ /គម/១៨

ថ្ងៃ ព្រហស្បតិ៍ ១០កើត ខែជេស្ឋ ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

រាជធានីភ្នំពេញ ថ្ងៃទី ២៤ ខែ ឧសភា ឆ្នាំ២០១៨

**ជម្រាបជូន**

**កម្មសិក្សាការី និងគ្រូកម្មសិក្សាមេធាវីទាំងអស់**

**កម្មវត្ថុ:** សេចក្តីណែនាំស្តីពីទម្រង់របាយការណ៍បញ្ចប់កម្មសិក្សាថ្មី

**យោង:** សេចក្តីសម្រេចលេខ ៧១១ /សសរគម/១៧ ចុះថ្ងៃទី០៧ ខែធ្នូ ឆ្នាំ២០១៧ របស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ។

តបតាមកម្មវត្ថុ និងយោងខាងលើ ខ្ញុំមានកិត្តិយស សូមជូនដំណឹងដល់កម្មសិក្សាការី ដែលកំពុងកម្មសិក្សា និងគ្រូកម្មសិក្សាមេធាវីទាំងអស់ថា: នាសម័យប្រជុំថ្ងៃទី ២៧ ខែ តុលា ឆ្នាំ ២០១៧ សមាជិកក្រុមប្រឹក្សាគណៈមេធាវីបានសម្រេច កំណត់ឲកម្មសិក្សាការីត្រូវធ្វើរបាយការណ៍បញ្ចប់កម្មសិក្សារយៈពេល ១២ (ដប់ពីរ) ខែ តាមទម្រង់ របាយការណ៍បញ្ចប់កម្មសិក្សាថ្មី ដូចមានគំរូភ្ជាប់មកជាមួយស្រាប់ ។

នៅក្នុងរបាយការណ៍ថ្មីនេះត្រូវមានសេចក្តីផ្តើម តួសេចក្តី និងសេចក្តីបញ្ចប់ និងមានកំរាស់ ២០ (ម្ភៃ)ទំព័រ ដោយមានរឹមខាងលើប្រវែង ២ (ពីរ)សង់ទីម៉ែត្រ និងខាងក្រោមប្រវែង២.៥(ពីរកន្លះ)សង់ទីម៉ែត្រ។ ចំពោះរឹមខាងស្តាំប្រវែង ១.៥ (មួយកន្លះ) សង់ទីម៉ែត្រ និងខាងឆ្វេងប្រវែង២.៥(ពីរកន្លះ)សង់ទីម៉ែត្រ ។ ក្នុងរយៈពេលធ្វើកម្មសិក្សានេះ កម្មសិក្សាការីត្រូវការពាររឿងក្តីព្រហ្មទណ្ឌចំនួន ៣ (បី)យ៉ាងតិច រឿងក្តីរដ្ឋប្បវេណីចំនួន៣ (បី)យ៉ាងតិច និង ពិគ្រោះយោបល់ច្បាប់ចំនួន ៥ (ប្រាំ)ករណីយ៉ាងតិច ។

កម្មសិក្សាការីត្រូវផ្តល់ព័ត៌មានឲបានត្រឹមត្រូវនៅក្នុងរបាយការណ៍ ។ ករណីកម្មសិក្សាការីណាម្នាក់មានចេតនាផ្តល់ព័ត៌មានមិនត្រឹមត្រូវ កម្មសិក្សាការីនោះនឹងត្រូវទទួលទណ្ឌកម្ម ។ ទម្រង់របាយការណ៍ថ្មីនេះនឹងអនុវត្តចាប់ពីថ្ងៃ ទី២៤ ខែឧសភា ឆ្នាំ

1

អគារស្ថិតនៅកាច់ជ្រុងផ្លូវលេខ ១១២៥ និងផ្លូវលេខ ១៩៣០ សង្កាត់ភ្នំពេញថ្មី ខណ្ឌសែនសុខ រាជធានីភ្នំពេញ ប្រអប់សំបុត្រលេខ ៖១៥៨៧ , ទូរស័ព្ទ: (៨៥៥-២៣) ៦២២ ៧០៧០
E-mail: info@bakc.org.kh, website: www.bakc.org.kh

២០១៨ តទៅ ហើយ អនុវត្តចំពោះ តែកម្មសិក្សាការីណាដែលចាប់ផ្តើមធ្វើកម្មសិក្សាក្រោយពីការជូនដំណឹងពីការណែនាំនេះតែប៉ុណ្ណោះ ។

លើសពីនេះ ខ្ញុំសូមជម្រាបផងដែរថា ក្នុងករណីកម្មសិក្សាការីណាម្នាក់មិនព្រមដាក់ពាក្យសុំធ្វើកម្មសិក្សា ឬលើសពេលកំណត់នៃការធ្វើកម្មសិក្សា ឬសុំពន្យា កម្មសិក្សា កម្មសិក្សាការីនោះនឹងត្រូវបង់ប្រាក់សុំពន្យាពេលធ្វើកម្មសិក្សា ជារៀងរាល់ ខែ គឺស្មើនឹងពាក់កណ្តាលនៃប្រាក់ភាគទានមេធាវីពេញសិទ្ធិ ។ គណៈមេធាវីនឹងជូនដំណឹងដល់សាមីខ្លួនចំពោះការខកខានមិនបានបង់ប្រាក់នេះ ។ ក្នុងករណីសាមី ខ្លួនមិនព្រមមកបង់ប្រាក់សុំពន្យាពេលធ្វើកម្មសិក្សាក្នុងអំឡុងពេល ២ខែយ៉ាងយូរ បន្ទាប់ពីការជូនដំណឹងដោយគ្មានមូលហេតុ គណៈមេធាវីចាត់ទុកថា បេក្ខជននោះបោះបង់ចោលការចូលប្រកបវិជ្ជាជីវៈមេធាវី ហើយត្រូវលុបឈ្មោះចេញពីបញ្ជីកម្មសិក្សា។

ក្នុងករណី កម្មសិក្សាការី និងគ្រូកម្មសិក្សា មិនយល់ពីចំណុចណាមួយនៃ របាយការណ៍គំរូថ្មីនេះ សូមទាក់ទងមកគណៈមេធាវីក្នុងម៉ោងធ្វើការ ដើម្បីទទួលបានព័ត៌មានបន្ថែម ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមកម្មសិក្សាការី និងគ្រូកម្មសិក្សាទាំងអស់អនុវត្តតាមសេចក្តីសម្រេចរបស់គណៈមេធាវី និងការណែនាំនេះឲបានត្រឹមត្រូវ និងមានប្រសិទ្ធភាពខ្ពស់ ។

សូមកម្មសិក្សាការី និងគ្រូកម្មសិក្សាមេធាវីទាំងអស់ទទួលនូវការរាប់អានដ៏ស្មោះស័គ្រអំពីខ្ញុំ ។

ប្រធាន

មេធាវី សួន_វិសាល

## គណៈកម្មការព្រឹត្តិបត្រ

| | |
|---|---|
| ១-ឯកឧត្តម សួន វិសាល | ចាងហ្វាងការផ្សាយ |
| ២-លោកមេធាវី កុយ នាម | និពន្ធនាយក |
| ៣-លោកមេធាវី លីវ សុវណ្ណា | លេខាធិការ |

## នាយកដ្ឋានស្រាវជ្រាវ បោះពុម្ព និងផ្សព្វផ្សាយ

| | |
|---|---|
| ១-លោកមេធាវី កែ ប៊ុនធឿន | ប្រធាននាយកដ្ឋាន |
| ២-លោកមេធាវី សេង សុខឃីម | អនុប្រធាននាយកដ្ឋាន |
| ៣- លោកស្រីមេធាវី លឹម ច័ន្ទលីដា | អនុប្រធាននាយកដ្ឋាន |
| ៤-លោកមេធាវី ម៉ៃ ច័ន្ទសត្យា | អនុប្រធាននាយកដ្ឋាន |
| ៥-លោក ឃឹម ចាន់ធឿន | អនុប្រធាននាយកដ្ឋាន |
| ៦-លោកមេធាវី វ៉ា សំរិត | ប្រធានការិ. ព្រឹត្តិបត្រ |
| ៧-លោកមេធាវី ហួត សុវណ្ណា | បុគ្គលិកស្ម័គ្រចិត្ត |
| ៨-លោក ប៉េង វិច្ឆិកា | ប្រធានការិ.ព័ត៌មានវិទ្យា |
| ៩-លោក ថា ប៊ុនថៃ | បុគ្គលិកបច្ចេកទេស |
| ១០-លោក ខន សុខេង | បុគ្គលិកស្ម័គ្រចិត្ត |
| ១១-លោក ស្រេង សីហប៊ុននុត | បុគ្គលិកស្ម័គ្រចិត្ត |
| ១២-លោក ជុំ ប៊ុនណារាយ | បុគ្គលិកហាត់ការ |
| ១៣.លោក នួន វ៉ា | បុគ្គលិកហាត់ការ |

ឧបត្ថម្ភការបោះពុម្ពផ្សាយដោយ

សម្តេចវិបុលសេនាភក្តី សាយ ឈុំ

លោកមេធាវី សារិន ដេណូវ៉ា

DFDL

គណៈមេធាវី នៃព្រះរាជាណាចក្រកម្ពុជា